# ការត្រួតពិនិត្យមីន



# កម្ពុជា

## ២០០១



**របាយការណ៍ប្រចាំឆ្នាំលើកទី៣ (២០០០-២០០១)**

**រៀបចំដោយក្រុមយុទ្ធនាការលុបបំបាត់មីនកម្ពុជា**

Cambodia CAMPAIGN TO BAN LANDMINES

LANDMINE MONITOR

**មាតិកា** **ទំព័រ**

គោលនយោបាយលុបបំបាត់មីន (Mine Ban Policy)……………………………………..01

ការផលិតមីន (Production)…………………………………………………………………..06

ការដឹកជញ្ជូនគ្រាប់មីន (Transfer)……………………………………………………………06

ការបំផ្លាញឃ្លាំងស្តុកមីន (Destruction of Stockpiles) ……………………………………..…07

ការប្រើប្រាស់ (Use)……………………………………………………………………………08

ពួកឧទ្ទាម (Non State Actor) …………………………………………………………………..08

ការផ្តល់មូលនិធិសំរាប់សកម្មភាពមីន ( Mine Action Funding ) ………………………..08

ការស្រាវជ្រាវ និង ការអភិវឌ្ឍន៏(Research and Development)…………………………15

បញ្ហាដែលកើតមានដោយសារមីន (Mine Problem) ……………………………………17

ការស្រាវជ្រាវនិងការប៉ាន់ស្មាន (Survey and Assessment) ……………………………...18

ការបោសសំអាតមីន (Mine Clearance) ……………………………………………………20

ផែនការការងារ និង ការសំរបសំរួល (Coordination and Planning) ………………….32

ការចាត់ចែងនិងប្រើប្រាស់ដីធ្លី (Land Use Management)…………………………………34

ការបំផុសការយល់ដឹងពីមីន (Mine Awareness) ……………………………………………37

គ្រោះថ្នាក់ដោយសាមីនក្នុងឆ្នាំ ២០០០ (Mine Casualties 2000)………………………40

ការឧបត្ថម្ភអ្នករងគ្រោះដោយសារមីន (Mine Victim Assistance) ………………………44

## គោលនយោបាយលុបបំបាត់មីន (Mine Ban Policy)

សន្ធិសញ្ញាលុបបំបាត់មីនបច្ចុប្បន្ននេះ គឺត្រូវបានប្រកាសជាសាធារណៈសំរាប់ធ្វើជាឯកសារយោងក្នុងគោលនយោបាយសកម្មភាពមីននៅកម្ពុជា ។

ប្រទេសកម្ពុជាបានចុះហត្ថលេខាលើសន្ធិសញ្ញាលុបបំបាត់មីនកាលពីថ្ងៃទី ៣ ខែធ្នូ ឆ្នាំ១៩៩៧ ហើយបានដាក់ជូនឯកសារផ្តល់សច្ចាប័នដល់អគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិនៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ១៩៩៩ ។ សន្ធិសញ្ញាលុបបំបាត់មីនបានចូលជាធរមាននៅកម្ពុជា កាលពីថ្ងៃទី ១ ខែមករា ឆ្នាំ២០០០ ។ តម្លាភាពនៃរបាយការណ៍កម្ពុជាដែលកំនត់ដោយមាត្រាទី ៧ នៃសន្ធិសញ្ញាលុបបំបាត់មីនត្រូវបានដាក់ជូន កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០០ ។

គ្រាប់មីន និង គ្រាប់មិនទាន់ផ្ទុះ ជាកេរ្តិ៍តំណែលដ៏ជូរចត់នៅកម្ពុជា ដែលបន្សល់ទុកតាំងពីសម័យសង្គ្រាមរាប់ទសវត្សរ៍ ហើយបង្ករអោយមានជនភៀសសឹករាប់លាននាក់ និង បំផ្លិចបំផ្លាញរចនាសម្ព័ន្ធប្រទេសមួយភាគធំ ។ '' ទីតាំងនៃអាវុធជាតិផ្ទុះទាំងនេះ ជាពិសេសគ្រាប់មីនប្រឆាំងមនុស្សនៅតែគ្មានសញ្ញាសំគាល់ទីតាំងរបស់វាដែលសេសសល់ដ៏ច្រើនសន្ធឹកសន្ធាប់ ក្នុងតំបន់មួយភាគធំនៃផ្ទៃប្រទេសនៅឡើយ ។ ផលវិបាកដែលកើតមាននោះ គឺប្រជាជននៅតែត្រូវប្រថុយនឹងគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរដោយមិនអាចធានាសុវត្ថិភាពក្នុងការចិញ្ចឹមជីវិត ការតាំងលំនៅដ្ឋាន និង ការរៀបចំដីធ្លីសំរាប់ដាំដុះ និង ចិញ្ចឹមសត្វ ហើយគំរោងការស្តារនិងកសាងឡើងវិញដ៏ចាំបាច់ទាំងឡាយក៏ត្រូវរាំងស្ទះមិនអាចដំណើរការបាន '' នេះជាសំដីអះអាងរបស់លោក Ian Bullpitt ជាអ្នកនិពន្ធអត្ថបទស្តីពីការស្វែងយល់ពីអនាគតសកម្មភាពមីននៅកម្ពុជា [1] ។

អត្ថបទពិសេសនេះជាលទ្ធផលបានមកពីលំដាប់នៃសិក្ខាសាលា និង កិច្ចពិភាក្សាស្តីពីសកម្មភាពមីនកំរិតខ្ពស់បំផុត ដែលត្រូវបានលើកឡើងក្នុងឱកាសកិច្ចប្រជុំស្តីពីអនាគតនៃសកម្មភាពមីន ក្រោមអធិបតីភាពរបស់សម្តេចនាយករដ្ឋមន្ត្រីកាលពីថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០០០ ។

នៅឱកាសកិច្ចប្រជុំនោះ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានមានប្រសាសន៍ថា '' ដូចអស់លោក លោកស្រីបានជ្រាបច្បាស់ហើយថា សកម្មភាពកំចាត់មីនត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកថាជាអាទិភាពចំបងក្នុងវិស័យកសាង និង អភិវឌ្ឍន៍ប្រទេសជាតិសាជាថ្មីឡើងវិញ ជាពិសេសដើម្បីជាប្រទីបឆ្ពោះទៅសំរេចបានការកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា ។ ការបោសសំអាតមីនមិនត្រឹមតែជាបញ្ហាសន្តិសុខសង្គម

[1] Bullpit Ian: ''Summary of Discussions and Recommendations Relating to National Strategy and Management Of The Mine Action Sector Within Cambodia In The and Long Term Beyond 2000.'' P.P. Nov. 5, 2000. p. 2

ប៉ុណ្ណោះទេ តែវាទាក់ទងទៅនឹងបញ្ហាសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ផងដែរនិយាយរួម ពិសេសសំរាប់ករណីការចែកចាយដីធ្លី និង រក្សាសុវត្ថិភាពជូនប្រជាកសិករក្រីក្រក្នុងតំបន់ដាច់ស្រយាល ។ ដោយទទួលស្គាល់នូវសារៈសំខាន់នៃរបៀបវារៈនេះ ប្រទេសកម្ពុជាបានក្លាយទៅជាប្រទេសហត្ថលេខីដែលគាំទ្រពេញទីដល់អនុសញ្ញាហាមប្រាមការប្រើប្រាស់ ការស្តុកទុក និង ការនាំចេញគ្រាប់មីនប្រឆាំងមនុស្ស និង ការបំផ្លាញគ្រាប់មីនគ្រប់ប្រភេទកាលពីថ្ងៃទី ៣ ខែធ្នូ ឆ្នាំ១៩៩៧ នៅទីក្រុងអុតតាវ៉ា ។ សកម្មភាពកន្លងមករបស់យើង បានឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តសន្ធិសញ្ញានេះ ។ ស្នាដៃទាំង ប៉ុន្មានដែលយើងសំរេចបានក្នុងវិស័យនេះ មិនអាចកាត់ផ្តាច់ពីជំនួយដ៏សប្បុរស និង មិនអាចកាត់ថ្លៃបានរបស់បណ្តាប្រទេសជាដៃគូអភិវឌ្ឍន៍ទាំងអស់របស់យើងបានឡើយ ។ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយក៏រិតខ្ពស់បំផុតក្នុងការពង្រឹង CMAC មជ្ឈមណ្ឌលកម្មភាពមីនកម្ពុជា អោយទៅជាអង្គភាពទទួលខុសត្រូវបោសសំអាតមីនរបស់ជាតិ និង ផ្តល់យន្តការក្នុងការអនុវត្តការទទួលខុសត្រូវនេះអោយមានប្រសិទ្ធិភាពក្រោមអនុសញ្ញាអុតតាវ៉ានេះ ''[2] ។

ឯកឧត្តម សុខ អាន ក្នុងឱកាសកិច្ចប្រជុំថ្ងៃថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០០០ នេះដែរបានបន្តថា ''យើងត្រូវតែស្វះស្វែងសំរេចអោយបានដំណោះស្រាយទូលំទូលាយមួយសំរាប់កេរ្តិ៍តំណែលនៃគ្រាប់មីនក្នុងស្មារតីអនុញ្ញាអុតតាវ៉ា ។ ការបោសសំអាតមីនដ៏មានប្រសិទ្ធិភាព និង ការប្រើប្រាស់ដីធ្លីដោះមីនរួចជាបន្ទាប់ គឺ ជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយមួយចំនួនដែលដាក់ចេញដោយរាជរដ្ឋាភិបាលក្នុងការឆ្លើយតបផ្ទាល់ និង ជាបន្ទាន់ទៅនឹងស្ថានភាពយ៉ាប់យ៉ឺនរបស់ប្រជាជនក្រីក្រ ។ នេះជាមធ្យោបាយដ៏ឆ្នើមក្នុងការលុបបំបាត់ទុគ៌តភាព កាត់បន្ថយភាពក្រីក្រ និង ធានាកិច្ចអភិវឌ្ឍន៍អោយមានដំណើរការល្អក្នុងប្រទេស[3]''។

ឯកឧត្តម អៀង ម៉ូលី បានថ្លែងនៅក្នុងកិច្ចប្រជុំកាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០០ ថា '' ប្រទេសកម្ពុជាស្ថិតនៅជួរមុខគេក្នុងចំនោមប្រជាជាតិដែលកំពុងប្រយុទ្ធប្រឆាំងនឹងគ្រាប់មីន ។ ព្រះរាជាណាចក្រកម្ពុជាបានធ្វើជាប្រទេសស្នូលក្នុងដំនើរការសន្ធិសញ្ញាអុតតាវ៉ា ។ រដ្ឋសភាជាតិបានផ្តល់សច្ចាប័នជាឯកច្ឆ័ន្ទលើសន្ធិសញ្ញានេះកាលពីខែឧសភា ឆ្នាំ១៩៩៩ ។ ចាប់តាំងពីកិច្ចប្រជុំលើកទី ១ នៃបណ្តារដ្ឋជាសមាជិកសន្ធិសញ្ញានៅទីក្រុងម៉ាពូតូ កាលពីឆ្នាំទៅប្រទេសកម្ពុជា និង ប្រទេសបារាំងបានសំរេចធ្វើជាសហប្រធាននៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃក្រុមជំនាញសកម្មភាពកំចាត់មីន ។ ឆ្នាំនេះក្នុងឱកាសកិច្ចប្រជុំលើកទី ២ នៃបណ្តារដ្ឋជាសមាជិកសន្ធិសញ្ញានៅទីក្រុងហ្សឺណែវ ប្រទេសកម្ពុជាត្រូវបានជាប់ឆ្នោតជាអនុប្រធានមួយរូបនៃអង្គប្រជុំ ។ ដោយមានច្បាប់លុបបំបាត់មីនជាធរមានរបស់ជាតិ ដោយធ្វើសកម្មភាពជាងប្រាំពីរឆ្នាំក្នុងការដោះមីនផ្ទាល់នៅនឹងកន្លែង ដោយមានការបំផ្លាញ

[2] Statement of Samdech Hun Sen, Prime Minister of Cambodia, on 16 November, 2000, P. P. Cambodia.
[3] Statement of H. E Sok An, Minister of Council of Cambodia, on 16 November, 2000, P. P. Cambodia.

ឃ្លាំងស្តុកមីនដែលគេរកឃើញជាប់ជាប្រចាំ ដោយបានចែករំលែកបទពិសោធន៍ក្នុងសកម្មភាពមីនកម្ពុជាជូនដល់ប្រជាជាតិឯទៀតក្នុងពិភពលោកនោះ ប្រទេសកម្ពុជាកំពុងបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះសន្ធិសញ្ញាអុតតាវ៉ាបានយ៉ាងពិតប្រាកដ [4] ''។

ច្បាប់ហាមឃាត់ការប្រើប្រាស់គ្រាប់មីនបំផ្លាញមនុស្ស [5] ជាច្បាប់ក្នុងស្រុករបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តនូវសន្ធិសញ្ញាលុបបំបាត់មីន ។ ច្បាប់នេះត្រូវបានអនុម័តដោយរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៩ ហើយបានចូលជាធរមាននៅពេលព្រះមហាក្សត្រព្រះបាទ នរោត្តម សីហនុ ទ្រង់ឡាយព្រះហត្ថលេខា កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៩ ។ ច្បាប់នេះហាមប្រាមការផលិតមីន ការប្រើប្រាស់ ការកាន់កាប់ ការដឹកជញ្ជូន ការជួញដូរ ការនាំចេញ និង នាំចូលគ្រាប់មីន ។ ច្បាប់នេះដាក់ទោសកំរិតព្រហ្មទណ្ឌដោយរាប់បញ្ចូលការពិន័យជាប្រាក់ និង ការដាក់អោយជាប់ពន្ធនាគារ ចំពោះជនល្មើសដែលជាជនស៊ីវិលឬក៏ជានគរបាល និង កងកំលាំងប្រដាប់អាវុធ ។ ច្បាប់នេះក៏បានចែងផងដែរអំពីការបំផ្លាញឃ្លាំងស្តុកមីន និង ការបង្កើតអាជ្ញាធរជាតិត្រួតពិនិត្យការបោសសំអាតមីនដើម្បីសំរបសំរួលសកម្មភាពនានាដែលទាក់ទងទៅនឹងបញ្ហាមីន ។ រហូតមកទល់គ្នានឹងពេលនេះមិនទាន់មានការកាត់ទោស ឬក៏ដាក់ទណ្ឌកម្មណាមួយស្តីពីការរំលោភច្បាប់លុបបំបាត់មីននៅឡើយទេ ។ ក្រោយពីការចេញផ្សាយរបាយការណ៍ត្រួតពិនិត្យគ្រាប់មីននៅកម្ពុជាឆ្នាំ ២០០០ កន្លងមក មានមន្ត្រីផ្លូវការ CMAC មួយចំនួនបានចុះទៅពិនិត្យសាកសួរប្រជាជនដែលនៅមានគ្រាប់មីនសេសសល់បំរុងលក់ ហើយក៏ពន្យល់អំពីទណ្ឌកម្មដែលត្រូវផ្តន្ទាចំពោះអ្នកដែលពាក់ព័ន្ធក្នុងការរំលោភច្បាប់ជួញដូរគ្រាប់មីនប្រឆាំងមនុស្ស ។ ពេលនោះអ្នកស្រុកក៏ប្រគល់គ្រាប់មីនទាំងនោះជូនមន្ត្រីផ្លូវការអោយធ្វើការកំទេចចោល [6]។

ប្រទេសកម្ពុជាបានចូលរួមក្នុងកិច្ចប្រជុំលើកទី ២ នៃបណ្តារដ្ឋជាសមាជិកសន្ធិសញ្ញានៅទីក្រុងហ្សឺណែវកាលពីខែកញ្ញា ។ គណៈប្រតិភូតំណាងកម្ពុជាឯកឧត្តម អៀង ម៉ូលី បានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលរបស់ឯកឧត្តមមានការព្រួយបារម្ភជាខ្លាំងចំពោះបញ្ហាគ្រាប់មីន : ''យើងកំពុងក្រាយផ្លូវដ៏ត្រឹមត្រូវមួយដោយចំណាយថាមពលដើម្បីកែលំអប្រសិទ្ធិភាព និង គុណភាពនៃការបោសសំអាតមីន ធ្វើយ៉ាងណាអោយជំនួយឧបត្ថម្ភដោយរាជរដ្ឋាភិបាល និង ម្ចាស់អំណោយត្រូវបានប្រើប្រាស់ក្នុងលក្ខណៈដ៏ប្រសើរបំផុត ។ វាជាសោកនាដកម្មសំរាប់

[4] Statement of H.E Ieng Mouly, Chairman of the Cambodian Mine Action Centre, on 16 November 2000, P. P. Cambodia.
[5] Law to Prohibit the Use of Anti Personnel Mines: Cambodia, 28 April 1999.
[6] CMAC report to Land Mine Monitor Meeting, Banteay Meanchey 11 February 2001.

ប្រទេសជាតិ និង ប្រជាជាតិយើង ជាពិសេសប្រជាជនទុគ៌តយើង បើសិនជាសកម្មភាពកំចាត់មីនរបស់យើងមិនអាចបន្តអោយបានដូចពីមុនទៀត [7] '' ។

របាយការណ៍ត្រួតពិនិត្យគ្រាប់មីនត្រូវបានចែកផ្សាយជាសាធារណៈក្នុងប្រទេសកម្ពុជាកាលពីថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ២០០០ ព្រមគ្នានិងការចាប់ផ្តើមនៃយុទ្ធនាការ ''**កុមារប្រឆាំងសង្គ្រាម**'' និង ការផ្ញើររទេះជនពិការដែលផលិតឡើងដោយអ្នកពិការខ្មែរទៅដាក់តាំងនៅសារមន្ទីរ**ណូបែលសន្តិភាព** ក្នុងទីក្រុង Stockholm ។ ក្នុងឱកាសនោះមានអ្នកសារពត៌មានជាច្រើនរូបបានចូលរួម ហើយតំណាងរាជរដ្ឋាភិបាលក៏បានថ្លែងអំណរគុណចំពោះការចែកផ្សាយនៃរបាយការណ៍ត្រួតពិនិត្យគ្រាប់មីននៅកម្ពុជាផងដែរ ។ ស្ថានទូតជាច្រើននៅទីក្រុងភ្នំពេញបានសំណូមពររបាយការណ៍ត្រួតពិនិត្យគ្រាប់មីនបន្ថែមជាច្រើនច្បាប់ទៀត ។

ប្រទេសកម្ពុជាបានបោះឆ្នោតយល់ស្របចំពោះសេចក្តីសំរេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិក្នុងការជំរុញសន្ធិសញ្ញាលុបបំបាត់មីនអោយមានប្រសិទ្ធិភាព ។ ប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសចំនួន៤៧ ដែលបានព្រមព្រៀងអនុវត្តតាមអនុសញ្ញាហាមប្រាមការប្រើប្រាស់អាវុធមួយចំនួន ដែលកែប្រែដោយពង្រាងអនុស្សារណៈទី II ។ ប្រទេសកម្ពុជាបានដាក់ជូនរបាយការណ៍ដែលស្នើសុំដោយមាត្រាទី១៣ នៃពង្រាងអនុស្សារណៈទី II កាលពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០០ ។ របាយការណ៍នោះបានគូសបញ្ជាក់ថា ពត៌មានស្តីពីកាតព្វកិច្ចរបស់កម្ពុជាក្នុងសន្ធិសញ្ញាលុបបំបាត់មីនត្រូវបានចែកចាយដោយកងទ័ព និង អាជ្ញាធរខេត្តក្នុងប្រទេសកម្ពុជា [8] ។

ដូចដែលបានជំរាបពីមុនមកហើយថា របាយការណ៍នៃមាត្រាទី៧ បានត្រូវដាក់ជូនអង្គការសហប្រជាជាតិកាលពីថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០០០ ។

ប្រទេសកម្ពុជាជាសហប្រធាននៃគណៈកម្មការអចិន្ត្រៃយ៍ជំនាញការមួយ ក្នុងចំណោមគណៈកម្មាធិការបង្កើតថ្មីទាំង ៥ ពោលគឺជា គណៈកម្មការអចិន្ត្រៃយ៍សំរាប់សម័យប្រជុំជំនាញការខាងបច្ចេកទេសដោះមីនក្នុងឆ្នាំ២០០០ ។ ក្រៅពីធ្វើគណៈកម្មការអចិន្ត្រៃយ៍ជំនាញការបច្ចេកទេសដោះមីន ប្រទេសកម្ពុជាក៏បានចូលរួមយ៉ាងសកម្មផងដែរក្នុងកិច្ចប្រជុំរបស់គណៈកម្មការអចិន្ត្រៃយ៍ជំនាញការផ្នែកដទៃទៀតផងដែរ រួមមាន ផ្នែកជួយអ្នករងគ្រោះ ផ្នែកបោសសំអាតមីន និង ផ្នែកកំទេចគ្រាប់មីន កាលពីខែឧសភា កញ្ញា និង ធ្នូ ហើយនិងចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការអចិន្ត្រៃយ៍ជំនាញការលើកទី២ ស្តីពីស្ថានភាពទូទៅនៃអនុសញ្ញា កាលពីខែឧសភា ឆ្នាំ២០០០ ថែមទៀត ។

[7] H.E Ieng Mouly, Chairman of the Governing Council of the Cambodian Mine Action Centre, Statement to the Second Meeting of States Parties to the Mine Ban Treaty, Geneva, 12 September 2001.
[8] Som Sotha, Cambodia National Annual Report to CCW, 1 December 2000.

យុទ្ធនាការលុបបំបាត់មីននៅក្នុងប្រទេសកម្ពុជា ដំណើរការយ៉ាងសកម្មតាមតំបន់ និង លើឆាកអន្តរជាតិ ក្នុងបំណងជំរុញអោយបានការអនុវត្តអនុសញ្ញាលុបបំបាត់មីន ។ ទូតយុទ្ធនាការអន្តរជាតិលុបបំបាត់មីន លោក ទន់ ចាន់ណារ៉េត និង អ្នកស្រី សុខ អេង ក្រោមកិច្ចឧបត្ថម្ភរបស់ UNICEF បានចូលរួមក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំប្រទេសតំបន់អាស៊ីប៉ាស៊ីហ្វិកខាងត្បូងចំនួនពីរលើកនៅលើកោះ Fiji ដើម្បីជំរុញអោយមានសកលកម្មនៃសន្ធិសញ្ញាលុបបំបាត់មីន ។ ថ្នាក់ដឹកនាំប្រទេសទាំងឡាយបានយល់ឃើញថា គេបានដឹង ឮអំពីបញ្ហាមីន តែទើបតែពេលដែលគេបានឃើញសភាពពិការដោយសារមីនរបស់លោក ទន់ ចាន់ ណារ៉េត ទើបគេភ្ញាក់ហើយឈានទៅដំណើរការ ។ ជាលទ្ធផល ប្រទេសពីរថ្មីទៀតបច្ចុប្បន្នបានក្លាយទៅជាសមាជិកនៃសន្ធិសញ្ញាលុបបំបាត់មីន ហើយក្រុមយុទ្ធនាការកម្ពុជាក៏បានទូន្មានដល់បណ្តារដ្ឋដទៃទៀតអោយចូលរួមក្នុងសន្ធិសញ្ញាអោយបានកាន់តែច្រើនថែមទៀត ។ ដើម្បីឆ្លើយតបទៅនឹងការប្រមូលប្រទេសអាស៊ានទាំងអស់អោយចូលរួមក្នុងសន្ធិសញ្ញាលុបបំបាត់មីន យុទ្ធនាការបានបោះផ្សាយកូនសៀវភៅពត៌មានស្តីពីមីន និង ផ្ញើលិខិតទៅប្រទេសម៉ាឡេស៊ីសាកសួរពីឃ្លាំងស្តុកមីន និង ផ្ញើទៅប្រទេសឥណ្ឌូនេស៊ីសាកសួរអំពីការផ្តល់សច្ចាប័នលើសន្ធិសញ្ញាលុបបំបាត់មីន ។ នៅប្រទេសថៃ ក្រុមសកម្មភាពមីនថៃ បានប្រើប្រាស់កូនសៀវភៅពត៌មានស្តីពីមីនជាប្រចាំ ដើម្បីបំផុសអោយបានសកលកម្មនៃសន្ធិសញ្ញាលុបបំបាត់មីនក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ។ លោក ទន់ ចាន់ណារ៉េត បានថ្លែងក្នុងឱកាសសិក្ខាសាលាស្តីពីវិស័យអន្តរជាតិនៅសិង្ហបូរី ដើម្បីជំរុញប្រទេសសិង្ហបូរីអោយចូលរួមសន្ធិសញ្ញាលុបបំបាត់មីន ។

យុទ្ធនាការកុមារប្រឆាំងសង្គ្រាម ត្រូវបានបំផុសយ៉ាងខ្លាំងក្លានៅប្រទេសជប៉ុន ប្រទេសស្វីស ប្រទេសបារាំង ប្រទេសកម្ពុជា ប្រទេសប៊ែលហ្ស៊ិក ប្រទេសអូស្ត្រាលី និងប្រទេសថៃ តាមរយៈដំណើរទស្សនកិច្ចរបស់យុវនារី សុង កុសល និង យុវជន ម៉ាន់ សុឃឿម ។ លោកទន់ ចាន់ណារ៉េត បានលើកឡើងអំពីរាត្រីនៃសន្តិភាពនៅទីក្រុង Lourdes កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០០ ហើយបន្ទាប់មកគាត់ក៏បានជំរុញដល់យុវជនទាំងអស់អោយចូលរួមក្នុងយុទ្ធនាការលុបបំបាត់មីន ។ យុទ្ធនាការលុបបំបាត់មីនកម្ពុជាបានផ្ញើលិខិតមួយច្បាប់ ក្នុងឱកាសឆ្នាំព្រះមហាករុណាទិគុណ ជូនដល់យុវជនយុវនារីពីរលាននាក់ដែលបានប្រមូលផ្តុំគ្នានៅទីក្រុងរ៉ូម ដើម្បីជំរុញពួកគេអោយចូលរួមយុទ្ធនាការ ''**កុមារប្រឆាំងនឹងសង្គ្រាម យុវជនចង់បានសន្តិភាព**'' ។

ក្រុមកីឡាបាល់ទះប៉ារ៉ាឡាំពិកកម្ពុជា ដែលមានអ្នកពិការដប់មួយនាក់ចូលរួមផងនោះ បានផ្សព្វផ្សាយសន្ធិសញ្ញាលុបបំបាត់មីននៅប្រទេសអូស្ត្រាលី និង ក្នុងចំនោមក្រុមកីឡាករមកពីប្រទេសនានាដទៃទៀត ។ ប្រព័ន្ធឃោសនាបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ។ ក្រុមទេសចររបាំកម្ពុជាដែលអមដំណើរដោយអ្នករងគ្រោះដោយសារមីនមួយរូបបានធ្វើដំណើរសំដែងរបាំ កាលពីខែវិច្ឆិកា ឆ្នាំ២០០០ នៅប្រទេសអេស្បាញ ហើយបានបញ្ចប់ដោយប្រទេសអេស្បាញបានបំផ្លាញឃ្លាំងស្តុកមីនចុងក្រោយរបស់ពួកគេ ។ ក្រុមរបាំទាំងនោះបានសំដែងរបាំពិសេស អំពី

មីន ដែលធ្លាប់សំដែងជាលើកដំបូងក្នុងឱកាសទិវាយល់ដឹងអំពីមីននៅសាលាបន្ទាយព្រាបកាលពី ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៦ ។

កាលពីខែកុម្ភៈ ឆ្នាំ២០០១ តំណាងរដ្ឋាភិបាលចំនួន ៤៣ ប្រទេសបានអញ្ជើញចូលរួមដោះស្រាយក្នុងឱកាសកិច្ចប្រជុំស្តីពីអនុសញ្ញាហាមប្រាមការប្រើប្រាស់សញ្ញវុធនៅទីក្រុងភ្នំពេញ និង ពិភាក្សាលើគោលនយោបាយរបស់ប្រទេសរៀងៗខ្លួន ។ នារីពិការខ្មែរម្នាក់នឹងធ្វើជាបន្ទាល់សាក្សីនៅឱកាសកិច្ចប្រជុំរបស់តុលាការពិភពលោកនៅប្រទេសអាហ្វ្រិកខាងត្បូងក្នុងខែមិនា ហើយយុវនារីសុង កុសល និង អ្នកពិការទន់ ចាន់ណារ៉េត ក៏នឹងជួបជាមួយអ្នកនយោបាយក្នុងប្រទេសកាណាដា និង ទីក្រុងវ៉ាស៊ីនតោនផងដែរ ។ យុវជន ម៉ាន់ សុឃឿម និង លោក ទន់ ចាន់ណារ៉េត នឹងចូលរួមគាំទ្រដល់កិច្ចប្រឹងប្រែងរបស់យុទ្ធនាការអូស្ត្រាលី ក្នុងការប្រមូលថវិកាជួយបោសសំអាតមីន និង ជួយឧបត្ថម្ភដល់អ្នករងគ្រោះដោយសារមីននៅ ខែមេសា ឆ្នាំ២០០១ ។

កិច្ចអភិវឌ្ឍន៍ដ៏សំខាន់ថ្មីមួយក្នុងសកម្មភាពកំចាត់មីននៅកម្ពុជាគឺការបង្កើតស្ថាប័នជំនាញសកម្មភាពកំចាត់មីនកម្ពុជា ។ ស្ថាប័នជាតិត្រួតពិនិត្យការដោះមីន ដាច់ចេញពីមជ្ឈមណ្ឌលនៃសកម្មភាពកំចាត់មីនកម្ពុជា (CMAC) នៅក្នុងឆ្នាំ២០០០ ហើយមានទីតាំងការិយាល័យនៅផ្ទះលោកប្រធានក្រុមប្រឹក្សាភិបាលរបស់ CMAC ។ តាមពិតការងាររបស់ស្ថាប័នជំនាញនេះមានតិចតួចនៅឡើយ ប៉ុន្តែពួកគេមើលការខុសត្រូវការបំផ្លាញឃ្លាំងស្តុកមីនក្នុងតំបន់ការងាររបស់នគរបាលដូចមានក្នុងរបាយការណ៍ត្រួតពិនិត្យគ្រាប់មីននៅកម្ពុជាឆ្នាំ២០០០ ។

ទោះជាយ៉ាងណាក្តី អាជ្ញាធរសកម្មភាពមីនកម្ពុជា គឺជាស្ថាប័នថ្មីមួយដែលចាប់កំនើតឡើងតាមរយៈកិច្ចប្រជុំពិភាក្សាឆ្នាំ២០០០ ដែលសំរេចអោយមានស្ថាប័នថ្មីនេះដឹកនាំដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ការបង្កើតស្ថាប័នមួយថ្មីនេះ គឺ យោលទៅតាមតំរូវការក្នុងការឆ្លើយតបទៅនឹងបញ្ហារបស់ម្ចាស់ជំនួយ ប៉ុន្តែសំខាន់ជាងនេះនោះ គឺការញែកមុខងារស្ថាប័នជំនាញត្រួតពិនិត្យគ្រប់សកម្មភាពមីននៅកម្ពុជា ចេញដាច់ពីស្ថាប័នរដ្ឋាភិបាលដែលអនុវត្តការបោសសំអាតមីន ។ មុខងារ CMAC បច្ចុប្បន្ននេះគឺ ជាអង្គភាពដោះមីនដែលពាក់ព័ន្ធទៅនឹងសកម្មភាពបំផុសការយល់ដឹងពីមីន និង សកម្មភាពបោសសំអាតមីន ។

ស្ថាប័នអាជ្ញាធរសកម្មភាពមីនកម្ពុជាត្រូវបានបង្កើតឡើងតាមច្បាប់ ដើម្បីសំរបសំរួលការងារសកម្មភាពមីននៅកម្ពុជា ។ អនុក្រឹត្យស្តីពីការបង្កើតស្ថាប័ន និង មុខងារនៃស្ថាប័នជំនាញត្រួតពិនិត្យសកម្មភាពមីន និង ការឧបត្ថម្ភដល់ជនរងគ្រោះនេះនឹងមានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធនៅចុងរបាយការណ៍នេះ ។ ការកែប្រែជាចាំបាច់ទាំងឡាយនៃក្រឹត្យដែលតែងតាំង CMAC ពីមុនជាស្ថាប័នត្រួតពិនិត្យគ្រាប់មីននោះ បច្ចុប្បន្នត្រូវស្ថាប័ន CMAA ដើរតួវិញម្តង ។ ស្ថាប័ន CMAA ត្រូវធ្វើការពិភាក្សាជាពិស្តារក្រោមការសំរបសំរួលរួមគ្នា ។

**ការផលិតមីន** (Production)

គ្មានការផលិតមីនណាមួយដែលត្រូវបានគេរកឃើញនៅក្នុងឆ្នាំ ២០០០-២០០១ នេះទេ ។

**ការដឹកជញ្ជូនគ្រាប់មីន (Transfer)**

គ្មានការដឹកជញ្ជូនគ្រាប់មីនណាមួយត្រូវបានគេរកឃើញឡើយ ទោះបីជាមានការនិយាយពីទីផ្សាររឹងរូស ដែលដឹកជញ្ជូនអាវុធខុសច្បាប់ដោយបុគ្គលនៅតាមព្រំដែនយ៉ាងណាក្តី ។

**ការបំផ្លាញឃ្លាំងស្តុកមីន (Destruction of Stockpiles)**

សិទ្ធិសញ្ញាលុបបំបាត់មីនអុតតាវ៉ាទាមទារអោយប្រទេសហត្ថលេខីទាំងអស់លុបបំបាត់ឃ្លាំងស្តុកមីនឱ្យអស់ ក្រុមប្រតិបត្តិការបោសសំអាតមីន និង ប្រជាជនជួនកាលជួបប្រទះនឹងឃ្លាំងស្តុកមីន ដែលលាក់ទុកក្នុងភូមិតាំងពីសម័យសង្គ្រាមបន្សល់ទុក ។ ការបំផ្លាញឃ្លាំងស្តុកមីនត្រូវបានអ្នកដោះមីនចាត់ទុកជាកិច្ចការបោសសំអាតអាវុធជាតិផ្ទុះតែម្តងដែលប្រសើរជាងការដោះមីន ។

ក្នុងឱកាសកិច្ចប្រជុំត្រួតពិនិត្យគ្រាប់មីន កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០០ នៅខេត្តបាត់ដំបង គេបានរាយការណ៍ថាតំបន់កាន់កាប់ដោយកងទ័ពនៅមានស្តុកទុកគ្រាប់មីននៅឡើយ ។ ឃ្លាំងស្តុកមីនមួយនៅចំងាយ ១៣ គ.ម ពីខេត្តបាត់ដំបងតាមបណ្តោយផ្លូវជាតិលេខ ១០ ។ ក្នុងកំឡុងរៀបចំបញ្ជីសារពើភ័ណ្ឌ គ្រាប់មីនដែលខូចគុណភាពត្រូវបានគេកំទេចចោល ប៉ុន្តែគ្រាប់មីនដែលមានគុណភាពល្អត្រូវគេរក្សាទុកតទៅទៀត ។ កិច្ចខំប្រឹងប្រែងក្នុងការរៀបចំគ្រាប់មីនក្នុងឃ្លាំងទូទាំងប្រទេសកំពុងដំណើរការដោយកងយោពលខេមរភូមិន្ទ និង ស្ថាប័ន CMAA [9] ។

យុទ្ធនាការលុបបំបាត់មីនកម្ពុជា បានធ្វើការអំពាវនាវ ក្នុងអត្ថបទចុះផ្សាយរបស់សារព័ត៌មាន ក្នុងឱកាសខួបសន្និសញ្ញាអុតតាវ៉ាកាលពីខែធ្នូ ឆ្នាំ២០០០ សុំអោយបំផ្លាញឃ្លាំងស្តុកមីនទាំងអស់នេះ [10] ។

មានគ្រាប់មីន និង គ្រាប់មិនទាន់ផ្ទុះច្រើនប្រភេទដែលគ្មានជាតិផ្ទុះនៅសេសសល់ត្រូវបានគេកាន់កាប់នៅតាមការិយាល័យ NGO តាមការដាក់តាំងពិពរណ៍ជាសាធារណៈតាមមជ្ឈមណ្ឌលហ្វឹកហាត់ដោះមីន និង ប្រើប្រាស់ដោយក្រុមបំផុសការយល់ដឹងពីគ្រាប់មីន និង គ្រាប់មិនទាន់ផ្ទុះ ។ ទាំងនេះសុទ្ធសឹងជាប្រពៃណីក្នុងបំណងត្រឹមត្រូវដូចជាការដាក់តាំងជាសាធារណៈ ការអប់រំបង្ហាញ និង គោលដៅបង្រៀនផ្សេងៗ ។ វាគ្មានកម្មវិធីទ្រទ្រង់ណាមួយដែលកំនត់គ្រាប់មីន និង គ្រាប់មិនទាន់ផ្ទុះដែលអស់ជាតិផ្ទុះ និង ធានាអោយបានឯកសារកត់ត្រាជាផ្លូវការនូវប្រភេទគ្រាប់មីនទាំងនេះទេ ។ ហេតុនេះហើយការប្រថុយប្រថានអាចកើតមានឡើង នៅពេលគេប្រើប្រាស់ប្រភេទគ្រាប់ដែលហាមឃាត់ និង អាចបណ្តាលអោយមានគ្រោះថ្នាក់ដោយមិនបានគិតពិចារណា ។ ស្ថានភាពបែបនេះនឹងកាន់តែធ្ងន់ធ្ងរខ្លាំងឡើងទៅតាមកំនើននៃតំរូវការរបស់ក្រុមដោះមីននានា ដែលចង់ប្រើប្រាស់គ្រាប់មីនមិនទាន់អស់អាយុ យោលតាមការយល់ឃើញពីការចាត់ចែងឃ្លាំងស្តុកមីន ពោលគឺសុវត្ថិភាពនៃគ្រាប់មីនមិនបានទាំងស្រុងទេ ។ ការខ្វះប្រព័ន្ធត្រួតពិនិត្យសមរម្យត្រូវបានកត់ត្រាក្នុងអត្ថបទរបស់លោក Ian Bullpit [11] ។

---

[9] Report to Land Mine Monitor meeting Battambang November 30, 2000, Cambodia.
[10] CCBL press release, 2 December, 2000,Phnom Penh, Cambodia.
[11] Bullpitt Ian: "Summary of Discussions and Recommendations Relating To National Strategy and Management Of The Mine Action Sector Within Cambodia In The Short and Long Term Beyond 2000," Phnom Penh 5 November 2000 p.44.

ទន្ទឹមនឹងនោះដែរ នៅមិនទាន់មានពត៌មានស្តីពីទំហំនៃឃ្លាំងស្តុកគ្រាប់រំសេវ/គ្រាប់មានជាតិផ្ទុះ ការដឹកជញ្ជូននិងការប្រើប្រាស់នៅឡើយ ។ លើសពីនេះមិនថា CMAC ឬក្រុមប្រតិបត្តិការផ្សេងទៀតនោះមិនទាន់មានឯកទេសគ្រប់គ្រាន់ក្នុងការប្រើប្រាស់គ្រាប់រំសេវ ឬ គ្រាប់មានជាតិផ្ទុះនៅឡើយ ។ ទីប្រឹក្សាបច្ចេកទេសអាវុធជាតិផ្ទុះបរទេសដែលធ្វើការនៅប្រទេសកម្ពុជាត្រូវបានគេស្នើសុំអោយផ្តល់ការណែនាំពិសេសសំរាប់វិស័យនេះ។យោលទៅលើបទពិសោធន៍ក្នុងការងារវាសមល្មមដែរ តែទោះជាយ៉ាងណាក៏ដោយ ក៏ការប្រថុយប្រថានជាក់ស្តែងនៅតែអាចកើតមានចំពោះគ្រោះថ្នាក់ដោយចៃដន្យដែលបណ្តាលមកពីឃ្លាំងស្តុកគ្រាប់រំសេវ ឬការប្រើប្រាស់វានៅក្នុងវិស័យសកម្មភាពមីនតទៅមុខ [12] ។

**ការប្រើប្រាស់** **(Use)**

គ្មានពត៌មានជាផ្លូវការស្តីពីការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស ឬគ្រាប់មីនប្រឆាំងរថក្រោះឡើយ ។ តែទោះជាយ៉ាងនេះក្តី នៅភូមិចំណោមក្នុងខេត្តបន្ទាយមានជ័យ បុរសម្នាក់ទទួលគ្រោះថ្នាក់កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០១ ដោយសារគ្រាប់មីនដែលបង្កប់ដោយអ្នកភូមិដែលស្រាស់របងការពារឡូត៍នៃសាទរបស់ខ្លួន[13] ។

**ពួកឧទ្ទាម** **(Non State Actor)**

ពួកឧទ្ទាមគឺជាពួកបះបោរ ឬទាហានទ័ពព្រៃ ។ គេគ្មានគោលនយោបាយស្តីពីការប្រើប្រាស់គ្រាប់មីនទេ ។ គ្មានពត៌មានស្តីពីការប្រើប្រាស់មីនរបស់ពួកគេទេ ។ រូបភាពអាវុធចាក់ផ្សាយតាមទូរទស្សន៍ ដោយក្រុមគ្មានរូបរាងដែលហៅខ្លួនឯងថាជាអ្នកប្រយុទ្ធដើម្បីសន្តិភាពនៅកម្ពុជា ក៏ហាក់ដូចជាមិនបានរាប់បញ្ចូលគ្រាប់មីនក្នុងនោះផងទេ ។

**ការផ្តល់មូលនិធិសំរាប់សកម្មភាពមីន** **( Mine Action Funding )**

មូលនិធិដែលអង្គការបោសសំអាតមីនបានទទួលចាប់ពី ខែមករា ដល់ ខែធ្នូ ឆ្នាំ ២០០០:

| អង្គការ | មូលនិធិដែលបានទទួល |
|---|---|
| CMAC | $ ៧,៦១២,០៨៤ |
| MAG | $ ៤,០០០,០០០ (ប្រមាណជា) |
| HALO Trust | $ ៤,០០០,០០០ (ប្រមាណជា) |
| RCAF | ប្រហែលជាថវិកាការពារជាតិ និង ថវិកាហេដ្ឋារចនាសម្ព័ន្ធ |

**ការវិត្តន៍នៃមូលនិធិ**

[12] Bullpitt Ian. p.45
[13] Report to Land Mine Monitor 20 February, 2001 by Enrique Figaredo, Battambang, Cambodia.

អង្គការ MAG និង អង្គការ HALO Trust បានរាយកាណ៍ថាបានទទួលមូលនិធិដូចគ្នានិងឆ្នាំ ១៩៩៩ ។ អង្គការ CMAC ទទួលបានមូលនិធិចំនួន ១លានដុល្លារ តិចជាងពីឆ្នាំ ១៩៩៩ ។

មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC)

មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា បានផ្តល់នូវរបាយការណ៍ហិរញ្ញវត្ថុដំបូងសំរាប់ឆ្នាំ ២000 របស់ខ្លួនដល់ក្រុមត្រួតពិនិត្យមីន កាលពីថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២00១ ។ ទឹកប្រាក់ថ្មីដែល CMAC បានទទួលក្នុងឆ្នាំ២000 សរុប $ ៧,៦១២,0៤៣ US ។ នៅក្នុងឆ្នាំ២000 អង្គការ UNDP Trust Fund បានផ្តល់ទឹកប្រាក់ $ ៧,៣៤៥,៣១១ US ហើយសប្បុរសជនដទៃទៀតបានប្រគល់ផ្ទាល់ដល់អង្គការ CMAC នូវទឹកប្រាក់ចំនួន $ ២៦៦,៧៣២ US ។ ការចំណាយរបស់អង្គការ CMAC ក្នុងឆ្នាំ២000 សរុបមាន $៧,៥២0,0១១.៨៨ US ។

ការចាត់ចែងចំណាយរបស់ CMAC [14]

ប្រាក់ចំណូល

| | |
|---|---|
| ថវិកាបន្តពីឆ្នាំ 1999 | $ ១,២៧៤,៧៥៣.៩១ US |
| មូលនិធិទទួលបានពីសប្បុរសជននានា | $ ៧,៦១២,0៤៣.៩៦ US |
| ការប្រាក់ទទួលបាន | $ ២២,៦៥១.៤៦ US |
| ការផ្ទេរប្រាក់ | $ 0.00 US |
| **សរុបប្រាក់ចំណូល** | **$ ៨,៩0៩,៤៤៩.៣៣ US** |

ការចំណាយ

| | |
|---|---|
| បៀវត្សរ៍ | $ ៤,៧៨៩,៧៧២.0៤ US |
| អាគារស្នាក់នៅ | $ ១៦៤,៨៨៣.១៩ US |
| សំភារៈមានតំលៃប្រើបានយូរ | $ ៦៨,៥៩0.៧៧ US |
| សំភារៈប្រើរួចហើយបោះបង់ចោល | $ ៦៤0,៥៩២.៦៩ US |
| ការថែទាំបរិក្ខារ | $ ៦៤៧,៤៧៩.៦៨ US |
| ការដឹកជញ្ជូន | $ ៧៩៤,៣២៨.៩២ US |
| ការផ្គត់ផ្គង់ | $ ២៨១,៩៦៥.៦៩ US |
| រដ្ឋបាល | $ ១៣២,៣៩៨.៩0 US |
| **សរុបប្រាក់ចំណាយ** | **$ ៧,៥២0,0១១.៨៨ US** |

[14] Khem Sophoan, CMAC General Director , Financial Report, 19 February 2001, Phnom Penh, Cambodia.

ទោះបីជាអង្គការ CMAC មានបញ្ហាផ្នែកហិរញ្ញវត្ថុក្នុងពេលថ្មីៗនេះក្តី ក៏នៅមានក្រុមប្រតិបត្តិការ និង សប្បុរសជនដទៃទៀតជួយឧបត្ថម្ភយ៉ាងទូលំទូលាយ សំរាប់បំពេញតំរូវការរបស់ស្ថាប័នជាតិបោសសំអាតមីនមួយនេះ ក្នុងពេលបច្ចុប្បន្ន និង ទៅអនាគត ។ ហើយក៏នៅតែមានកិច្ចគាំទ្រដ៏ខ្លាំងក្លាក្នុងការរក្សាទុកអង្គការ CMAC ជាអង្គភាពរដ្ឋាភិបាលជាជាងប្តូរផ្លាស់អង្គភាពនេះអោយទៅជាអង្គការក្រៅរដ្ឋាភិបាលកម្ពុជា ។ ទោះជាយុទ្ធសាស្រ្តរយៈពេលពីខ្លីទៅមធ្យមអ្វីក៏ដោយក៏ CMAC នឹងនៅតែជាសេវាកម្មរបស់រាជរដ្ឋាភិបាលចំបងទទួលបន្ទុកបោសសំអាតមីនក្នុងពេលដ៏ខ្លីខាងមុខ[15] ។

ភាពអសមត្ថភាពបច្ចុប្បន្នរបស់រាជរដ្ឋាភិបាលកម្ពុជាផ្នែកហិរញ្ញវត្ថុសំរាប់ទ្រទ្រង់អង្គការ CMAC ដែលជាស្ថាប័នជាតិមានសមត្ថភាពដោះមីនតទៅអនាគតនោះ សរអោយឃើញថាអង្គការនេះត្រូវពឹងផ្អែកយ៉ាងខ្លាំងទៅលើជំនួយមូលនិធិពីបរទេស ។ អង្គការ CMAC មិនមែនតំណាងត្រឹមតែជាអង្គការដោះមីនមួយមុខប៉ុណ្ណោះទេ វាតំណាងសមត្ថភាពដោះមីនរយៈពេលវែងដែលយើងត្រូវការ ដើម្បីអនុវត្តដោះមីនបន្តក្រោយពេលអង្គការក្រៅរដ្ឋាភិបាលទាំងឡាយចាកចេញទៅ ។

ប្រាក់ចំណូល/ចំណាយសរុបដែលអង្គការ CMAC បានទទួលក្នុងកំឡុងពីខែធ្នូ ឆ្នាំ១៩៩៣ ដល់ ខែធ្នូ ឆ្នាំ២000 :




2000 p.32.




## ជំនួយជាក់លាក់ដែលរដ្ឋាភិបាលនានាបានរាយការណ៍ជូនក្រុមពិនិត្យគ្រាប់មីន

រដ្ឋាភិបាលរបស់ប្រទេសអាល្លឺម៉ង់បានផ្តល់មូលនិធិផ្ទាល់សំរាប់ប្រតិបត្តិការនៃអង្គភាពបោសសំអាតមីនប្រាំមួយកងរបស់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ។ អង្គភាពទាំងនោះមានទីតាំងនៅខេត្តសៀមរាប និង ឧត្តរមានជ័យ ។ វិភាគទានជាថវិកាមានទឹកប្រាក់ប្រហែល $ ៧00,000 US រឺ DM១,៥00,000[16] ។

កិច្ចប្រតិបត្តិការបោសសំអាតមីនលើកទី ២ បានទទួលថវិកាឧបត្ថម្ភសំរាប់បោសសំអាតមីននៅខេត្តបាត់ដំបង ។ គំរោងការនេះ ដោយដាក់រាយប្រតិបត្តិការ និង ការឧបត្ថម្ភនូវគ្រឿងចក្របោសសំអាតមីន ‘‘Rhino’’ បានចាប់ផ្តើមរួចមកហើយកាលពីឆ្នាំ ១៩៩៩ ។ វិភាគទានជាថវិកាសំរាប់គំរោងការរយៈពេលពីថ្ងៃទី ១ ខែមករា ដល់ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២000 គិតជាទឹកប្រាក់មាន $ ១១២,000 US ។ ចំនួនទឹកប្រាក់នេះគិតត្រឹមតែការចំណាយរបស់អង្គការ CMAC ផ្ទាល់តែប៉ុណ្ណោះ ពោលគឺមិនបានរាប់បញ្ចូលនូវការចំណាយខាងផ្នែកនាំចូល ផ្នែកថែទាំ ផ្នែកផ្គត់ផ្គង់បច្ចេកទេស រួមនិង ផ្នែកនាំចេញឧបករណ៍ទេ ។

អង្គការ CARE បានទទួលវិភាគទានផ្នែកហិរញ្ញវត្ថុក្នុងប្រតិបត្តិការនៃគ្រឿងចក្រ Rhino ចំនួនទឹកប្រាក់ $២៥0,000 US រឺក៏ DM ៥00,000 ពីរដ្ឋាភិបាលប្រទេសអាល្លឺម៉ង់ ។ វិភាគទានមួយផ្នែកទៀតមានទឹកប្រាក់ $២0.000 US សំរាប់ចំណាយរបស់អង្គភាព CMAC ជាមួយកម្មវិធីគ្រឿងចក្រ ‘‘Rhino’’ ត្រូវបានប្រគល់

[16] Stmadl, Robert, Germany Embassy , response to LM Monitor, 24 January 2001, Phnom Penh, Cambodia.

កាលពីខែមេសា ឆ្នាំ២000 ។ រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់បានចុះខសន្យាផ្តល់គ្រឿងចក្រសំរាប់កំទេចមីនដែលដោះបាន និង កំទេចគ្រាប់មិនទាន់ផ្ទុះរួមនឹងគ្រឿងបន្លាស់ផ្នែកបរិក្ខារបោសសំអាតមីនផ្សេងទៀត។

ក្នុងឆ្នាំ ២000 ប្រទេសស៊ុយអែដ (Sweden) បានផ្តល់វិភាគទានជាទឹកប្រាក់សំរាប់មូលនិធិ UNDP Trust Fund CMAC (ការបោសសំអាតមីនដែលគ្មានផ្លាកសំគាល់ និង ការទ្រទ្រង់ស្ថាប័នទូទៅ ) ទឹកប្រាក់ចំនួន $ ១,៧២៩,៧៣0 US ( 16.0 million Swedish Kronor ) ហើយនិងទឹកប្រាក់ចំនួន $ ១,៩៥៦,៧៩៧ US សំរាប់កម្មវិធីឆ្កែរុករកមីនផងដែរ ( កសាងសមត្ថភាពនិងប្រើប្រាស់ឆ្កែដើម្បីធ្វើការរុករកមីន និង កាត់បន្ថយតំបន់ពាក់ព័ន្ធនឹងមីន)[17] ។

នៅឆ្នាំ២000 (រដ្ឋាភិបាលសហព័ន្ធប៊ែលហ្ស៊ិក) ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ ប៊ែលហ្ស៊ិកបានផ្តល់វិភាគទានដល់អង្គការ CMAC ចំនួន $ ៤៩៧,៧៩0 US តាមរយៈកម្មវិធី UNDP Trust Fund និងទីប្រឹក្សាយោធាបីរូបសំរាប់សាខាទទួលបន្ទុកកំទេចគ្រឿងផ្ទុះរបស់អង្គការ CMAC[18] ។

កម្មវិធីមនុស្សធម៌របស់រដ្ឋាភិបាលប្រទេសអង់គ្លេសផ្នែកសកម្មភាពមីន (British) ត្រូវបានទទួលការផ្គត់-ផ្គង់ជាថវិកា និង គ្រប់គ្រងដោយនាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ ។ នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិបានផ្តល់ការគាំទ្រសំរាប់កម្មវិធីមនុស្សធម៌ផ្នែកសកម្មភាពកំចាត់មីននៅប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៤ មកម្ល៉េះ ។ ហិរញ្ញវត្ថុប្រចាំឆ្នាំ ពីខែមេសាឆ្នាំ២000 ដល់ ខែមីនា ឆ្នាំ២00១ ទឹកប្រាក់ដែលបានផ្តល់មានចំនួន ២,១៣៦ លានផោន ។ ទឹកប្រាក់នេះ ត្រូវបានគេរំពឹងទុកថានឹងត្រូវចំណាយទាំងអស់ ។ ជាទូទៅកម្មវិធីទាំងនេះបានបញ្ចូលសកម្មភាពស្ទង់រកកន្លែងមីន សកម្មភាពដោះមីន និង សកម្មភាពបំផុសការយល់ដឹងពីមីន ។ បន្ថែមពីលើនេះ នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ ក៏កំពុងផ្គត់ផ្គង់បរិក្ខារសំរាប់សាកល្បងនៅនឹងកន្លែង និង ការកសាងសមត្ថភាពផងដែរ[19] ។

សាធារណរដ្ឋកូរ៉េ បានផ្តល់ថវិកាដល់មូលនិធិ UN Volontary Trust Fund ចំនួន $៨0,000 US ក្នុងឆ្នាំ២000 សំរាប់សកម្មភាពដោះមីននៅក្នុងប្រទេសកម្ពុជា [20] ។

ប្រទេសន័រវែស្ស បានផ្តល់វិភាគទានជាទឹកប្រាក់ចំនួន ២,៥ លានក្រូណឺ (Kronas) ដល់អង្គការ UNDP Trust Fund សំរាប់ឧបត្ថម្ភអង្គការ CMAC ។ ប្រទេសន័រវែស្សក៏បានផ្តល់វិភាគទានចំនួន ៥,២ ក្រូណឺ តាមរយៈអង្គការ NPA សំរាប់ការបោសសំអាតមីន និង កិច្ចអភិវឌ្ឍន៍សហគមន៍ដែលរងគ្រោះដោយសារមីនផងដែរ ។ វិភាគទានបំផុសការយល់ដឹងអំពីមីន ៨៣៥.000 ក្រូណឺ សំរាប់ TRAUMACARE/WHO និង វិភាគទាន

[17] Daniel Asplund, Counsellor of Sweden, response to LM Monitor, 25 January 2001, Phnom Penh, Cambodia.
[18] Jacques Luyssaert, Belgium Embassy , response to Land Mine Monitor, 7 February 2001, Phnom Penh, Cambodia.
[19] Khieu Chakrya,Aid Assistant of British Embassy, response to Land Mine Monitor, 8 February2001,Cambodia.
[20] Oh Byung-Seang, Counsellor of the Republic of Korea, 20 February 2001, Phnom Penh, Cambodia.

ជួយអ្នករងគ្រោះដោយសារមីនចំនួន ១.១ លានក្រូណើ សំរាប់ស្តារលទ្ធភាពពលកម្មអ្នករងគ្រោះដោយសារសង្គ្រាម តាមរយៈ ICRC[21] ។

ប្រទេសអូស្ត្រាលីតាមរយៈ AusAID បានផ្តល់មូលនិធិជួយសកម្មភាពកំចាត់មីនក្នុងប្រទេសកម្ពុជាចំនួន ២.៥លានដុល្លាអូស្ត្រាលី (ប្រហាក់ប្រហែល ១.៤ លានដុល្លាអាមេរិក) ក្នុងហិរញ្ញវត្ថុប្រចាំឆ្នាំ ២០០០/២០០១ (ពីខែកក្កដា ឆ្នាំ២០០០ដល់ ខែមិថុនា ឆ្នាំ២០០១) ។ វិភាគទាននេះផ្តល់ជូនអង្គការមូលនិធិ UNDP CMAC Trust Fund សំរាប់ប្រតិបត្តិការបោសសំអាតមីនរបស់អង្គការ CMAC[22] ។

ប្រទេសជប៉ុនបានផ្តល់វិភាគទានដល់ UNDP Trust Fund សំរាប់ការងារ CMAC ពីខែមេសា២០០០ ដល់ ខែមីនា ២០០១ ចំនួន $ ៩០,000 US ។ ជប៉ុនក៏បានគាំទ្រសកម្មភាព CMAC តាមរយៈការឧបត្ថម្ភទ្វេភាគី ដូចជាផ្តល់អំណោយជាបរិក្ខារ និង បញ្ជូនអ្នកឯកទេសនៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនមកជួយ[23] ។

ជប៉ុនបានផ្តល់មូលនិធិដល់អង្គការ VVAF សំរាប់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មនៅខេត្តក្រចេះចំនួនទឹកប្រាក់ $ ៦៦,៧៥០ US និង ផ្តល់ដល់អង្គការ AAR ចំនួន $ ៨៣,៣០០ US សំរាប់កែលំអមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈកៀនឃ្លាំងផងដែរ ។ ជប៉ុនបានផ្តល់មូលនិធិដល់អង្គការ HALO Trust សំរាប់ម៉ាស៊ីនស្ទូច និង តំឡើងរថយន្តធុនធ្ងន់ចំនួនទឹកប្រាក់ $ ៣២.០០០ US ។ ប្រទេសជប៉ុនបានបន្ថែមជំនួយដល់រាជរដ្ឋាភិបាលកម្ពុជាចំនួន $ ៣.០០០.០០០ US សំរាប់ការកែលំអបរិក្ខារប្រើប្រាស់ក្នុងសកម្មភាពបោសសំអាតមីនកាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០០ ។ វិភាគទាននេះតមកពីដំណាក់កាលទី២នៃជំនួយសំរាប់គ្រឿងបរិក្ខារដែលគិតជាទឹកប្រាក់ចំនួន $ 4.៣៧0.000 US ផ្តល់កាលពីថ្ងៃទី២ ខែមេសា ឆ្នាំ២០០០[24] ។

សហរដ្ឋអាមេរិក និង ជប៉ុនជាប្រទេសមួយក្នុងចំណោមប្រទេសផ្តល់វិភាគទានឯទៀតទាំងផ្នែកថវិកា និង សេវា ។

UNICEF បានផ្តល់ប្រាក់ $៩០.000US សំរាប់ក្រុមបំផុសការយល់ដឹងពីមីន និង ក្រុមបោះផ្លាកសញ្ញាមីន។

ZOA បានផ្តល់ទឹកប្រាក់ $ ១0000 US ។

UNHCR បានផ្តល់មូលនិធិសំរាប់កម្មវិធីនៅស្រុកសំឡូត និង តំបន់ជនមាតុភូមិនិវត្តន៍ដទៃទៀត ។

តួលេខពត៏មានលំអិតដែលផ្តល់ដោយប្រទេសម្ចាស់ជំនួយសំរាប់មូលនិធិ UNDP Trust Fund ឆ្នាំ២០០០ នៅមិនទាន់មាននៅឡើយ ។

---

[21] Ragne Birte Lund, Ambassador of Norway, response to Land Mine Monitor, 1 March 2001, P.P, Cambodia.
[22] Khun Eak, Program Officer of AusAID, 15 February 2001, Phnom Penh Cambodia.
[23] Horiuchi Toshihiko, First Secretary of Japanese Embassy , 12 March 2001, Phnom Penh, Cambodia.
[24] Horiuchi Toshihiko, First Secretary of Japanese Embassy , 12 March 2001, Phnom Penh, Cambodia.

ក្នុងឆ្នាំ២០០១ CMAC រំពឹងថានឹងបានទទួលទឹកប្រាក់ចំនួន $ ២,២លាន US ពីមូលនិធិ UNDP General Trust Fund និង ទឹកប្រាក់ $ ២,៣ លាន US ពីមូលនិធិ Earmark Trust Fund និង $ ២.៨ លានUS ពីមូលនិធិទ្វេភាគី (Bilateral fund)សរុបប្រហែល $ ៧.៣ លាន US ។ ជំនួយទ្វេភាគីពីអង្គការដទៃរួមមាន :

អង្គការ CARE ពីរកងអនុសេនាតូចដោះមីនសំរាប់រយៈពេល ២ រឺ ៣ឆ្នាំ ។

អង្គការ NPA បីកងអនុសេនាតូចដោះមីនសំរាប់រយៈពេល 1 ឆ្នាំ ។

អង្គការ UNICEF ក្រុមបំផុសការយល់ដឹងពីមីន / ក្រុមដើរដាក់សញ្ញាសំគាល់មីនតាមសហគមន៍ ។

គេសង្ឃឹមថា សហគមន៍អឺរ៉ុប និង សំរេចផ្តល់មូលនិធិជួយអង្គការ CMAC ជាមិនខាន ។

## <u>អង្គការ</u> HALO TRUST[25]

អង្គការ HALO Trust បានចំណាយ $ ២.៥លានUS សំរាប់ប្រទេសកម្ពុជាក្នុងឆ្នាំ២០០១ ពោលគឺជាទឹកប្រាក់មួយផ្នែកនៃថវិកាសរុបប្រមាណជា $ ៤ លានUS ។ ម្ចាស់អំណោយរួមមាន DFID សហរដ្ឋអាមេរិក រដ្ឋាភិបាលប្រទេសហ្វាំងឡង់ កងទ័ពសហព័ន្ធប្រជាធិបតេយ្យអៀរឡង់ Rotary International Japan រដ្ឋាភិបាលប្រទេសណេដឺលែន ហើយនឹងអង្គការ UNHCR សំរាប់តំបន់ជនមាតុភូមិនិវត្តន៍នៅសំរោង ។ មូល-និធិបន្ថែមសំរាប់កម្មវិធីទំនេរមួយផ្នែកខាងផ្គត់ផ្គង់បរិក្ខារបានមកពី កម្មវិធីជំនួយខ្នាតតូចរបស់ប្រទេសជប៉ុន-ស្ថានទូតសហរដ្ឋអាមេរិក និង មូលនិធិម្ចាស់ក្សត្រីដាយអាណា ។ HALO Trust ផ្តល់តួរលេខពត៌មានលំអិតអំពីតំបន់ដែលបានដោះមីន និង ទទួលការឧបត្ថម្ភការចំណាយដោយម្ចាស់អំណោយជាក់លាក់ ។

សរុបលទ្ធផលការងារបានពីម្ចាស់ជំនួយពីខែមករា ឆ្នាំ២០០០ រហូតដល់ខែធ្នូ ឆ្នាំ២០០០

| ម្ចាស់ជំនួយ | ដីដោះមីនរួច | ដីកាត់ដោយត្រាក់ទ័រ | គ្រាប់មីនប្រឆាំងមនុស្ស | គ្រាប់មីនប្រឆាំងរថក្រោះ | គ្រាប់មិនទាន់ផ្ទុះ |
|---|---|---|---|---|---|
| Aust Care | ១០០,៤៩៤ | ១២,៨០០ | ១១០ | 0 | ៨៣ |
| DAM | ៧៨,៤៩២ | ២០,៣៧០ | ១១៧ | 0 | ៧២ |
| DFID | ៩០៣,៧៩៧ | ៣៧០,២៧៣ | ១,២៥០ | ៨ | ១,២៥៧ |
| FINN | ៧២៩,០០៦ | ២៥៨,៧០៥ | ៥៣៣ | 0 | ៣០៤ |
| IRISH | ១៧៩,០៤០ | ៧២,៩២៣ | ២៣៤ | ១ | ៩៣ |
| Rotary Int. | ២១១,៥៣១ | ១៣,៦១៩ | ៤៨ | 0 | ៩៦ |
| UNHCR | ២៥៨,៤៦២ | ៤៩,៩៧៣ | ១៣២ | 0 | ២១៣ |
| USA | ៣៩១,៨៩៦ | ៨៥,៣១៨ | ១៨៥ | ១ | ១៨៦ |
| USA 3 | ១០,៦៣៣ | 0 | 0 | 0 | ២ |
| USA 4a | ៥២,៦៤៩ | ៣៧,៥២៥ | ១៩ | 0 | ១៤ |
| USA 4b | ៣៨,៩១៦ | ១,៨៣៩ | ៥ | 0 | ៥៥ |
| USA 4b | ៤៥,៥៣៧ | ១៨,៨០០ | ៣១ | 0 | ៥១ |
| **សរុប** | **៣,០០០,៨៥៣** | **៨៩២,១៤៥** | **២,៦៦៤** | **១០** | **២,៤២៦** |

[25] David McMahom: Deputy director of Halo Trust to Land Mine Monitor (Denise Coghlan) on 22 Feb., 2001.

វិភាគទានរបស់ម្ចាស់ជំនួយនៃ UNDP Trust Fund សំរាប់គាំទ្រការបោសសំអាតមីន [26]:

| ម្ចាស់អំណោយ | ទឹកប្រាក់ដែលបានទទួលសរុប |
|---|---|
| Adopt A Minefield | ៥១១,៤៣៧ |
| Australia | ២,២៧៥,៩៥៩ |
| Belgium | ៤៥៧,៧៩០ |
| Cambodia | ៧០៥,១២០ |
| Finland** | ៩៨២,៩៧១ |
| Japan | ៩០០,០០០ |
| New Zealand** | ៦៦,០៣៧ |
| Norway | ២៧៦,១៥៦ |
| Sweden | ១,៤៧៩,៦២១ |
| United Kingdom | ៣១៥,១២៥ |
| USA | ៩៣៧,៨៤៧ |
| សរុបវិភាគទានទទួលបានក្នុងឆ្នាំ ២០០០ | ៩,១៧៨,០៦៣ |

* សំខាន់សំរាប់ជំនួយទីប្រឹក្សាបច្ចេកទេស ។

<u>អង្គការ</u> (MAG) [27]

ម្ចាស់ជំនួយរបស់អង្គការ MAG ក្នុងឆ្នាំ ២០០០គឺ :

នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ (DFID), ECHO អង្គការ World Vision / AusAid អង្គការ AustCare អង្គការ CWS អង្គការ LWS រដ្ឋាភិបាលអូស្ត្រាលី សហរដ្ឋអាមេរិក UNHCR, Anti-landmijn Stichting និង អង្គការ UNICEF ។

## ការស្រាវជ្រាវ និង ការអភិវឌ្ឍន៍ (Research and Development)

តាមរយៈបទពិសោធន៍ សហគមន៍ដែលត្រូវការបោសសំអាតមីននៅកម្ពុជាជឿជាក់ថា ការរួមផ្សំរវាងឧបករណ៍ និង បច្ចេកទេសខុសៗគ្នាទាមទារអោយមានពិតមែន តែត្រូវដំណើរការអោយបានល្អក្នុងតំបន់មីនជាក់លាក់ ។ គ្មានដំណោះស្រាយ ‘‘គ្រាប់កាំភ្លើងប្រាក់’’ ទោលតែឯងណាមួយអាចពន្លឿនការបោសសំអាតមីនបានឡើយ ។ បច្ចេកទេសដោះមីនត្រូវស៊ីគ្នាទៅនឹងស្ថានភាព និង តំរូវការក្នុងស្រុក ។ អង្គការ CMACជឿជាក់ថា

[26] Reported from UNDP Trust Fund , Phnom Penh, Cambodia
[27] Archie Law: country program manager of MAG Cambodia, "MAG brief" p. 7, 23 Feb. 2001, Cambodia.

ដើម្បីបោសសំអាតមីនអោយមានប្រសិទ្ធិភាពក្នុងពេលអនាគតត្រូវមានការរួមផ្សំរវាងឧបករណ៍បច្ចេកទេសផ្សេងៗ ក្នុងប្រអប់សំភារៈតែមួយគឺ ជាដំណោះស្រាយដែលចាំបាច់[28] ។

បទពិសោធន៍គំរូមួយគឺបានពីការប្រើប្រាស់ម៉ាស៊ីនបោសសំអាតមីន Flail របស់ប្រទេសហ្វាំងឡង់ ។ កម្មវិធីនេះទទួលបានការឧបត្ថម្ភផ្ទាល់តាមរយៈ UNDP Trust Fund របស់រដ្ឋាភិបាលហ្វាំងឡង់ ។ ម៉ាស៊ីនបោសសំអាតមីន Flail ពីរគ្រឿងម៉ាក SISU RA-14DS និង រថពាសដែក APS កំពុងដំណើរការនៅតំបន់ខេត្តបន្ទាយមានជ័យ ។ គោលបំណងនៃអង្គភាពបោសសំអាតមីន Flail ដោយម៉ាស៊ីនឆ្នាំ ២០០១ គឺការប្រើប្រាស់ដោះមីនដើម្បីបង្កើនអត្រានៃការដោះមីនដោយដៃអោយកើនដល់ ៧០% ។ ម៉ាស៊ីននេះរៀបចំដីសំរាប់អ្នកដោះមីន បំផ្លាញអន្ទាក់លួស កាប់ចិញ្ច្រាំកូនរុក្ខជាតិហើយជាច្រើនលើកបំបែកគ្រាប់មីនអោយផ្ទុះដែលអាចបំពុលដីអោយខូចបាន[29]។

ម៉ាស៊ីនមួយគ្រឿងនឹងដោះមីនបានផ្ទៃដីប្រមាណ ៦ ហិកតាក្នុងមួយខែ ។ CMAC ស្នើសុំអោយមានការដោះមីនដោយប្រើម៉ាស៊ីនដោះរួមផ្សំជាមួយ ។ ម៉ាស៊ីនសំរាប់កាត់មានធ្មេញបួន ផ្តល់អោយដោយកម្មវិធីជំនួយដ៏ធំរបស់ជប៉ុនទើបនឹងសាកល្បង ហើយធ្វើការវាយតំលៃក្នុងគោលបំណងបញ្ចូលការដោះមីនដោយម៉ាស៊ីនទៅនឹងការដោះមីនដោយដៃអោយបានល្អ ។ បច្ចុប្បន្ននេះក្រុមដោះមីនមានម៉ាស៊ីនកាត់ស្មៅ ៤គ្រឿង (Hitachi 2 គ្រឿង និង Komatsu 2 គ្រឿង) ។ នៅថ្ងៃអនាគតក្រុមដោះមីននឹងបំពាក់ទៅដោយរថយន្តធុនធ្ងន់រ ថយន្តសណ្តោង និង អ្នកបញ្ជាឧបករណ៍ខ្លះ ។ គេប៉ាន់ស្មានថាអ្នកដោះមីនរបស់ CMAC ត្រូវចំណាយពេលប្រហែល ៦០% ទៅ ៧០% នៃពេលម៉ោងការងាររបស់ខ្លួន ក្នុងការកាត់អន្ទាក់លួស និង កាប់ចិញ្ច្រាំកូនរុក្ខជាតិ ។ ម៉ាស៊ីនកាត់ចិញ្ច្រាំមួយគ្រឿងអាចសំអាតផ្ទៃដីបានជាមធ្យម ៣.០០០គ.ម២ ក្នុងមួយថ្ងៃ ហើយអាចដាក់រាយម៉ាស៊ីននេះដើម្បីជួយគាំទ្រការបោសសំអាតមីនដោយដៃ និង ដោយប្រើឆ្កែរុករកមីន[30] ។

ការទទួលឆ្កែរុករកមីនមានប្រយោជន៍ខ្លាំងណាស់ សំរាប់បង្កើនសមត្ថភាពផ្នែកដោះមីនរបស់អង្គការ CMAC ។ ឆ្កែដែលបានទទួលការហ្វឹកហាត់នៅប្រទេសស៊ុយអែដ បានមកដល់ប្រទេសកម្ពុជា កាលពីខែសីហា ឆ្នាំ១៩៩៧ នៅពេលដែលអ្នកដោះមីនកម្ពុជាត្រូវបានគេជ្រើសរើសរួចជាស្រេច ហើយការហ្វឹកហាត់ប្រើឆ្កែទាំងនោះ ក៏ចាប់ផ្តើមក្នុងពេលនោះតែម្តង ។ ដោយមានសមត្ថភាពស្រង់ក្លិនបាន៤០០ដងច្រើនជាងមនុស្ស ឆ្កែដែលបានហ្វឹកហាត់រាវរកមីនអាចបង្កើនដំនើរការស្ទង់រកគ្រាប់មីនក្នុងតំបន់កាត់បន្ថយមីនបាន ។ ឆ្កែទាំងនោះជួយការដោះមីនដោយដៃមានប្រសិទ្ធិភាព និង មានគុណភាពប្រសើរឡើង ។ កម្មវិធីនេះអាចដំណើរការបាន គឺ ដោយ

---

[28] CMAC's Integrated Work plan 2001, page 10.
[29] Ibid. page 10
[30] CMAC's Integrated Work plan 2001,page 10

សារមានការគាំទ្រពីរដ្ឋាភិបាលស៊ុយអែដ និង ការគាំទ្រផ្នែកបច្ចេកទេសពីកងទ័ពស៊ុយអែដ តាមរយៈទីប្រឹក្សាបច្ចេកទេសដែលបញ្ជូនអោយមកបំពេញការងារ ។ ក្រុមឆ្កែរាវរកមីនត្រូវបានគេសាកល្បងនៅខេត្តបាត់ដំបងហើយទទួលបានអត្រានៃការរាវរកមីនកំរិតខ្ពស់បំផុត ។ ឆ្កែក្នុងស្រុកមិនអាចទទួលការហ្វឹកហាត់បានដោយជោគជ័យទេ។ ឆ្កែបរទេសទទួលអារម្មណ៍ពីការផ្លាស់ប្តូរអាកាសធាតុ [31]។

កម្មវិធីឆ្កែរាវមីនមានគំរោងការ និង ចំនុចគោលដៅក្នុងឆ្នាំ២០០១ដូចតទៅ [32] :

* ត្រូវពង្រាយឆ្កែរាវមីន៥ក្រុមអោយបានទៅដល់ទល់នឹងដំណាច់ឆ្នាំ២០០១ ។ ក្រុមនីមួយៗមានឆ្កែ៦ក្បាល ។
* ក្នុងកំឡុងឆ្នាំ ២០០១ គេរំពឹងថាក្រុមនីមួយៗនឹងបង្កើនសមត្ថភាពរបស់ខ្លួនហើយអាចសំរេចគោលដៅកាត់បន្ថយគ្រាប់មីនលើផ្ទៃដីចំនួន ១,២០០ម៉ ក្នុងមួយថ្ងៃ ។

ម៉ាស៊ីនព្យុះ (Tempest) គឺជាម៉ាស៊ីនផលិតក្នុងស្រុកដែលបានសាកល្បងប្រើដោយអង្គការ HALO Trust និង អង្គការ MAG រួចមកហើយ ។ វាមានអានុភាពខ្លាំងក្លា ប៉ុន្តែគុណភាពរបស់វាត្រូវតែកែលំអដើម្បីអាចទុកចិត្តបាន ។ គេត្រូវចំណាយពេលវេលាដើម្បីជួសជុលម៉ាស៊ីនដែលមានទិន្នផលទាប ។ វាពិតមែនហើយសំរាប់ម៉ាស៊ីនបោសសំអាតមីន Flail និង ម៉ាស៊ីនកាត់ស្មៅ (Brush cutter) និង ស្ថានភាពដីដោះមីនដែលទាមទារការប្រើប្រាស់ម៉ាស៊ីនអោយស៊ីទៅនឹងលក្ខណៈភូមិសាស្ត្ររបស់ដី នេះបើតាមប្រសាសន៍របស់ឯកឧត្តម អៀង ម៉ូលី ។

ការប្រើម៉ាស៊ីន និង ឆ្កែបែបដំណោះស្រាយព្រមគ្នាសោធអោយឃើញនូវជោគជ័យដ៏ធំធេងក្នុងវិស័យដោះមីននៅប្រទេសកម្ពុជាក្នុង ឆ្នាំ២០០១[33] ។

## បញ្ហាដែលកើតមានដោយសារមីន (Landmine Problem)

ចាប់ពីខែមករា ឆ្នាំ២០០០ រហូតដល់ខែធ្នូ ឆ្នាំ២០០០ ប្រជាជនចំនួន៧៩៣នាក់ បានទទួលរងគ្រោះ រឺ ស្លាប់ដោយសារគ្រាប់មីននៅក្នុងប្រទេសកម្ពុជា ។ ប្រការសំខាន់ដូចគ្នានោះ គឺ ការកសាងឡើងវិញក្រោយពីសង្គ្រាមបានបញ្ចប់ទៅនូវឧស្សាហកម្មបឋមចាំបាច់ទាំងឡាយ ដែលកំពុងរងនូវការរំខានបង្អាក់ដោយសារតែការធានារ៉ាប់រងចំពោះគ្រោះថ្នាក់គ្រាប់មីន ។ ទោះបីជាការស្រាវជ្រាវពត៌មានចំការមីនកំរិតថ្មី (new level surveys) កំពុងដំណើរការដើម្បីកំនត់បញ្ហា និង សើរើពិនិត្យឡើងវិញពីការប៉ាន់ប្រមាណចំនួនគ្រាប់មីនក្នុងសម័យអ៊ុនតាក់យ៉ាងណាក្តី ក៏ទំហំបញ្ហាមីននៅកម្ពុជានៅតែមិនទាន់កំរិតបានទៀងទាត់ទាំងស្រុងនៅឡើយ ។ បច្ចុប្បន្ននេះគេប៉ាន់

---

31 MDD team interview with Denise Coghlan , 12 February 2001, Battambang, Cambodia.
32 CMAC'S Integrated Work Plan 2001 page 12.
33 Ieng Mouly interview with Denise Coghlan 9 February 2001, Phnom Penh, Cambodia.

ស្ថានថាមានចំការមីន ៣.៦០០ កន្លែង គ្របដណ្តប់លើផ្ទៃដីប្រមាណ ២.៩០០ គ.ម² ភាពល្អក់កករបង្កឡើងដោយសារមីនរាលដាលពាសពេញផ្ទៃប្រទេស[34] ។

''ថ្វីបើគ្មានទិន្នន័យពិតប្រាកដក៏ដោយ ក៏ប្រតិបត្តិការសកម្មភាពមីនទំនងជាត្រូវការបន្តរយៈពេលពីប្រាំទៅដប់ឆ្នាំទៅមុខទៀតសំរាប់កំរិតដោះមីនក្នុងពេលបច្ចុប្បន្ននេះ ។ តាមឯកសាររបស់លោក Ian Bullpitt បានលើកឡើងថា ក្រោយពីដប់ឆ្នាំគេប្រហែលជាត្រូវការកាត់បន្ថយសមត្ថភាពដោះមីន ដើម្បីអោយវាស៊ីសង្វាក់ទៅនឹងអាទិភាព ដំណើរការដោះមីនធុនតូច និង កំរិតទាប និង សមស្របទៅនឹងរបាយការណ៍ស្តីពីគ្រាប់មីន និង គ្រាប់មិនទាន់ផ្ទុះច្រើនសន្ធឹកសន្ធាប់ ដែលអាចស៊ីពេលបោសសំអាតវាច្រើនជាងហាសិបឆ្នាំទៅមុខ''[35] ។

ប្រភេទដីដែលទទួលផលប៉ះពាល់ដោយសារមីនរួមមាន:

- ដីសំរាប់លំនៅដ្ឋាន
- ដីសំរាប់កសិកម្ម
- ដីសំរាបសង់សាលារៀន គ្លីនិក និង បំរើសេវាផ្សេងៗទៀត ។
- ដីសំរាប់ធ្វើថ្នល់ ស្ពាន និង កសាងហេដ្ឋានរចនាសម្ព័ន្ធដទៃទៀត ។
- ដីសំរាប់រកអុស ដីក្បែរកន្លែងនេសាទ និង ដីតំបន់ព្រៃ ។

## ការស្រាវជ្រាវ និង ការវាយតំលៃ (Surveys and Assessments)

សំនួរស្តីពីការស្រាវជ្រាវដ៏សមរម្យនៅកម្ពុជាក្នុងតំណាក់កាលសកម្មភាពបោសសំអាតមីនបច្ចុប្បន្ននេះត្រូវបានលើកឡើងយ៉ាងច្បាស់កាលពី ឆ្នាំ២០០០ ។ ជារួមការស្រាវជ្រាវសកម្មភាពមីនបានក្លាយទៅជាសកម្មភាពអភិវឌ្ឍន៍កំរិតខ្ពស់ពិសេសទាំងស្រុងនៃក្រុមស្ទាបស្ទង់ ដែលស្ទើរតែក្លាយទៅជាក្រុមឯកទេសនៃតំបន់ប្រតិបត្តិការរងមួយរបស់សកម្មភាពមីនទៅហើយ ។ ការប្រមូលទិន្នន័យពីមុនដោយអ៊ុនតាក់ និង ការស្រាវជ្រាវជាបន្តបន្ទាប់ដោយអង្គការCMAC គឺ ជាមូលដ្ឋាននៃពត៌មានដែលអាចរកបាននៅប្រទេសកម្ពុជា ប៉ុន្តែវាមិនទាន់គ្រប់គ្រាន់សំរាប់បទអន្តរាគមន៍ និង គំរោងការយូរអង្វែងនៅឡើយ[36] ។

''ការហត់នឿយក្នុងការស្ទាបស្ទង់ (survey fatigue)'' កំពុងតែក្លាយទៅជាកង្វល់ដែលកើនឡើងឥតឈប់ឈរនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និង ប្រទេសស្ថិតក្នុងស្ថានភាពក្រោយសង្គ្រាម ។ រឿងនេះកើតមានឡើងនៅពេលដែលអង្គការមួយចំនួនធំចុះហ្វឹកហាត់ប្រមូលទិន្នន័យទូលំទូលាយច្រើនយ៉ាងដោយគ្មានរបៀបរបប ហើយ

[34] Bullpitt Ian: p.31
[35] Ibid. p.2
[36] CMAC's Integrated Work plan 2001 page 11, Phnom Penh, Cambodia

ដែលជាលទ្ធផលនោះគឺប្រជាជនមូលដ្ឋានត្រូវអ្នកចុះសួរសុខទុក្ខមុខផ្សេងៗជិះក្នុងឡានសធំៗសួរសំនួរដូចផ្ទុះលាជ ប៉ុន្តែមិនដែលបានទទួលអ្វីតបជាប្រយោជន៍ ឬ ក៏ជាកំរៃឡើយ [37] ''។

បច្ចុប្បន្ននេះកម្មវិធីស្រាវជ្រាវកំរិតជាតិទីមួយរបស់កម្ពុជាកំពុងដំណើរការតាមបែបគំរោងការរួមរវាងអង្គការ CMAC កម្ពុជា និង ស៊ីដា (CIDA)កាណាដា ។ ក្រុមហ៊ុនស្រាវជ្រាវរបស់ប្រទេសកាណាដាឈ្មោះ Geo-spatial International Inc. (GeoSpatial/GST) គឺជាភ្នាក់ងារប្រតិបត្តិរបស់ប្រទេសកាណាដា ។ គេប្រ-មើលទុកជាមុនថា គំរោងការនេះនឹងបញ្ចប់នៅចុងឆ្នាំ២០០១ ។ ហើយលទ្ធផលដែលគេរំពឹងទុកមានដូចតទៅ [38]:

- ផែនទីមួយ ដែលងាយស្វែងយល់ពីទំហំបញ្ហាមីនដែលកំពុងកើតមាននៅប្រទេសកម្ពុជាសំរាប់រាជរដ្ឋា-ភិបាលកម្ពុជា ម្ចាស់ជំនួយ និង អង្គការអន្តរជាតិនានាប្រើប្រាស់ ។
- ឧបករណ៍ធ្វើគំរោងមួយសំរាប់ CMAC ប្រើប្រាស់ធ្វើគំរោងរយៈពេលវែងតទៅមុខ និង ជួយគិតគូពីអាយុកាលនៃបញ្ហាគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះដែលកម្ពុជាកំពុងប្រឈមមុខ ។
- ផលប៉ះពាល់ផ្នែកសង្គមកិច្ច និង សេដ្ឋកិច្ចនៃតំបន់ដែលរងគ្រោះដោយសារគ្រាប់មីន និង អាទិភាពនៃយុទ្ធសាស្ត្រ ។

និយមន័យនៃការបោះផ្លាកសញ្ញាសំគាល់តំបន់មានមីន/តំបន់អំពល់ដោយសារគ្រាប់មិនទាន់ផ្ទុះ និងនិយមន័យបន្ថែមទៀតអំពីអាទិភាពនៃយុទ្ធសាស្ត្រ ។

សេចក្តីសង្កេតក្រៅផ្លូវការទាំងឡាយក្នុងខេត្តនានាបានបង្ហាញថាតំបន់ដែលគេសង្ស័យថាមានគ្រាប់មីនអាចមានច្រើនជាងការស្រាវជ្រាវដែលគេបានប៉ាន់ស្មានទុកពីមុនទៅទៀត ។

លទ្ធផលនៃការស្រាវជ្រាវពត៌មានចំការមីនថ្នាក់ជាតិកំរិតទីមួយមកទល់សព្វថ្ងៃនេះ÷

គិតត្រឹមថ្ងៃ ២៤ ខែកុម្ភៈ ឆ្នាំ ២០០១ ការងារស្រាវជ្រាវតាមមូលដ្ឋានបានបញ្ចប់ការងារនៅខេត្តកំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង ក្រុងប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ និង ផ្នែកខ្លះនៃខេត្តសៀមរាប ។ ភូមិចំនួនប្រហែល ២,៧០០ភូមិ ត្រូវបានគេស្រាវជ្រាវរួច ។ ខេត្តដែលគេបានបញ្ចប់ការស្រាវជ្រាវរហូតមកទល់ពេលនេះ សុទ្ធសឹងជាខេត្តដែលមានមីនច្រើនជាងគេបំផុតនៅប្រទេសកម្ពុជា ។ កំរិតនៃកិច្ចប្រឹងប្រែង (គឺថាពេលវេលាដែលគេត្រូវការក្នុងការស្រាវជ្រាវភូមិមួយ) ដើម្បីបំពេញការស្រាវជ្រាវក្នុងបណ្តាខេត្តទាំងនោះ គឺ មានទំហំធំជាងកិច្ចប្រឹងប្រែងដែលគេនឹងធ្វើនៅបណ្តាខេត្តដទៃទៀតភាគច្រើននៃប្រទេសកម្ពុជា ។ ការស្រាវជ្រាវពត៌

[37] Bullpitt Ian: p.46
[38] CMAC's Integrated Work plan 2001, 15 November 2000, page 12, Cambodia.

មានចំការមីនថ្នាក់ជាតិត្រូវបានគេប៉ាន់ស្មានថាសំរេចបាន ៣៥ ទៅ ៤០% ទោះបីជាចំនួនភូមិដែលបានបញ្ចប់ការស្រាវជ្រាវមានចំនួនតិចជាងមួយភាគបីនៃចំនួនភូមិទាំងអស់ក្នុងប្រទេសកម្ពុជាក៏ដោយ [39] ។

លទ្ធផលដែលបានពីភូមិចំនួន ២៣៩៥ភូមិ មកទល់នឹងពេលនេះបានបញ្ចូលក្នុងឯកសារទិន្នន័យរួចជាស្រេច ។ ពត៌មានស្តីពីការស្រាវជ្រាវនេះត្រូវបានសង្ខេបក្នុងតារាងដូចខាងក្រោមនេះ [40] :

| ខេត្ត/ក្រុង | ភូមិថ្មី | សរុបភូមិ | តំបន់ដែលមានមីន | តំបន់មានគ្រាប់មិនទាន់ផ្ទុះ | ភូមិដែលមានមីន | អត្រាភាគរយនៃភូមិដែលមានមីនធៀបនឹងភូមិទាំងអស់ |
|---|---|---|---|---|---|---|
| បន្ទាយមានជ័យ | ៣៥ | ៥៤៥ | ២៤១ | ២៤៦ | ២១៤ | ៣៩% |
| បាត់ដំបង | ១២៩ | ៧៥៤ | ៨៤៨ | ៥១៦ | ៤៣៩ | ៥៨% |
| កំពង់ឆ្នាំង | ០ | ៥២០ | ៥០ | ២២៣ | ១៧១ | ៣៣% |
| ពោធិ៍សាត់ | ៦ | ៤៩៨ | ១០៩ | ១៣៦ | ១២៦ | ២៥% |
| ក្រុងប៉ៃលិន | ២៥ | ៧៨ | ១០៣ | ៦១ | ៧១ | ៩១% |
| **សរុបចំនួន** | ១៩៥ | ២,៣៩៥ | ១,៣៥១ | ១,១៨២ | ១,០២១ | ជាមធ្យម ៤២% |

ទិន្នន័យនេះបង្ហាញថា ខេត្តបាត់ដំបង និង តំបន់ក្បែរក្រុងប៉ៃលិនជាតំបន់ដែលមានគ្រាប់មីនច្រើនជាងគេ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ខេត្តនីមួយៗប្រែប្រួលទៅតាមស្រុក ។ តួយ៉ាងស្រុកម៉ាឡៃដែលជាអតីតតំបន់ការពាររបស់ខ្មែរក្រហមក្នុងខេត្តបន្ទាយមានជ័យមានភូមិ ៣៤ មានមីន ក្នុងចំណោមភូមិទាំង ៣៨ (៨៩% សំរាប់ស្រុកម៉ាឡៃបើធៀបទៅនឹង ៣៩%របស់ខេត្ត គិតជាមធ្យម)។

កម្មវិធីស្រាវជ្រាវពត៌មានចំការមីនថ្នាក់ជាតិកំរិតទី៣មួយ ដែលឧបត្ថម្ភដោយប្រទេសអាល្លឺម៉ង់កំពុងដំណើរការងារ ។ ឯកសារទិន្នន័យនឹងចងក្រងនៅក្នុងអាគារថ្មីរបស់ CMAA។

## ការបោសសំអាតមីន (Mine Clearance)

ការបោសសំអាតមីននៅកម្ពុជា ធ្វើឡើងដោយមជ្ឈមណ្ឌលសកម្មភាពមីនកម្ពុជា (CMAC) អង្គការ HALO Trust (អង់គ្លេស) អង្គការ MAG (អង់គ្លេស) កងយោធពលខេមរភូមិន្ទ និង តាមរយៈអ្នកភូមិហៅថាជា ‘‘ អ្នកដោះមីន ’’ ដែលជួនកាលគេហៅថាជាការដោះមីនដោយខ្លួនឯង ។ អង្គការជំនួយខាងដោះមីន ឥឡូវនេះត្រូវបានគេអនុញ្ញាតអោយដោះមីនជាផ្លូវការហើយ ។

[39] A. (Tony) Chori: "Cambodia National Level One Survey Project: Status Report ",p. 3 GeoSpatial International Inc. P. Penh, Cambodia, 23 February 2001.
[40] Ibid. p.3

## ការដោះមីនសរុបក្នុងឆ្នាំ ២០០០

| អង្គការ | ផ្ទៃដីបោសសំអាតមីនរួចម[២] | មីនប្រឆាំងមនុស្ស | មីនប្រឆាំងរថក្រោះ | គ្រាប់មិនទាន់ផ្ទុះ |
|---|---|---|---|---|
| CMAC | ៨,៣៦៩,៦៣៥ | ១៥,៧៣៣ | ៦២៨ | ៤៥,៣៧៩ |
| HALO Trust | ៣,០០០,៤៥៣ | ២,៦៦៤ | ១០ | ២,៤២៦ |
| MAG | ៨០៥,២៥២ | ៣,១៣៨ | ៣២ | ៧,៤៨៤ |
| ក្រុមឯទៀត | | | | |
| កងយោធពលខេមរភូមិន្ទ | ២០,០១១,០០០ | ១,០៧៨ | ១៨៦ | ៦,២៩០ |
| ចំនួនសរុប(ដែលដឹង) | ៣២,១៨៦,៣៤០ | ២២,៦១៣ | ៨៥៦ | ៦១,៥៧៩ |

## មជ្ឈមណ្ឌលសកម្មភាពមីនកម្ពុជា (CMAC)

បេសកម្មរបស់អង្គការ CMAC ក្នុងឆ្នាំ២០០១ គឺ ‘‘សង្គ្រោះជីវិត និង គាំទ្រកិច្ចអភិវឌ្ឍន៍នៅកម្ពុជា’’ ។ អង្គការ CMAC ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៣ក្នុងសម័យ UNTAC ។ កាលពីពេលនោះ ការដោះមីនជំនួយមនុស្សធម៌មានជំនាញស្ទួចស្តើងប៉ុណ្ណោះដែលអាចរកបាន ។ ការខ្វះជំនាញសកលដើម្បីផ្សារភ្ជាប់ជាមួយគំនិតយោធាដ៏មានឥទ្ធិពលនៅពេលនោះ បានលេចចេញឡើងនូវព្រះរាជក្រឹត្យតែងតាំងស៊ីម៉ាក់ជាស្ថាប័នជំនាញសំរាប់មនុស្សរាល់គ្នា ដែលជាអង្គភាពផ្នែកធ្វើគំរោង និង សំរបសំរួលរបស់ជាតិ ជាសេវាចំបងក្នុងការបោសសំអាតមីន និង កំទេចគ្រឿងផ្ទុះ ជាអ្នកបំផុសការយល់ដឹងពីមីន និង ការរុករកមីន ជាមជ្ឈមណ្ឌលជាតិហ្វឹកហាត់បច្ចេកទេសដោះមីន និង ជាវិជ្ជាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍ ។ CMAC បានបង្កើនចំនួនបុគ្គលិកយ៉ាងឆាប់រហ័សជិតដល់ ៣០០០នាក់ នៅដើមឆ្នាំ២០០០ [41] ។

លទ្ធភាពដោះមីនរបស់ CMAC បានរងនូវវិបត្តិមូលនិធិ ដែលសំរេចអោយមានការបញ្ឈប់បុគ្គលិកជាច្រើនរូបកាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០០ ។ នៅខែតុលា កងអនុសេនាតូចដោះមីនចំនួន៦៦កង ត្រូវកាត់បន្ថយមកនៅត្រឹមតែ១៥កង ក្រុមបោះផ្លាកសញ្ញាមីន១២ក្រុមត្រូវកាត់បន្ថយមកនៅត្រឹម៨ក្រុម ក្រុមកំទេចផ្ទុះចំនួន២៣ក្រុមត្រូវកាត់បន្ថយមកនៅត្រឹមតែ៩ក្រុម ហើយក៏មានការកាត់បន្ថយផងដែរនូវ ក្រុមបំផុសការយល់ដឹងអំពីមីន១២ក្រុម និង ក្រុមបោះផ្លាកសញ្ញាមីនក្នុងសហគមន៍ចំនួន១២ក្រុម ។ ក្រុម CMAC ផ្នែកកម្មវិធីស្រាវជ្រាវពត៌មានចំការមីនកំរិតទី១ចំនួន៨ក្រុម បានចាប់ផ្តើមធ្វើការជាមួយ Geo-Spatial តាំងដំបូងទីនៃកម្មវិធីម្ល៉េះ ។

---

[41] Bullpitt Ian: "Summary of Discussions and Recommendations Relating To National Strategy and Management Of The Mine Action Sector Within Cambodia In The Short and Long Term Beyond 2000," Phnom Penh 5 November 2000 p.31.

ដើម្បីសង្គ្រោះជីវិតមនុស្ស ស្ថិតិនៃគ្រោះថ្នាក់ដោយសារគ្រាប់មីនអាចប្រើជាមូលដ្ឋានសមហេតុសមផល ក្នុងការសំរេចលើអាទិភាពនៃការចុះធ្វើអន្តរាគមន៍ ។ CMAC កំពុងដាក់ពង្រាយកងកំលាំងតាមបណ្តាខេត្តដែលរងគ្រោះដោយសារមីននីមួយៗ ដោយយោងទៅតាមអត្រានៃគ្រោះថ្នាក់ដោយសារមីន ។

ការរីកចំរើនផ្នែកដោះមីនរបស់ស៊ីម៉ាក់ ក្នុងកំឡុងឆ្នាំ ១៩៩៣ ដល់ ២០០០[42]:

| កំឡុងពេល | បោសសំអាត/កំទេចចោល | | | |
|---|---|---|---|---|
| | ផ្ទៃដី (ម$^{២}$) | មីនប្រឆាំងមនុស្ស | មីនប្រឆាំងរថក្រោះ | គ្រាប់មិនទាន់ផ្ទុះ |
| UNTACមីនា/៩២-តុលា/៩៣ | ៥,៤៧៩,៨៥០ | ១៩,៤៣៣ | ១៣២ | ៩៦,៤៨៦ |
| CMAC វិច្ឆិកា/៩៣-ធ្នូ/៩៤ | ៧,៨៦៥,២៤២ | ១២,១២៦ | ១២១ | ២០៨,៨៥៤ |
| CMAC ១៩៩៥ | ១០,១៥០,០១៤ | ២២,១១៥ | ៩៣ | ៤៧,១២៣ |
| CMAC ១៩៩៦ | ១០,៤៩៣,៦៥៤ | ៧,១២៦ | ១៩០ | ៣១,៥៧៤ |
| CMAC ១៩៩៧ | ១៥,៥៦៥,៤២១ | ១៧,០៣៥ | ២៦៦ | ៣២,៧៦៧ |
| CMAC ១៩៩៨ | ១២,៣៨២,៥៤១ | ១៣,៥៣៦ | ២៤៥ | ៤៧,៣១៣ |
| CMAC ១៩៩៩ | ១០,៧៩៧,៧០៥ | ១៤,៣២២ | ៦៤៩ | ៦៧,៦១០ |
| មករា ២០០០ | ១,០២៧,១៩១ | ១,៧៣៤ | ៤៦ | ៦,១០៨ |
| កុម្ភៈ ២០០០ | ៨៣៩,៩៧៨ | ១,៩៣៧ | ១១៤ | ១១,៥៦២ |
| មីនា ២០០០ | ៦៨១,៧១២ | ១,៥៦១ | ២៤ | ៦,៦៨៣ |
| មេសា ២០០០ | ៧០៣,១២៤ | ១,១៤២ | ៣១ | ២,៦៣៥ |
| ឧសភា ២០០០ | ៦៥៩,៨២០ | ៦០១ | ៦៥ | ៣,១០៩ |
| មិថុនា ២០០០ | ៧០១,៩៣៣ | ១,៨៨៣ | ១៥៤ | ៣,៦២៨ |
| កក្កដា ២០០០ | ១,០០៤,២៩៨ | ៣,២៣៨ | ១២៣ | ៤,៩០៩ |
| សីហា ២០០០ | ៨៦០,៣៥៧ | ១,៤៣៧ | ៣៦ | ២,៩៨៨ |
| កញ្ញា ២០០០ | ៧៥៦,០៥៥ | ៧៩១ | ១៨ | ២,២១៥ |
| តុលា ២០០០ | ៥៧៧,០២៣ | ៦២១ | ៤ | ៩២៧ |
| វិច្ឆិកា ២០០០ | ១៧២,៨៣៣ | ២៦៨ | | ២៥៨ |
| ធ្នូ ២០០០ | ៣៨៥,៧១១ | ៥២០ | ១៣ | ៣៥៧ |
| សរុបឆ្នាំ ២០០០ | ៨,៣៦៩,៦៣៥ | ១៥,៧៣៣ | ៦២៨ | ៤៥,៣៧៩ |
| សរុប CMAC ៩៣-៩៩ | ៦៧,២៥៤,៥៧៧ | ៨៦,២៦០ | ១,៥៦៤ | ៤៣៥,២៤១ |
| សរុបរួម ១៩៩៣- ២០០០ | ៨១,១០៤,០៦២ | ១២១,៤២៦ | ២,៣២៤ | ៥៧៧,១០៦ |

[42] Response by CMAC Report , January 1, 2001, Phnom Penh, Cambodia.

ការដាក់ពង្រាយធនធានរបស់ស៊ីម៉ាកដោយយោលទៅតាមគ្រោះថ្នាក់ដោយសារមីន [43] ( ខែកញ្ញាឆ្នាំ២០០០):

| ខេត្តតាមលំដាប់គ្រោះថ្នាក់ដោយសារមីន/គ្រាប់មិនទាន់ផ្ទុះ | គ្រោះថ្នាក់ឆ្នាំ ២០០០ | ការបោសសំអាតមីនដោយដៃ | ការយល់ដឹងពីមីន/គ្រាប់មិនទាន់ផ្ទុះ | ក្រុមដាក់ផ្លាកសញ្ញាមីនសហគមន៍ | កំទេចគ្រឿងផ្ទុះ |
|---|---|---|---|---|---|
| បាត់ដំបង | ២១៩ | ៥៥% | ២៧% | ៥០% | ១៤% |
| បន្ទាយមានជ័យ | ៩៤ | ២៥% | ១៨% | ២០% | ១៤% |
| ឧត្តរមានជ័យ | ៥៦ | ៥% | ១៨% | - | ជាមួយ PMU |
| ព្រះវិហារ | ៥៣ | ៧% | ការដាក់ពង្រាយសាកល្បង | - | - |
| សៀមរាប | ៣៨ | ៥% | ១៨% | | ជាមួយ PMU |
| ប៉ៃលិន | ៤២ | ២០០១(IWP) | ៩% | ២៥% | ១៤% |
| កំពង់ធំ | ១៨ | ៣% | - | - | - |
| ខេត្តដទៃទៀត | ១២៧ | - | ១០% | - | ៥៨% |
| **សរុប** | **៦៤៧** | **១០០%** | **១០០%** | **១០០%** | **១០០%** |

អង្គការស៊ីម៉ាក់បានពង្រីកគំរោងការបញ្ចូលការងារក្នុងឆ្នាំ ២០០១ ដើម្បីបោសសំអាតមីនលើផ្ទៃដីចំនួន ៧,៦៩៥,០០០ម២ នៃចំនួនផ្ទៃដីទាំងអស់១១,៣៦០,០០០ម២ ដែលសំរាំងដោយគណ:កម្មការខេត្តផ្នែកដោះមីន សំរាប់ការតាំងលំនៅដ្ឋាន ធ្វើកសិកម្ម ធ្វើផ្លូវ សង់សាលារៀន និង សង់មណ្ឌលសុខភាពក្នុងបណ្តាខេត្តចំនួន៧ ។ អ្នកដោះមីនចំនួន១២០០នាក់ ឬ បុគ្គលិកជំនួយត្រូវបានអះអាងថានឹងបានការងារធ្វើវិញបន្តិចម្តងជាលំដាប់នៅពេលណាដែលប្រព័ន្ធការងារមានតម្លាភាព ។ ទឹកចិត្ត CMAC បានប្រសើរឡើងវិញជាថ្មី ហើយក៏មានការប្តេជ្ញាថានឹងធ្វើការអោយមានប្រសិទ្ធិភាពក្នុងអង្គការទាំងមូល ។

**អង្គការ HALO TRUST:**

HALO Trust គឺជាអង្គការក្រៅរដ្ឋាភិបាលរបស់អង់គ្លេសដែលមិនមាននិន្នាការនយោបាយ សាសនា ប្រកាន់អព្យាក្រឹតភាព មនុស្សធម៌ សប្បុរស មានឯកទេសខាងបោសសំអាតកាកសំណល់នៃសង្គ្រាម ។ បេសកម្មរបស់ HALO Trust ក្នុងប្រទេសកម្ពុជា គឺកាត់បន្ថយការឈឺចាប់របស់ប្រជាជនក្នុងអតីតតំបន់ពើបប្រយុទ្ធគ្នា ។ តួនាទីរបស់ HALO Trust គឺលាតសន្ធឹងកិច្ចសង្គ្រោះបន្ទាន់ក្នុងតំបន់ដែលគ្មានការគាំទ្រ ឬមានការគាំទ្រតិចតួច និង ដើម្បីពង្រឹងប្រតិបត្តិការនៅគ្រប់កាលៈទេសៈដ៏លំបាកទាំងឡាយ ។ HALO Trust

[43] CMAC's Integrated Workplan 2001,15 November 2000, p. 5, Phnom Penh, Cambodia.

ក៏បានលះបង់ខ្ពស់ក្នុងការហ្វឹកហាត់ និង ពង្រឹងសមត្ថភាពផ្នែកចាត់ចែងដល់បុគ្គលិកកម្ពុជា ដើម្បីអោយអង្គការនេះមានប្រសិទ្ធិភាពបំរើការងារជាបន្តក្នុងប្រទេសទោះបីជាក្រោយពេលដែលអន្តរាគមន៍របស់បុគ្គលិកបរទេសស្ម័គ្រចិត្តបញ្ចប់ទៅក៏ដោយ [44] ។

គោលបំណងនៃកិច្ចប្រតិបត្តិការបោសសំអាតមីននៅកម្ពុជារបស់អង្គការ HALO Trust គឺ [45]:

១-សង្គ្រោះជីវិត និង ទប់ស្កាត់គ្រោះថ្នាក់ដោយសារមីន ។

២-ប្រគល់ដីដែលបានធ្វើការបោសសំអាតមីនរួចជូនទៅសហគមន៍ ។

HALO Trust បានចាប់ផ្តើមការងារនៅប្រទេសកម្ពុជាកាលពីខែតុលាឆ្នាំ១៩៩១ នៅក្នុងខេត្តបន្ទាយមានជ័យ តាមសំណើរបស់អង្គការ UNHCR ដោយយោលទៅលើការធ្វើមាតុភូមិនិវត្តន៍របស់ប្រជាជនយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ HALO Trust បានចាប់ផ្តើមការស្រាវជ្រាវលើបញ្ហាមីនក្នុងខេត្តចំនួនបួននៃភូមិភាគពាយ័ព្យក្រោមកិច្ចគាំទ្ររបស់អង្គការ UNHCR ។ ជាលទ្ធផលនៃការស្រាវជ្រាវជាបន្តបន្ទាប់នោះសំណើរអោយបោសសំអាតមីនយ៉ាងច្បាស់លាស់មួយត្រូវបានគេកំនត់ធ្វើនៅ ខេត្តពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ និង សៀមរាប ។ ដោយមានស្ថាប័ន CMAC និង ការរីកដុះដាលនៃប្រតិបត្តិការបោសសំអាតមីននៅកម្ពុជារបស់អង្គការដោះមីនដទៃទៀតនោះ HALO មានលទ្ធភាពផ្តោតបេសកកម្មរបស់ខ្លួន និង ពង្រាយបុគ្គលិកដោះមីនក្នុងតំបន់ដែលក្រីក្របំផុត និង តំបន់ដែលទើបរងការប្រយុទ្ធថ្មីៗ [46] ។

គិតមកទល់ខែមករាឆ្នាំ២០០១ អង្គការ HALO Trust បានបោសសំអាតផ្ទៃដីមីន ១២,៣៨២,៨៣០ម² បានកំទេចគ្រាប់មីនចំនួន២៥,១៩៧គ្រាប់ (ដោយរាប់បញ្ចូលទាំងមីនប្រឆាំងរថក្រោះផង) និង កំទេចគ្រាប់មិនទាន់ផ្ទុះចំនួន២១,៥៩៨គ្រាប់ ។ កិច្ចការនេះមានសារៈសំខាន់យ៉ាងខ្លាំងចំពោះជីវភាពរស់នៅរបស់ប្រជាជនខ្មែររាប់ពាន់នាក់ដែលរស់នៅក្នុងតំបន់ពាយ័ព្យនៃប្រទេសកម្ពុជា ។ ជីវិតមនុស្សជាច្រើននាក់ត្រូវបានសង្គ្រោះ ហើយគ្រួសារជាច្រើនបច្ចុប្បន្ននេះមានលទ្ធភាពទទួលដីសំរាប់សង់ផ្ទះ ដាំដំណាំ សង់សាលារៀន សង់មណ្ឌលសុខភាព និង អាចរកទឹកស្អាតបានប្រើប្រាស់ដោយសុវត្ថិភាព ។ នៅឆ្នាំ២000 [47] អង្គការ HALO Trust ដោះមីនបានផ្ទៃដី ៣,000,៤៥៣ម² និង ត្រៀមផ្ទៃដី ចំនួន៨៩២,១៤៥ម² បន្ថែមទៀត សំរាប់ការបោសសំអាតមីននៅពេលខាងមុខ ។

---

[44] David McMahom, Deputy director Halo Trust Cambodia "Briefing Paper Executive Summary " p.2, January 2001, Phnom Penh , Cambodia.
[45] Ibid. p.2
[46] Ibid. p.2
[47] David McMahom, Deputy director Halo Trust Cambodia "Briefing Paper Executive Summary " p.3, January 2001, Phnom Penh , Cambodia.

បុគ្គលិកអង្គការ HALO Trust បច្ចុប្បន្ននេះចែកចេញជា៧៧ផ្នែកក្រុមដោះមីនដែលមាន៧នាក់ក្នុងមួយក្រុម បោសសំអាតមីនលើផ្លូវចំនួន៥៣៩ផ្លូវ អមដោយអង្គភាពត្រាក់ទ័រប្រដាប់ដោយកន្ត្រៃកាត់ស្មៅចំនួន១២គ្រឿង ដែលធ្វើអោយចំនួនបុគ្គលិកទាំងអស់សរុបមាន៨៥៩នាក់ ។ ប្រតិបត្តិការបោសសំអាតមីនមាននៅតំបន់ពាយ័ព្យប្រទេសកម្ពុជាក្នុងទីតាំងបួនកន្លែងរៀបតាមលំដាប់ទំហំគឺ ថ្មពួក អន្លង់វែង សៀមរាប និង សំរោង[48] ។

HALO Trust ប្រើប្រព័ន្ធ '' មនុស្សម្នាក់សំអាតមួយផ្លូវ '' គឺថារៀងរាល់ថ្ងៃធ្វើការដោះមីន អ្នកដោះមីនចំនួន៥៣៩នាក់ ជាមួយនឹងឧបករណ៍៥៣៩គ្រឿងត្រូវធ្វើការ៧ម៉ោង[49] ។ ក្រុមដោះមីនបញ្ចាឧបករណ៍ដោះមីនពីចំងាយក្នុងកំរិតមធ្យមដោយបំពេញការងារបានចំនួន៤០កិច្ចការក្នុងមួយពេល ។

## កិច្ចប្រតិបត្តិការបច្ចុប្បន្ន

HALO Trust បច្ចុប្បន្នកំពុងបំពេញការងារក្នុងទីតាំងអាទិភាពខ្ពស់ចំនួន៣៦កន្លែងគឺខេត្តបន្ទាយមានជ័យ១៣កន្លែង ខេត្តសៀមរាប៦កន្លែង និង ខេត្តឧត្តរមានជ័យ១៧កន្លែង ហើយប្រើប្រាស់អ្នកដោះមីនជំនាញ៥៣៩នាក់ និង មានទីតាំងមូលដ្ឋានប្រតិបត្តិការទាំងស្រុងចំនួន៤កន្លែងនៅខេត្តសៀមរាប ស្រុកថ្មពួក (ខេត្តបន្ទាយមានជ័យ) ស្រុកសំរោង និង អន្លង់វែង (ខេត្តឧត្តរមានជ័យ)[50] ។

## ប្រតិបត្តិការដោយប្រើម៉ាស៊ីន

### *កន្ត្រៃកាត់ស្មៅ (Vegetation Cutting)*

តាំងពីដើមមក ក្នុងប្រតិបត្តិការរបស់ HALO Trust កម្ពុជាគេឃើញថា អ្នកដោះមីនប្រើពេលវេលារបស់ខ្លួនពី៧០% ទៅ ៨០% ដើម្បីឆ្ការព្រៃមុនពេលគេអាចដោះមីននៅនឹងផ្ទៃដីផ្ទាល់បាន ។ ហេតុនេះហើយទើបក្នុងឆ្នាំ១៩៩៥/១៩៩៦ HALO បានសាកល្បងប្រើត្រាក់ទ័រគំរូមួយប្រកបដោយរថក្រោះមានគំរបបីជ្រុងមួយគ្រឿង និង ម៉ាស៊ីនកាត់ស្មៅមួយគ្រឿងដែលមានដៃប្រើដោយប្រេងបូមថ្នក់ពីក្រោយ ។ អង្គភាពដោះមីនបញ្ចាដៃម៉ាស៊ីនដែលប្រើដោយប្រេងបូមទៅកាត់គុម្ពោតព្រៃលើផ្ទៃដីដែលស៊ុបទ្រុបចោល ។ ចាប់តាំងពីត្រាក់ទ័ររបស់ HALO Trust បំពាក់ទៅដោយម៉ាស៊ីនកាត់ស្មៅ ដែលធ្វើប្រតិបត្តិការកើនចំនួនដល់១៣អង្គភាព ហើយធ្វើការពង្រាយកាត់ឆ្ការគុម្ពោតព្រៃមុនពេលដោះមីនមក ជាលទ្ធផលអត្រាភាគរយនៃការដោះមីនក្នុងមួយផ្លូវៗបានកើនឡើងដល់ ១០០% ក្នុងចំការមីនដែលរៀបចំជាស្រេចដោយអង្គភាពទាំងនេះ[51] ។

---

[48] Ibid. p.4
[49] Ibid. p.4
[50] Ibid. p.5
[51] David McMahom, Deputy director Halo Trust Cambodia "Briefing Paper Executive Summary " p.5, January 2001, Phnom Penh, Cambodia.

## ការបោសសំអាតមីនដោយប្រើម៉ាស៊ីន

HALO Trust បច្ចុប្បន្ននេះ កំពុងដំណើរការប្រើម៉ាស៊ីនខ្ចងជួយអ្នកដោះមីនក្នុងតំបន់ដែលមានផ្ទុកជាតិដែកបង្កគ្រោះថ្នាក់ក៏រិតខ្ពស់ ឬក៏កន្លែងដែលគេត្រូវខ្ចងក្នុងជំរៅមិនលើសពីមួយស្លាបព្រាបាយអដល់មីន ។ ប្រព័ន្ធនេះប្រើត្រាក់ទ័រភ្ជាប់ដោយប៉ែលយន្ត ដែលត្រូវបានបង្កើតនៅក្នុងទីក្រុងកាប៊ុលប្រទេសអាហ្គានីស្ថានហើយដែលបច្ចុប្បន្ននេះត្រូវបានគេផ្នែតំរូវទៅតាមបរិស្ថាននៃប្រទេសកម្ពុជា[52] ។

## គំរោងទៅអនាគត

ក្នុងត្រីមាសទីមួយដើមឆ្នាំ២០០១ HALO Trust មានគំរោងរើសបុគ្គលិកដោះមីនបន្ថែមអោយបាន ២១៧នាក់ទៀត ដើម្បីបង្កើនអោយបានដល់១០៨ផ្នែក ដែលក្នុងនោះមានអ្នកដោះមីនចំនួន៧៥៦នាក់ ។ បុគ្គលិកខ្មែរជំនួយការអ្នកដោះមីនទាំងនេះមានខ្មែរប្រមាណ១២០០នាក់ដោយមានបរទេសពី២ទៅ៣នាក់ផង[53] ។

នៅពេលណាដែល HALO Trust ពង្រឹងបាន ហើយយល់ថាអាចបំពេញតំរូវការផ្នែកបោសសំអាតមីនបានគ្រប់គ្រាន់តាមបណ្តាខេត្តក្នុងភូមិភាគពាយ័ព្យហើយនោះ HALO គំរោងនឹងពង្រីកការងារនេះនៅតាមខេត្តផ្សេងទៀតដែលទទួលការបោសសំអាតមីនតិចតួច ឬក៏មិនដែលបានបោសសំអាតមីនទាល់តែសោះ [54] ។

ក្នុងឆ្នាំ២០០០ អង្គការ HALO Trust ដោះមីនបានផ្ទៃដី ៣,០០០,៨៥៣ម៉ែ២ និងបានត្រៀមផ្ទៃដីបន្ថែម៨៩២,១៤៥ម៉ែ២ សំរាប់ការសំអាតក្នុងពេលខាងមុខ ។ អង្គការនេះបានរកឃើញនិងកំទេចគ្រាប់មីនប្រឆាំងមនុស្សចំនួន២៦៦៨គ្រាប់ គ្រាប់មីនប្រឆាំងរថក្រោះ១០គ្រាប់ និង គ្រាប់មិនទាន់ផ្ទុះ២៤២៦គ្រាប់ ។ ការបោសសំអាតមីនទាំងនេះបានធ្វើឡើងនៅក្នុង ខេត្តសៀមរាប ឧត្តរមានជ័យ និង បន្ទាយមានជ័យ[55] ។

អង្គការ HALO Trust បានអោយដឹងថា បុគ្គលិកដោះមីន៥នាក់បានស្លាប់ដោយជំងឺអេដស៍ក្នុងឆ្នាំ២០០០. HALO Trust យល់ថាជំងឺនេះ[56] ជាបញ្ហាចំបងសំរាប់ការដោះមីននាពេលខាងមុខនៅប្រទេសកម្ពុជាព្រោះតែការបាត់បង់អ្នកដោះមីនដែលមានជំនាញ និង ទទួលបានការបណ្តុះបណ្តាល ។ អង្គការ MAG ក៏បានរាយការណ៍ថាមានអ្នកដោះមីន៤នាក់ ស្លាប់ដោយសារជំងឺអេដស៍ ហើយអង្គការ CMAC ក៏បានគិតផងដែរថា ជំងឺអេដស៍ជាបញ្ហាដ៏ធ្ងន់ធ្ងរបំផុត ។

---

[52] Ibid. p.5
[53] Ibid. p.5
[54] Ibid. p.5
[55] David McMahom, Deputy director Halo Trust to Land Mine Monitor (Denise Coghlan) on 22 February 2001 Phnom Penh , Cambodia.
[56] David McMahom, Deputy director Halo Trust to Land Mine Monitor (Denise Coghlan) on 22 February 2001 Phnom Penh , Cambodia.

## អង្គការ MAG [57]

MAG នៅប្រទេសកម្ពុជាចាប់ផ្តើមប្រតិបត្តិការកាលពីខែតុលា ឆ្នាំ១៩៩២ ដោយពង្រាយក្រុមដោះមីនមួយក្រុមនៅក្នុងខេត្តបាត់ដំបង ។ សព្វថ្ងៃនេះ អង្គការ MAG មានក្រុមប្រតិបត្តិការផ្នែកសកម្មភាពមីន (MAT) ២០ក្រុម និង ក្រុមកំទេចគ្រឿងផ្ទុះ២ក្រុម ។ ពេលនេះ MAG មានអ្នកដោះមីន៣០០នាក់កំពុងធ្វើការដោះមីននៅកម្ពុជា ។ គំនិតការងាររបស់ MAT រីកចំរើនដោយសារ MAG ក្នុងការពង្រីកឥទ្ធិពលដល់គំរោងការមីននៅតាមសហគមន៍ដែលទទួលរងគ្រោះដោយសារមីន ។ MATs ជាការបញ្ចូលគ្នានៃក្រុមបោសសំអាតមីនដែលមានសមត្ថភាពជាមួយនឹងក្រុមកំទេចគ្រឿងផ្ទុះ ក្រុមទំនាក់ទំនងតាមសហគមន៍ ក្រុមបោះផ្លាកសញ្ញាចំការមីន និង ក្រុមស្រាវជ្រាវពត៏មានចំការមីន ។ ជាអាទិភាព MATs ផ្តោកទៅលើការសំអាតដីឡូត៍សំរាប់សហគមន៍ប្រើប្រាស់ ដូចយ៉ាង បរិវេណវត្ត ទីប្រភពទឹក គ្លីនិច សាលារៀន និង តំបន់ត្រូវសាងសង់លំនៅដ្ឋានថ្មី ។ ការងារនេះបង្កើននូវសារៈសំខាន់របស់ MAG ផ្នែកសកម្មភាពមីនមនុស្សធម៌សំរាប់អ្នកទទួលផលរបស់គំរោងនេះ ។ MATs អាចពង្រាយ ទៅសំអាតដីឡូត៍តូចៗសំរាប់កសិកម្ម ដើម្បីធ្វើអោយប្រសើរឡើងនូវសុវត្ថិភាពស្បៀងតាមសហគមន៍ ។ ក្រុមអប់រំបញ្ហាមីនទាំងអស់របស់អង្គការ MAG ត្រូវផ្លូវទៅជាក្រុម MATs វិញបច្ចុប្បន្ននេះ ។

<u>ស្ថិតិបោសសំអាតមីនរបស់អង្គការ MAG</u> :

| ខេត្ត | ស្រុក | ផ្ទៃដីបោសសំអាតរួច (គ.ម$^{២}$) | មីនប្រឆាំងមនុស្ស | មីនប្រឆាំងរថក្រោះ | គ្រាប់មិនទាន់ផ្ទុះ |
|---|---|---|---|---|---|
| បាត់ដំបង | បវិល/កំរៀង/សំឡូត/បាណន់ | ៥៣០,៤០៥ | ១,១១៥ | ៨ | ៨១៦ |
| ពោធិសាត់ | | ៣៧,៤៥១ | ៣៨៤ | 0 | ៩៧ |
| កំពង់ធំ | | ៩៧,២៥៦ | ៤0 | 0 | ១៣៦ |
| ព្រះវិហារ | ររៀង / គូលែន | ៥៤,៩៧១ | ៣៧ | 0 | ២២២ |
| កំពង់ស្ពឺ | | ៨៥,១៦៨ | ២៥ | 0 | ៥0 |
| ក្រុមកំទេចគ្រឿងផ្ទុះបាត់ដំបង | | | ១,៤៨0 | ២៤ | ៥,៦៩១ |
| ក្រុមកំទេចគ្រឿងផ្ទុះកំពង់ធំ | | | ៥៧ | 0 | ១,៧៨២ |
| **សរុប** | | **៨0៥,២៥២** | **៣,១៣៨** | **៣២** | **៧,៤៩៤** |

[57] Mines Advisory Group-Cambodia Brief, p.2, 23 February 2001, Phnom Penh, Cambodia.

## កងយោធពលខេមរភូមិន្ទ (RCAF)

តាំងពីឆ្នាំ១៩៩៤មកម្ល៉េះ កងវិស្វកម្មទាហាននៃកងយោធពលខេមរភូមិន្ទបានចូលរួមក្នុងការដោះមីន (និងកំទេចគ្រាប់ដែលទំលាក់ពីយន្តហោះមិនទាន់ផ្ទុះ) ។ ការរួមចំណែករបស់គេបានកាត់បន្ថយការគំរាមកំហែងដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះបានមួយភាគធំ ។ ការសំអាតផ្លូវធំថ្មីៗនេះដោយកងទ័ព ដូចជាផ្លូវក្នុងស្រុកវាលវែងក្នុងខេត្តពោធិសាត់ គឺជាតំបន់មួយដែលក្រុមដោះមីនឯទៀតបដិសេធមិនចូលទៅធ្វើការ ពីព្រោះតែការខ្វះការផ្គត់ផ្គង់គ្រឿងបរិក្ខារថ្នាំពេទ្យ [58] ។

កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០០១ លោកវរសេនីយឯក ទួន គង់ បានផ្តល់ទិន្នន័យដល់ក្រុមត្រួតពិនិត្យគ្រាប់មីន ។ ការបោសសំអាតមីនក្នុងឆ្នាំ២០០០របស់គេ គឺ ធ្វើឡើងនៅខេត្តកំពត ខេត្តពោធិសាត់ និងតាមបណ្តោយផ្លូវជាតិលេខ១ពីខេត្តកណ្តាលទៅព្រៃវែង ។ ការសំអាតមីនភាគច្រើន គឺ ធ្វើឡើងនៅលើដីផ្តល់ និង ទីតាំងខ្សែកាប ។ កងយោធពលខេមរភូមិន្ទក៏បានត្រួតពិនិត្យមើល និង ដោះមីនមុន ឬ ពេលដែលថ្នាក់ដឹកនាំប្រទេសកម្ពុជាចុះទៅទស្សនកិច្ចតាមបណ្តាខេត្តនានាផងដែរ ។ លោកវរសេនីយឯក ទួន គង់ បានថ្លែងថារាល់សកម្មភាពដោះមីនរបស់កងយោធពលខេមរភូមិន្ទក្នុងឆ្នាំ២០០១ ត្រូវបានធ្វើឡើងទៅតាមខ្នាតគំរូរបស់អង្គការសហប្រជាជាតិ [59] ។

ទិន្នន័យនៃការបោសសំអាតមីនរបស់កងយោធពលខេមរភូមិន្ទពីឆ្នាំ១៩៩៤ ដល់ ឆ្នាំ២០០០ [60] :

| ឆ្នាំ | ផ្ទៃដីដោះមីនរួច ($ម^2$) | មីនប្រឆាំងមនុស្ស | មីនប្រឆាំងរថក្រោះ | មីនថ្មៃ | គ្រាប់មិនទាន់ផ្ទុះ |
|---|---|---|---|---|---|
| ១៩៩៤ | ១,៦៦៨,៣៩១ | ១៣,៩៧០ | ៣៦២ | 0 | 0 |
| ១៩៩៥ | ២,៩៧៦,១៤៨ | ៥,០៩៣ | ៥៦០ | 0 | 0 |
| ១៩៩៦ | ៤,៩៧២,៥០០ | ៣៤,៩០៧ | ១,៦០៥ | ១១,៣២៥ | 0 |
| ១៩៩៧ | ១,៦៧៤,០០០ | ៦,១៥១ | ៩២៧ | ៧,៣០៧ | 0 |
| ១៩៩៨ | ៣,០៤០,០០០ | ១១,៩១០ | ១៣១ | ៤,៣៩២ | 0 |
| ១៩៩៩ | ២,៤៣២,០០០ | ៧,០៨០ | ៣,៥៨៧ | ២៣,០២៤ | ១១,៧២៩ |
| ២០០០ | ២០,០១១,០០០ | ១,០៧៨ | ១៨៦ | ៩០ | ៦,២៩០ |
| **សរុប** | **៣៦,៣២៩,០៣៩** | **៨០,១៤៩** | **៧,៣៥៨** | **៤៦,១៣៨** | **១៨,០១៩** |

[58] UNICEF External Evaluation of Supported mine action projects June/July 2000, p. 15, Cambodia.
[59] Interview Col. Tuon Kon, JRS office, 25 April 2001, Phnom Penh, Cambodia.
[60] Statistics from Col. Tuon Kon, Chief of de-mining office, 25 April 2001, Phnom Penh, Cambodia.

ទិន្នន័យនៃការបោសសំអាតមីនរបស់កងយោធពលខេមរភូមិន្ទពីខែមករា២០០១ដល់ខែមេសា២០០១ [61]:

| ខែ | ទីតាំង | ផ្ទៃដីដោះមីនរួច (ម²) | មីនប្រឆាំងមនុស្ស | មីនប្រឆាំងរថក្រោះ | គ្រាប់មីនទាន់ផ្ទុះ | ផ្សេងៗ |
|---|---|---|---|---|---|---|
| មករា | RN5B + RN56<br>RN7A+Taken | ៤៣៩,៨២៥.៣ | ៦៩ | ១ | ១៣៧ | បោសសំអាតសំ-រាប់ធ្វើផ្លូវឡើងវិញ |
| កុម្ភៈ | RN56 + RN5<br>RN7+69B+Taken | ១,៦០៨,៧០៩.៣ | ២៨១ | | ២៩២ | –//– |
| មីនា | RN56 + 69B<br>RN5 + RN7 | ៦៩៤,៨៦៣.១៦ | ៥០២ | | ៥៨៨ | –//– |
| មេសា | RN56 | ១,១៦៣,៣០០ | ២៧១ | | ៩០២ | –//– |
| សរុប | | ៣,៩០៦,៦៩៧.៧៦ | ១,១២៣ | ១ | ១,៩១៩ | |

គ្រាប់មីនដែលទាហានរកឃើញគឺជាគ្រាប់មីនមកពីប្រទេសចិន សូវៀត និង វៀតណាម ។

## ការដោះមីនដោយអ្នកភូមិ (Village Demining)

ការបន្តដោះមីនដោយអ្នកភូមិភាគច្រើននៅកន្លែងដែលមានគ្រាប់មីនច្រើន ។ ទោះជាយ៉ាងណាក៏គ្មានស្ថិតិពិតប្រាកដពីចំនួនដីដែលគេដោះបាននោះដែរ ។

ករណីពិសេសមួយត្រូវបានលើកឡើងកាលពីខែកុម្ភៈ ឆ្នាំ២០០១ គឺការដោះមីនដោយក្រុមដោះមីនជាអ្នកភូមិមួយក្រុមដែលមានគ្នា៧៦នាក់ ។ កងអនុសេនាតូច នេះត្រូវបានគេសុំអោយដោះមីនលើដីមួយកន្លែងក្នុងតំបន់ប៉ៃលិនសំរាប់កសាងភូមិក្នុងពេលអនាគត បន្ទាប់ពីអ្នកភូមិប្រឈមមុខនឹងការបណ្តេញពួកគេចេញពីភូមិ ។ ការដោះមីនដោយខ្លួនឯងបានកើតមានជាយូរយារមកហើយក្នុងប្រទេសកម្ពុជា ។ នៅឯកិច្ចប្រជុំរបស់អាជ្ញាធរមីនកម្ពុជាកាលពីខែកុម្ភៈ គំនិតនៃការពិចារណាសាជាថ្មីអំពីជំហរជាផ្លូវការសំរាប់ដោះមីនដីភូមិត្រូវបានគេស្នើឡើង (បញ្ហាពីរដែលចូលមកពាក់ព័ន្ធគឺកម្មសិទ្ធិដីធ្លីហើយនិង អ្នកណាទៅត្រូវបានទទួលការអនុញ្ញាតអោយដោះមីន) ។

បទពិសោធន៍បានបង្ហាញពីតំរូវការក្នុងការបង្កើនសមត្ថភាពសហគមន៍អោយដើរតួប្រសើរជាងនេះក្នុងកិច្ចប្រឹងប្រែងផ្នែកសកម្មភាពមីន ។ ការប្រើឆ្កែបោសសំអាតមីនរួមជាមួយការខិតខំរបស់អ្នកភូមិត្រូវបានគេលើកឡើង ។ គណៈកម្មការពិសេសរបស់ CMAA កំពុងលើកឡើងពីបញ្ហាការដោះមីនដោយអ្នកភូមិ ។ សុវត្ថិភាពរបស់អ្នកដោះមីន និង ភ័ស្តុតាងស្តីពីដីធ្លីដែលអាចធានាបានសុវត្ថិភាពក្នុងការប្រើប្រាស់គឺជាគន្លឹះ ។

---

[61] Ibid.

ការត្រួតពិនិត្យគ្រាប់មីនឆ្នាំ១៩៩៩ និង ឆ្នាំ២000 បានបង្ហាញថាគ្រាប់មីនជាច្រើនគឺ អ្នកភូមិជាអ្នកដោះ ហេតុនេះហើយទើបអង្គការជនពិការអន្តរជាតិ (H.I) បានផ្តួចផ្តើមការសិក្សាអំពី ''ការដោះមីនដោយខ្លួនឯង'' នៅប្រទេសកម្ពុជាក្នុងឆ្នាំ២000 ។ លទ្ធផល[62] នៃការស្រាវជ្រាវបានបង្ហាញថាភាគច្រើននៃអ្នកភូមិដែលដោះមីនដោយខ្លួនឯង គឺជាបុរសភេទដែលទទួលបានចំនេះដឹងផ្នែកដោះមីនតាមរយៈបទពិសោធន៍ក្នុងការបង្រៀន ឬ ក៏បទពិសោធន៍ក្នុងជីវិតជាទាហាន ។ ការដោះមីនរបស់ពួកគេធ្វើឡើងដោយសារតំរូវការក្នុងជីវភាព ហើយការបោសសំអាតគ្រាប់មីនក៏ធ្វើឡើងដោយខ្លួនឯងដោយប្រើឧបករណ៍ក្នុងស្រុកដែលអាចរកបាន ។

ហេតុផលមួយចំនួនដទៃទៀតបានបង្ហាញថា សន្ទុះទឹកចិត្តក្នុងការដោះមីនមានរាប់បញ្ចូលទាំងតំរូវការរបស់ប្រជាជនក្នុងការវិលត្រឡប់ទៅកាន់ភូមិចាស់ដែលដីធ្លីនៅមានគ្រាប់មីន និង ការពង្រីកផ្ទៃដីដែលអាចកាន់កាប់បានសំរាប់សង់ផ្ទះនិងបង្កបង្កើនផល រួមនឹងការបោសសំអាតផ្លូវដើរទៅកាន់ប្រភពធនធានរួមទាំងឡាយដែលប្រជាជនគ្មានលទ្ធភាពរង់ចាំអង្គការដោះមីនអោយមកបំពេញតំរូវការរបស់ខ្លួនបាន ហើយនឹងដោយសារអ្នកមានអំណាចរឹបអូសដីធ្លីប្រជាជន ដែលបង្ខំប្រជាជនអោយផ្លាស់ប្តូរទីលំនៅទៅកាន់តំបន់ដែលត្រូវការដោះមីនដើម្បីតាំងភូមិដ្ឋាន ។

ហេតុផលទាំងឡាយដើម្បីបញ្ឈប់ការដោះមីន រួមមាន សុខភាពអន់ថយ ឬ វ័យចំណាស់ ឬ នៅពេលគ្រួសារមានដីធ្លីដែលអាចរកបានគ្រប់គ្រាន់សំរាប់តំរូវការរបស់ខ្លួន ។

ឧបករណ៍ដែលប្រើប្រាស់ជារៀងរាល់ថ្ងៃ គឺ ឧបករណ៍កសិកម្មរួមមានចបកាប់ ចបជីក និង កាំបិត ។ ការប្រើប្រាស់ឧបករណ៍រាវរកមីនធ្វើពីដែកមានកំរិត ដោយយោលទៅលើការចំណាយ ។ ភាគច្រើននៃការដោះមីន គឺ ត្រូវបានធ្វើឡើងនៅរដូវភ្លៀងពីព្រោះដីធូរងាយស្រួលក្នុងការចាក់ និង ជីក ។ ការបោសសំអាតមីនពីដីដោយដៃដីក៏កើតមានផងដែរ ។ គ្រាប់មីនត្រូវបានគេដោះ និង ដុតចោល ឬ ក៏បញ្ជូនទៅអោយអង្គការបោសសំអាតមីន ជាពិសេសបើសិនជាគេមិនធ្លាប់ស្គាល់វា ឬ ក៏យល់ថាគ្រាប់មីនទាំងនោះគ្មានសុវត្ថិភាពក្នុងការដោះ ។ គ្រាប់មិនទាន់ផ្ទុះ ជាទូទៅត្រូវគេបំផ្លាញនៅនឹងកន្លែងដែលគេរកឃើញ បើសិនជាគេចង់ប្រើប្រាស់វា ។ គ្រឿងសព្វាវុធត្រូវគេបញ្ជូនទៅអោយរដ្ឋអំណាចភូមិ ឬ ក៏ប្រគល់អោយអង្គការបោសសំអាតមីននៅពេលណាដែលគេរកឃើញវា ។ ភាគច្រើន នៃអ្នកដោះមីនប្រកាន់យកសុវត្ថិភាពក្នុងការដោះមីន ដោយដោះមីនតែនៅពេលណាដែលគេយល់ថាសមរម្យនឹងដោះកើត ហើយនិង ដោះតែមីនណាដែលគេស្គាល់ច្បាស់ ។ អ្នកស្រុកដែលជាអ្នកដោះមីនជាទូទៅច្រើនដោះនៅតាមផ្លូវទៅកាន់ប្រភពធនធានដែលជាកម្មសិទ្ធិរួម និង បោះផ្លាកសញ្ញាសំគាល់ទុក

[62] H.I. ''Spontaneous Demining Initiatives'' workshop on 18th December 2000, Phnom Penh, Cambodia.

ក្នុងតំបន់មានមីនដើម្បីព្រមានប្រជាជនឯទៀតក្នុងភូមិ ។ ពួកគេកំទេចមីនខាងក្រៅភូមិនៅពេលល្ងាច ដោយព្រមានពីពេលដែលត្រូវធ្វើការកំទេចដល់អ្នកភូមិឯទៀត ។

អ្នកភូមិដែលធ្វើការដោះមីនភាគច្រើនយល់ថា គេងាយទទួលរងគ្រោះដោយជាន់មីនជាងការដោះមីនទៅទៀត ។ ភាគច្រើនពួកគេចង់ឈប់ដោះមីនព្រោះខ្លាចក្រែងត្រូវរបួស ប៉ុន្តែគេយល់ថាគេគ្មានជំរើសឡើយ ។ ក្រុមគ្រួសារអ្នកភូមិដែលដោះមីនតែងបារម្ភពីការប្រថុយប្រថានទាំងនេះ ។ អាជ្ញាធរមានសមត្ថកិច្ចអះអាងថា គេមិនគាំទ្រសកម្មភាពទាំងនេះទេ ប៉ុន្តែគេទទួលស្គាល់ថាអ្នកដោះមីនទាំងនេះបានជួយកាត់បន្ថយការប្រថុយប្រថាននឹងគ្រោះថ្នាក់សំរាប់អ្នកឯទៀត ។ អ្នកភូមិជឿជាក់ថា អ្នកដោះមីនបានកាត់បន្ថយការប្រថុយប្រថាននឹងគ្រោះថ្នាក់ដោយសារមីននៅក្នុងភូមិ ប៉ុន្តែគេនៅតែមិនទាន់ទុកចិត្តថាដីដែលដោះមីនរួចមានសុវត្ថិភាពពិតប្រាកដនោះឡើយ ។ ភូមិខ្លះចង់អោយអង្គការដោះមីនសំអាតផ្ទៃដីភូមិខ្លួនជាង ។ ឯភូមិខ្លះទៀតមិនចង់អោយអង្គការដោះទេ ពីព្រោះខ្លាចថាក្រោយពេលដោះបាន ដីនោះត្រូវប្រគល់ទៅអោយអ្នកផ្សេងទៀតកាន់កាប់ ។

អ្នកស្រុកមានសង្ឃឹមយ៉ាងខ្លាំងទៅលើការដោះមីនដោយអង្គការបោសសំអាតមីន ប៉ុន្តែគេមានបទពិសោធន៍ ពីការពិបាកក្នុងការធ្វើសំណើដោះមីន និង មិនបានទទួលការឆ្លើយតបភ្លាម១តាមសំណូមពរ ។ គេត្រូវរង់ចាំការចាប់ផ្តើមបោសសំអាតមីនយ៉ាងយូរ ហើយអ្នកស្រុកភាគច្រើនអះអាងថាដីកសិកម្មមិនបានត្រូវគេបោសសំអាតឡើយ ។ ដីសំរាប់សង់ផ្ទះជាការល្អហើយ តែគេមិនអាចរស់នៅដោយគ្មានដីកសិកម្មឡើយ ។

## ក្រុមហ៊ុនដោះមីនឯកជន (Private Demining Companies)

យោងទៅតាមឯកឧត្តម សម សុត្ថា ដែលជាអគ្គលេខាធិការនៃអាជ្ញាធរមីនកម្ពុជា (CMAA) ដែលទើបនឹងបង្កើតថ្មី១នេះយល់ថា ក្រុមហ៊ុនឯកជនខាងដោះមីនដែលក្រសួងបានយល់ព្រមអោយដោះមីនជាផ្លូវការនោះនឹងអនុវត្តការងារបោសសំអាតមីននៅព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ២០០១ ។ ឯកឧត្តមបានថ្លែងថា ''ក្រុមហ៊ុនឯកជននឹងដើរតួយ៉ាងថ្លៃថ្លាក្នុងការបោសសំអាតមីនលើផ្ទៃដីដែលពោរពេញទៅដោយគ្រាប់មីន''។ ក្រោយកិច្ចពិភាក្សាជាមួយនឹងរដ្ឋាភិបាលកម្ពុជា CMAC, MAG និង HALO ឯកឧត្តម សម សុត្ថា កំពុងតាក់តែងបទបញ្ញាដើម្បីកំនត់លក្ខណៈវិនិច្ឆ័យសំរាប់ក្រុមហ៊ុនឯកជនក្នុងការចុះអនុវត្ត និង គ្រប់គ្រងការបំពេញការងាររបស់ពួកគេផង ។ ឯកឧត្តម សម សុត្ថា ប្រមើលគិតទុកជាមុនថា ក្រុមហ៊ុនដោះមីនឯកជននឹងបំពេញនូវចន្លោះដែល CMAC ឬ អង្គការមនុស្សធម៌នានាមិនអាចធ្វើបានក្នុងប្រតិបត្តិការបោសសំអាតមីន ដោយចាប់យកកិច្ចសន្យាបោសសំអាតមីនអនុលោមទៅតាមប្រភេទ ទំហំ ឬ ភាពស្មុគ្រស្មាញក្នុងការបោសសំអាតមីន ។ ឯកឧត្តម សម

សុត្ថា បានថ្លែងថា “ កិច្ចសន្យាដោះមីនដោយក្រុមហ៊ុនឯកជននឹងធ្វើឡើងដោយយោលទៅតាមផែនការជាតិរបស់ CMAA” ។ ចំនួនក្រុមហ៊ុននឹងត្រូវអនុញ្ញាតអោយដំណើរការបានអាស្រ័យទៅលើតំរូវការរបស់ជាតិ [63] ។

ក្រុមហ៊ុន Chirgwin Services Group ទទួលបានកិច្ចសន្យាឧបត្ថម្ភថវិកាដោយ AusAID ក្នុងការបំផ្លាញចំការមីនដើម្បីបោសសំអាតគ្រាប់មិនទាន់ផ្ទុះ និង គ្រាប់រំសេវក្នុងបរិវេណដីមជ្ឈមណ្ឌលកុមារកំព្រាភូមិទួលក្រសាំង ពីថ្ងៃទី៤ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០១ [64] ។

ផែនការជាតិប្រាំឆ្នាំរបស់អាជ្ញាធរមីនកម្ពុជាក្នុងការដោះមីន មានកម្មវិធីដែលបានទទួលផលល្អយ៉ាងក្រៃលែង ដើម្បីធ្វើការសំរបសំរួលជាពិសេសដល់ក្រុមហ៊ុនដោះមីនឯកជនសំរាប់ការកសាងផ្លូវថ្នល់ធំៗ ស្ពាន និង ទំនប់ទឹក យោងទៅតាមសំដីអ្នកជំនាញការផ្នែកជំនួញម្នាក់ ។ គាត់បានប៉ាន់ប្រមាណថា ក្នុងកំឡុងពីរឆ្នាំការងារក្រុមហ៊ុនគាត់អាចផ្តល់ការងារដល់អ្នកដោះមីនចំនួនពី ៥០០ ទៅ ៦០០នាក់ ដោយផ្ទាល់ ឬ ក៏តាមរយៈការម៉ៅការតពីគេ [65] ។

## ផែនការការងារ និង ការសំរបសំរួល (Coordination and Planning)

ការសំរបសំរួលផ្នែកសកម្មភាពមីននៅកម្ពុជា ប្រែប្រួលទៅតាមការបង្កើតអាជ្ញាធរមីន និង ការឧបត្ថម្ភជនរងគ្រោះកម្ពុជា (CMAA) ដែលតែងតាំងដោយព្រះរាជក្រឹត្យកាលពី ខែកញ្ញា ឆ្នាំ២០០០ ។ ក្រោមកិច្ចដឹកនាំរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន CMAA នឹងកាន់កាប់មុខការជាច្រើនដែលពីមុនស្ថិតនៅក្រោមឱវាទ CMAC ។

CMAA បំពេញការងារក្នុងនាមរាជរដ្ឋាភិបាល នឹង ធានាបាននូវការសំរបសំរួលផ្នែកសកម្មភាពមីននៅកម្ពុជា ។ ក្នុងឆ្នាំ២០០១ CMAC គឺជាអ្នកផ្តល់សេវាមួយរូបក្នុងរង្វង់កម្មវិធីការងារ និង ស្វ័យភាពរបស់ខ្លួន ប៉ុន្តែការសំរបសំរួលជាមួយក្រុមការងារសកម្មភាពមីនដទៃទៀត គឺ ជាការងាររបស់អង្គភាពជំនាញផ្នែកច្បាប់ដែលរៀបចំថ្មី ។ ការចេញក្រឹត្យច្បាប់របស់រាជរដ្ឋាភិបាលក្នុងការបង្កើត CMAA គឺធ្វើឡើងក្រោយពីមានកិច្ចប្រជុំពិភាក្សាជាបន្តបន្ទាប់ក្នុងសិក្ខាសាលារបស់ក្រុមពាក់ព័ន្ធនឹងសកម្មភាពមីនផ្សេងៗ និង ក្នុងឱកាសសន្និសីទជាតិនៃអ្នកជំនាញការសកម្មភាពមីនដែលចូលរួមដោយម្ចាស់អំណោយ បុគ្គលិករដ្ឋាភិបាល និង អង្គភាពពាក់ព័ន្ធនានា ។

កិច្ចប្រជុំជាបន្តបន្ទាប់ដើម្បីកំនត់មុខងាររបស់ CMAA បានដាក់ចេញនូវរូបមន្តផ្នែកសំរបសំរួលយ៉ាងជាក់លាក់របស់អនុក្រឹត្យស្តីពីអង្គការ និង ដំណើរការអនុវត្តរបស់អាជ្ញាធរមីនកម្ពុជា ។ CMAA ចាត់តាំងឡើងដោយ

[63] Phnom Penh Post newspaper, page 7, Issue February 2-15, 2001.
[64] Ibid. p. 7
[65] Phnom Penh Post newspaper, page 7,Issue February 2-15, 2001.

រាជរដ្ឋាភិបាលកម្ពុជាអោយត្រួតពិនិត្យនូវរាល់សកម្មភាពមីនក្នុងព្រះរាជាណាចក្រកម្ពុជា ។ CMAA ត្រូវតែធានាអោយបានបរិស្ថានដ៏ជាទីពេញចិត្តសំរាប់ការបំពេញការងារ និង ការអភិវឌ្ឍន៍សកម្មភាពមីនកម្ពុជា ។ CMAA នឹងមិនលំអៀងក្នុងការប្រើប្រាស់ថវិការបស់ម្ចាស់អំណោយអោយមានប្រសិទ្ធិភាព និង តម្លាភាព ការប្រើប្រាស់ដីធ្លីដោះមីនរួច និង ធានាអោយបានការសំរបសំរួលដ៏មានប្រសិទ្ធិភាពជាមួយបណ្តាក្រុមប្រតិបត្តិការ និង ដៃគូសកម្មភាពមីនទាំងអស់ ។

CMAA ទទួលខុសត្រូវក្នុងការបង្កើតគំរូបច្ចេកទេស ទំរង់ការ ថវិកា និង បទបញ្ញតិដែលទាក់ទងទៅនឹងផែនការសកម្មភាពមីន និង ការគ្រប់គ្រងពត៏មានបច្ចេកទេសរៀបចំផែនការជាតិសំរាប់សកម្មភាពមីន សំរបសំរួលរាល់សកម្មភាពមីន តាមដាន និង ត្រួតពិនិត្យសកម្មភាពមីន ដើម្បីអោយក្រុមប្រតិបត្តិការជាតិ និង អន្តរជាតិប្រព្រឹត្តតាមយុទ្ធសាស្ត្រ និង ផែនការរបស់រាជរដ្ឋាភិបាល បញ្ចុះបញ្ចូលដើម្បីទទួលបានការគាំទ្រផ្នែកបច្ចេកទេស និង ថវិកាក្នុងប្រទេសកម្ពុជា និង ក្រៅប្រទេស បញ្ជាអោយកំទេចគ្រាប់មីនប្រឆាំងមនុស្ស គ្រាប់មីនប្រឆាំងរថក្រោះ និង គ្រឿងផ្ទុះគ្រប់ប្រភេទដទៃទៀតទាំងអស់ដែលមិនបានកាន់កាប់ ឬ ក៏កំពុងប្រើប្រាស់ដោយមន្ត្រីអាជ្ញាធរ និង ផ្តល់ កែសំរួល និង ដកហូតមកវិញនូវលិខិតតែងតាំង និង លិខិតអនុញ្ញាតិពីអង្គការជាតិ និង អន្តរជាតិដែលធ្វើការផ្នែកសកម្មភាពមីននៅក្នុងព្រះរាជាណាចក្រកម្ពុជា គ្រប់គ្រងកម្មវិធីផ្នែកសំរង់ស្ថិតិ និងប្រព័ន្ធផ្តល់ពត៏មានដទៃទៀត សំរបសំរួលជាមួយម្ចាស់ជំនួយ អង្គការអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ អង្គភាពរដ្ឋាភិបាល (ក្រសួងមន្ទីរ និង អាជ្ញាធរដែលពាក់ព័ន្ធ) ក្រុមហ៊ុនឯកជន ដើម្បីធានាអោយបានថា ការជឿនលឿនផ្នែកការងារ/ផែនការក្នុងប្រទេសកម្ពុជា ដែលកំពុងដំណើរការ បានធានាសុវត្ថិភាព បរិស្ថានក៏រិតខ្ពស់បំផុត សំរបសំរួលជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ និង អង្គភាពរដ្ឋាភិបាលដែលពាក់ព័ន្ធ ក្នុងការរៀបចំ និង ត្រួតពិនិត្យគោលនយោបាយ និង គោលការណ៍ណែនាំ ផ្នែកការគ្រប់គ្រងដីធ្លីដែលបោសសំអាតមីនរួច គ្រប់គ្រងការអនុវត្តច្បាប់ស្តីពីការហាមប្រាមក្នុងការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស និង សន្ធិសញ្ញាលុបបំបាត់មីន (អនុសញ្ញាអុតតាវ៉ា) ស្តីពីការហាមប្រាមការប្រើប្រាស់ ការស្តុកទុក ការផលិត និង ការដឹកជញ្ជូនគ្រាប់មីនប្រឆាំងមនុស្ស និង ការកំទេចគ្រាប់មីនទាំងនោះ ។

ព្រះរាជក្រឹត្យបង្កើតអាជ្ញាធរមីន (CMAA) មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ១ ។

អ្នកធ្វើសកម្មភាពមីនទាំងអស់យល់ព្រមគ្នាថា ការសំរបសំរួលគឺជាការងារចាំបាច់សំរាប់វិស័យសកម្មភាពមីន ដើម្បីអោយកិច្ចប្រឹងប្រែងក្នុងវិស័យនេះដែលកំពុងតែដំណើរការជាបន្តបន្ទាប់បានទទួលផលច្រើនបំផុត និង ដើម្បីបញ្ចូលសកម្មភាពមីនទៅក្នុងកម្មវិធីអភិវឌ្ឍន៍របស់ប្រទេស ។

ការសំរបសំរួលធ្វើឡើងដោយ អាជ្ញាធរមីននឹងធានាបានតាមរយៈយន្តការដោយឡែកពីគ្នា [66] :

- គណៈកម្មាធិការកម្ពុជាសំរបសំរួលការបោសសំអាតមីន (CDCC) ដែលជាទូទៅធ្វើការជួបប្រជុំជាទៀងរាល់ខែរវាងក្រុមពាក់ព័ន្ធផ្នែកសកម្មភាពមីន (ក្រុមប្រតិបត្តិការបោសសំអាតមីន អង្គការសកម្មភាពមីន អង្គការស្តារ និង អភិវឌ្ឍន៍ម្ចាស់ជំនួយ ។ល។) ។ CDCC ដឹកនាំដោយ CMAA ។

- ក្រុមប្រឹក្សាបច្ចេកទេស(TAB)ជាទូទៅប្រជុំបច្ចេកទេសរាល់ខែ ដើម្បីលើកឡើងពីបញ្ហាបច្ចេកទេស ។ អ្នកចូលរួមប្រជុំរួមមានក្រុមប្រតិបត្តិការបោសសំអាតមីន និង អង្គការនានាដែលសកម្ម និង អនុវត្តពិតប្រាកដជាក់ស្តែងផ្ទាល់នៅមូលដ្ឋាន ។

- ក្រុមពិគ្រោះយោបល់ (CG)ដែលមានដំណើរការសំរបសំរួលប្រចាំឆ្នាំ ក្នុងការតាក់តែង និង បញ្ចប់ផែនការសកម្មភាពមីនថ្នាក់ជាតិ ក្រោមកិច្ចសហការជាមួយក្រសួងពាក់ព័ន្ធ អ្នកតំណាងម្ចាស់ជំនួយនានា និង បណ្តាអង្គការជាតិ និង អន្តរជាតិដែលពាក់ព័ន្ធក្នុងសកម្មភាពមីន ។

- យន្តការផែនការថ្នាក់ខេត្ត ដើម្បីតាក់តែងផែនការសកម្មភាពមីនថ្នាក់ខេត្ត (LUPU/LUMU) រវាងអាជ្ញាធរខេត្ត ក្រុមប្រតិបត្តិការសកម្មភាពមីន និង អង្គការស្តារនិងអភិវឌ្ឍន៍ ។

- កិច្ចប្រជុំម្ចាស់ជំនួយសកម្មភាពមីន(MADM) ដែលធ្វើការប្រជុំជាទៀងទាត់ ចាត់ចែង កោះប្រជុំ និង ដឹកនាំដោយ CMAA ។ កិច្ចប្រជុំនេះនឹងត្រូវប្រើធ្វើជាវេទិកាពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា និង សហគមន៍ម្ចាស់ជំនួយ ។

- កិច្ចប្រជុំពិសេសដោយឡែកអាចធ្វើឡើងបានក្នុងចំណោមដៃគូសកម្មភាពមីនស្តីពី បញ្ហាពិសេសទាំងឡាយ (ការអប់រំបំផុសការយល់ដឹងពីគ្រោះថ្នាក់ដោយសារមីន កាស្រង់ស្ថិតិ អ្នករងគ្រោះដោយសារមីន ។ល។)

## <u>ការគ្រប់គ្រង និង ប្រើប្រាស់ដីធ្លី</u> (Land Use Management)

ការស្រាវជ្រាវស្តីពីដីធ្លីដែលដោះមីនរួចដោយ CMAC ក្នុងខេត្តទាំងបីដែលរងគ្រោះដោយសារមីនធ្ងន់ធ្ងរជាងគេនៃប្រទេសកម្ពុជា ត្រូវបានដំណើរការដោយក្រុមអ្នករៀបចំឯកសារត្រួតពិនិត្យគ្រាប់មីន ឆ្នាំ២០០១ (Landmine Monitor 2001) ក្នុងចន្លោះខែវិច្ឆិកា ឆ្នាំ២០០០ ដល់ ខែមករា ឆ្នាំ២០០១ [67] ។

---

[66] Cambodian Mine Action Standards (CMAS) -VERSION DRAFT 01, p. 6, February 2001, Cambodia.

[67] Emma Leslie and Soth Ngarm "Land Study: three provinces on Mine Affected Communities", p. 3, November 2000 - February 2001, Phnom Penh, Cambodia.

ដោយពិចារណាសព្វគ្រប់ទៅ ដីធ្លីដែលដោះមីនរួចត្រូវបានប្រគល់ជូនអ្នកដែលមានតំរូវការខ្លាំងជាងគេគឺ មានប្រជាជនក្រីក្រគ្មានដីធ្លី ជនមាតុភូមិនិវត្តន៍ និង ជនភៀសសឹក ។ ក្រៅពីប្រជាជនគ្មានដីធ្លី ប្រជាជនជាច្រើនគ្រួសារទៀតដែលបានកាន់កាប់ដីមីន ក៏គេទទួលបានផលប្រយោជន៍យ៉ាងធំពីការបោសសំអាតមីនចេញពីដីរបស់ពួកគេដែរ ។ ការបោសសំអាត និង ការចែកចាយដីមីនទាំងនេះបានរួមវិភាគទានយ៉ាងមានតំលៃ ក្នុងន័យបង្កើនសុវត្ថិភាព និង លទ្ធភាពជូនប្រជាជនធ្វើការបង្កបង្កើនផលដើម្បីធានាសុវត្ថិភាពស្បៀងរបស់ពួកគេ[68] ។

ទោះបីជាយ៉ាងនេះក្តី ភាគច្រើននៃការចែកចាយ និងការគ្រប់គ្រងដីបោសសំអាតមីនទាំងនេះមិនទាន់បានគ្រប់គ្រាន់ដើម្បីទំលាយរង្វង់ភាពក្រីក្រចេញពីភូមិស្រុកទាំងអស់នោះឡើយ ហើយមានតែតំបន់ដែលអង្គការក្រៅរដ្ឋាភិបាលមានកម្មវិធីការងារផ្សេងៗប៉ុណ្ណោះទេដែលភាពខុសគ្នាពិតប្រាកដអាចមើលឃើញបាន ។ ទឹកជន់ ភាព-ឯកោ ការខ្វះច្រកចូលទៅកាន់ទីផ្សារ កំរិតជំនាញនៅទាប និង ការខ្វះប្រភពធនធានទាំងនេះ ជួយបង្កើតបញ្ហាទាំងស្រុងដែលប្រជាជនកំពុងរស់នៅក្នុងអតីតតំបន់មីនបានជួបប្រទះ [69] ។

បញ្ហាខ្លះនៅតែកើតមានក្នុងវិស័យបោសសំអាតមីន និង ការចែកចាយដីធ្លីក្នុងប្រទេសកម្ពុជា ។ បញ្ហាទាំងនោះកើតមាននៅក្នុងតំបន់ណាដែលមានអំពើពុករលួយដោយអាជ្ញាធរឃុំ និង ស្រុកកាន់កាប់ច្បាប់ក្នុងកណ្តាប់ដៃ ហើយលក់ដីអោយអ្នកតាំងលំនៅ ឬ ក៏កាន់កាប់ដីខ្លួនឯងផ្ទាល់តែម្តង ។ ក្នុងករណីខ្លះ ពួកគេប្រើការគំរាមកំហែង ឬ ក៏ប្រើពួកសេនាជនមូលដ្ឋានធ្វើជាខ្នងគាំទ្រសកម្មភាពពួកគេ ។ ក្នុងករណីទាំងអស់នេះ ការរឹបអូសដីដោយអយុត្តិធម៌ខុសច្បាប់ គឺ កើតមានឡើងក្រោយពេលដែលអង្គការដោះមីនជាធម្មតា គឺ មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) បានប្រគល់ដីធ្លីដែលដោះមីនរួចទាំងស្រុងជូនរដ្ឋអំណាចមូលដ្ឋាន[70] ។

នៅពេលដែលគ្មានភស្តុតាងប្រាកដប្រជា វត្តមានរបស់អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ឬ អង្គការក្នុងស្រុកដ៏សំខាន់ណាមួយក្នុងបណ្តាភូមិដែលកំពុងធ្វើការបោសសំអាតមីន ពិតជារួមចំណែកយ៉ាងសំខាន់ដល់ការចែកចាយដីធ្លីដ៏ត្រឹមត្រូវ [71]។

តាមការអះអាងរបស់អ្នកសិក្សាស្រាវជ្រាវទាំងឡាយ ការយល់ដឹងមួយដ៏សំខាន់គួរតែកត់សំគាល់ ។ ក្នុងករណីខ្លះៗ ដីធ្លីមួយដុំតូចប្រមាណពីរ ឬ បីហិកតាប៉ុណ្ណោះ ត្រូវបានគេបោសសំអាត ប៉ុន្តែការងារដ៏មានសារៈសំខាន់នេះមិនអាចវាស់វែងបាន ព្រោះដីធ្លីមួយដុំតូចនេះអាចអោយគេចូលទៅដល់អាគារសិក្សា និង សាសនា និង

[68] Ibid. p.3
[69] Emma Leslie and Soth Ngarm "Land Study: three provinces on Mine Affected Communities", p. 3, November 2000 - February 2001, Phnom Penh, Cambodia.
[70] Ibid. p.3
[71] Ibid. p.3

ស្ថាប័ននានាបាន ។ នេះសរអោយឃើញថា យុទ្ធសាស្ត្រក្នុងការដោះមីនសំខាន់ណាស់ ។ អ្វីដែលគួរជាទីពេញចិត្ត គឺ មិនស្ថិតនៅត្រង់ការដោះមីនតំបន់ធំៗក្នុងក្តីសង្ឃឹមថា ប្រទេសកម្ពុជានឹងអស់មីនពីផ្ទៃដីនៅថ្ងៃណាមួយនោះទេ ។ អ្វីដែលពិតជាសំខាន់ណាស់នោះ គឺ អាទិភាពនៃការងារដោះមីនដើម្បីអោយសហគមន៍អាចទទួលបានផលប្រយោជន៍កំរិតខ្ពស់បំផុតពីការងារដែលបានបំពេញនោះ [72] ។ របាយការណ៍ទាំងស្រុងអាចរកបាននៅក្នុងឯកសារត្រួតពិនិត្យមីនកម្ពុជា ។

លោក Neil Hawkins ធ្វើការនៅអង្គការ Care International តំណាលពីជោគជ័យនៃគំរោងការតាំងលំនៅដ្ឋាននៅក្នុងខេត្តបាត់ដំបងដោយថ្លែងថា "*អង្គការ Care International ជឿជាក់យ៉ាងខ្លាំងថាបញ្ហាមីននៅប្រទេសកម្ពុជាមិនអាចកាត់ផ្តាច់ចេញពីភាពក្រីក្របានទេ ។ ការងារបោសសំអាតមីន គឺ គ្រាន់តែជាជំហានមួយនៃដំណើរការតាំងលំនៅដ្ឋានប៉ុណ្ណោះ ហើយត្រូវតែរួមដៃគ្នាធានានូវសុវត្ថិភាពនៃការកាន់កាប់ដីធ្លី និង មានវិធានការត្រៀមជួយអ្នកតាំងលំនៅអោយធានាបានការចិញ្ចឹមជីវិតដោយខ្លួនឯង ។ អង្គការ Care International ក៏គាំទ្រផងដែរនូវគំរូវការផ្នែកសមត្ថភាពក្នុងការដោះមីនអោយមានប្រសិទ្ធិភាពថ្នាក់ជាតិ ។ តាមរយៈភាពជាដៃគូរវាង CARE, CMAC និង WFP យើងអាចដោះមីនបានផ្ទៃដី ៦០ហិកតា និង តាំងលំនៅជាថ្មីជូនប្រជាជនបាន៧១៥គ្រួសារ នៅស្រុកបវិល ខេត្តបាត់ដំបង ។ កិច្ចសហប្រតិបត្តិការរវាងដៃគូទាំងអស់មានដំណើរការល្អប្រពៃជាទីបំផុត និង មានផលប៉ះពាល់ជាវិជ្ជមានរយៈពេលវែងទៅលើការរស់នៅរបស់ប្រជាជនជាង ៣,៥០០នាក់ ។ អង្គការ CMAC បានដើរតួយ៉ាងសំខាន់ក្នុងជោគជ័យនៃកម្មវិធីតាំងលំនៅដ្ឋាន ហើយអង្គការ CARE ក៏ប្តេជ្ញាបន្តការងារស្អិតរមួតជាមួយ CMAC ក្នុងការដោះមីនថែមទៀតសំរាប់តាំងលំនៅដ្ឋាន*" ។

គំនិតជាអាទិភាពដែល CMAC បានគូសវាសពាក់ព័ន្ធទៅនឹងការចូលរួមរបស់សហគមន៍ ។ អង្គការ CMAC ជាអ្នកដោះមីនពីដីសំរាប់សហគមន៍ប្រើប្រាស់ ហើយសហគមន៍ជាអ្នកកំនត់អាទិភាព ។ ការងារនេះសំរេចបានតាមរយៈការអនុវត្តដំនើរការ និង ទំរង់ការ LUPU / LUMU [73] ។

"អ្វីដែលប្រព័ន្ធការងារនេះសំរេចបាននោះ គឺការធានាបាននិរន្តរ៍ភាពនៃការប្រើប្រាស់ដីធ្លីបោសសំអាតមីនដែលគេចង់បាន ។ តាមរយៈការកំនត់អត្តសញ្ញាណនៃអ្នកទទួលផល និង អង្គការអភិវឌ្ឍន៍ទាំងឡាយទុកជាមុនមុនពេលដោះមីន ឬ ក៏ពេលផ្តើមដោះមីន យើងទទួលបានជោគជ័យក្នុងការកាត់បន្ថយបញ្ហាជំលោះដីធ្លី និង បាន

[72] Ibid. p.3
[73] CMAC's INTEGRATED WORKPLAN 2001, p. 19,15 November 2000, Phnom Penh, Cambodia.

ការទទួលស្គាល់ពីរាជរដ្ឋាភិបាល និង អង្គការម្ចាស់ជំនួយនានា ព្រមទាំងសំរេចបានផលប្រយោជន៍ផ្នែកសង្គមកិច្ច និង សេដ្ឋកិច្ចដ៏ខ្ពស់បំផុត [74]'' ។

NPA (ជាអង្គការជំនួយរបស់ប្រជាជនន័រវែស្ស) នឹងគាំទ្រតំបន់ដោះមីនចំនួន១៣កន្លែង នៅក្នុងខេត្តបន្ទាយមានជ័យ ។ អង្គការដទៃទៀតដែលកំពុងដំណើរការគំរោងការគាំទ្រក្នុងតំបន់ដោះមីនទាំងនោះ រួមមាន MSF , UNDP, Jesuit Service, ZOA , PRD (មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ) និង EU ។

អង្គការ H.I (ជនពិការអន្តរជាតិ)ដែលឧបត្ថម្ភថវិកាដោយរដ្ឋាភិបាលប្រទេសអូស្ត្រាលីក្នុងឆ្នាំ២០០០នេះបានប៉ាន់ប្រមាណការងាររបស់ LUPU និង LUMU និងបានព្យាយាមពិពណ៌នាពីដំណើរការកម្មវិធី និង បទពិសោធន៍រហូតមកដល់ពេលនេះ ។ ជាទូទៅអង្គការអភិវឌ្ឍន៍ និង អង្គការដោះមីននានាផ្តល់យោបល់ថាដំណើរការ LUPU/LUMU មានសក្តានុពល នឹងត្រូវតែបានអនុវត្តនៅតាមបណ្តាខេត្តថ្មីៗថែមទៀតក្នុង ឆ្នាំ២០០១ ។

អង្គការនានាដែលពាក់ព័ន្ធក្នុងគំរោងការអភិវឌ្ឍន៍នៃតំបន់មានមីនត្រូវបានរាយឈ្មោះក្នុងបញ្ជីឯកសារត្រួតពិនិត្យមីនដោយអ្នកភូមិរួមមាន World Vision, CARE, Jesuit Service, ZAO, UNDP/SEILA, NPA, មេត្តាករុណា, LWS និង CWS [75] ។

## ការបំផុសការយល់ដឹងពីមីន (Mine Awareness)

កម្មវិធីបំផុសការយល់ដឹងពីមីននៅក្នុងប្រទេសកម្ពុជា តំរូវអោយលើកឡើងពីបញ្ហាមីន រួមនឹង បញ្ហាគ្រាប់មិនទាន់ផ្ទុះផងដែរ ។ កិច្ចប្រឹងប្រែងពីមុនទាំងប៉ុន្មានច្រើនផ្តោតទៅលើការបង្រៀនសហគមន៍រងគ្រោះដោយសារមីនពីការស្គាល់គ្រឿងផ្ទុះបច្ចុប្បន្នទាំងឡាយ ។ កិច្ចប្រឹងប្រែងថ្មីៗបន្ថែមទៀតបានផ្តោតទៅលើការអប់រំប្រជាជនអោយស្គាល់តំបន់មីន មានលទ្ធភាពស្គាល់តំបន់ដែលអាចកើតមានគ្រោះថ្នាក់ដោយសារមីន និង អប់រំសហគមន៍មានមីន អំពីយុទ្ធសាស្ត្រដើម្បីរស់នៅក្បែរតំបន់ដែលមានគ្រោះថ្នាក់ ។ យន្តការទាំងឡាយត្រូវបានប្រគល់អោយប្លែកៗពីគ្នា ហើយបច្ចុប្បន្ននេះគឺមានការសាកសួរពត៌មានពីក្រុមចល័តក្នុងសហគមន៍មានមីន ការបង្កើតទីប្រឹក្សា និង គ្រូបង្វឹកនានាក្នុងសហគមន៍ យុទ្ធនាការផ្សព្វផ្សាយពត៌មានក្នុងស្រទាប់ប្រជាជន និង ការផ្តល់ការបំផុសការយល់ដឹងអំពីមីនតាមសាលារៀន ។ ដោយសារតែការបោសសំអាតមីន/គ្រាប់មិនទាន់ផ្ទុះជាផ្នែកមួយនៃសកម្មភាពមីន ដូចនេះទំរង់ខ្លះនៃការបំផុសការយល់ដឹងពីមីន/ការអប់រំត្រូវតែបន្តទៅអនាគតដើម្បីបំពេញតំរូវការក្នុងសកម្មភាពបោសសំអាតមីន [76] ។

---

[74] Oun Sang Onn: " One Year of Experience of LUPU/LUMU" p. 5, September 2000, Phnom Penh, Cambodia.
[75] Reports to Land Mine Monitor Battambang, Banteay Meanchey, Oddar Meanchey, Siem Reap, Kompong Thom, December, January, February 2001, Cambodia.
[76] Bullpitt Ian: p.52

បច្ចុប្បន្ននេះចំនួនប្រជាជនស៊ីវិលដែលរងគ្រោះដោយសារមីនមានពី ៥០នាក់ ទៅ ៩០នាក់ ក្នុងមួយខែ ។ អ្នកដែលរងគ្រោះញឹកញាប់ជាងគេដោយសារមីន/គ្រាប់មិនទាន់ផ្ទុះ គឺ បុរស ៦៣% ក្មេង៣១% និង ស្ត្រី៦% ។ គ្រាប់មីនបង្កគ្រោះថ្នាក់៥៥% ហើយគ្រាប់មិនទាន់ផ្ទុះវិញ៤៥% ។ កម្មវិធីបំផុសការយល់ដឹងពីមីនទៅថ្ងៃមុខត្រូវលើកឡើងពីបញ្ហាមីន និង គ្រាប់មិនទាន់ផ្ទុះព្រមគ្នា ព្រមទាំងត្រូវផ្តល់យន្តការ និង បច្ចេកទេសគ្រប់គ្រាន់អោយបានដល់ក្រុមដែលទទួលគ្រោះថ្នាក់ញឹកញាប់ជាងគេ (បុរសពេញវ័យ)[77] ។

ការផ្តោតចំនុចគោលដៅនៅលើកម្មវិធីបំផុសការយល់ដឹងអំពីមីនទាំងឡាយគឺ ជាដំណោះស្រាយមួយបែបថ្មីសំរាប់ការធ្វើការបំផុសការយល់ដឹងពីមីននៅប្រទេសកម្ពុជា ។ ការចូលរួមយ៉ាងសមរម្យរបស់អ្នកភូមិក្នុងការផ្តល់ពត៌មានជូនដល់ក្រុមដាក់ផ្លាកសញ្ញាមីនសហគមន៍ ក្រុមកំទេចគ្រឿងផ្ទុះ ក្រុមបោសសំអាតមីន និង ក្រុមអភិវឌ្ឍន៍សហគមន៍ គឺ ជាគន្លឹះនៃដំណោះស្រាយនេះ ។

នៅឆ្នាំ២000 អង្គការ CMAC មានក្រុមបំផុសការយល់ដឹងពីមីន១២ក្រុម ដែលមានកម្មវិធីអប់រំចំនួន ១៣០៥លើក នៅក្នុងភូមិចំនួន៩០៣ ។ ប្រជាជនចំនួន ៦២៧,២៤៤នាក់ បានទទួលការអប់រំបំភ្លឺ ។

ការចុះសាកសួរពត៌មានក្នុងចំណោមបុរស១៨,៨០៨នាក់ ស្ត្រី២៥,២៦៣នាក់ និង កុមារ ៣៧,២៨៧នាក់ ត្រូវបានគេធ្វើឡើង ។

ពត៌មានដែលអ្នកភូមិបានផ្តល់ជូនក្រុមបំផុសការយល់ដឹងពីមីនបាននាំឆ្ពោះទៅការកំទេចគ្រាប់មិនទាន់ផ្ទុះបាន៤,៧១៦គ្រាប់ និង មីន២,៣៤០គ្រាប់ និង ដឹងពីចំការមីនចំនួន៣៧១កន្លែង ។ អង្គការ CMAC ក៏បានប្រើប្រព័ន្ធយុទ្ធនាការឃោសនាផ្សព្វផ្សាយតាមទូរទស្សន៍ចំនួន ៦០៧ពេល និង តាមវិទ្យុ ៥៤៣ពេល ។ អង្គការ HALO Trust បាននិយាយណែនាំប្រជាជនក្នុងតំបន់ដែលគេបំពេញការងារផងដែរ ។

ក្រុមការងារទំនាក់ទំនងសហគមន៍របស់ MAG/MAT បានបំផុសការយល់ដឹងរបស់សហគមន៍ដែលត្រូវធ្វើនៅពេលជួបមីន ក្នុងតំបន់ដែលពួកគេកំពុងធ្វើការ ។ ការអប់រំបំភ្លឺត្រូវបានគេធ្វើភ្លាមនៅពេលដែលក្រុម MAT ទៅដល់ភូមិដោយប្រើរយៈពេលប្រមាណពី ៣០ ទៅ ៤៥នាទី ។ បន្ទាប់ពីការអប់រំបំភ្លឺលើកដំបូងនោះមក ការអប់រំបំភ្លឺទាំងឡាយក៏ត្រូវបានគេធ្វើតាមសំណូមពរជាបន្តបន្ទាប់[78] ។

ក្នុងនាមកម្មវិធី ‘‘កុមាររងផលប៉ះពាល់ដោយសារសង្គ្រាមក្នុងប្រទេសកម្ពុជា’’ ដែលគេបានធ្វើការវាយតំលៃសកម្មភាពដែលទ្រទ្រង់ដោយអង្គការ UNICEF ដើម្បីទប់ស្កាត់គ្រោះថ្នាក់ដោយសារមីននោះមានរាប់បញ្ចូល

[77] Bullpitt Ian p.52
[78] Archie Law : ‘‘MAG Briefing Paper’’ p.3, February 2001, Phnom Penh, Cambodia.

ទាំងការបំផុសការយល់ដឹងពីមីនផងដែរ ។ របាយការណ៍ដែលសរសេរដោយលោក Chris Horwood និងលោក Andrea Croslan កាលពីខែកក្កដា ឆ្នាំ២០០០ ត្រូវបានគេធ្វើការកត់សំគាល់ ។

នៅក្នុងតំបន់អង្កេតដែលក្រុមដាក់ផ្លាកសញ្ញាមីនបានធ្វើការសន្និដ្ឋានឃើញថា ''មួយភាគធំនៃមនុស្សពេញវ័យ និង កុមារបានយល់យ៉ាងច្បាស់ពីបង្គោលមីនពិតប្រាកដ ។ ទោះជាយ៉ាងដូច្នេះក្តី ក៏នៅគ្រប់តំបន់ដែលគេបានចុះសាកសួរ ថ្វីត្បិតតែប្រជាជនយល់ពីសញ្ញាបង្គោលមីន ក៏ប្រជាជននៅតែរស់នៅធ្វើស្រែចំការ ឃ្វាលគោ និង ឆ្លងកាត់តំបន់មានផ្លាកបង្គោលមីន និង គ្មានសុវត្ថិភាពទាំងនោះ ពោលគឺ កន្លែងដែលនៅពីក្រោយបង្គោលសញ្ញាមីនតែម្តង[79] ''។

សំរាប់ពួកយើងដែលបានធ្វើការងារផ្នែកសកម្មភាពមីនជាច្រើនឆ្នាំ យើងសូមកំនត់អោយធ្វើការការកែតំរូវផ្ទាល់រវាងសកម្មភាពមីន និង អត្រាគ្រោះថ្នាក់ ។ លក្ខខ័ណ្ឌនេះសរបង្ហាញថា គ្មានទំនាក់ទំនងបែបនេះកើតមាននៅឡើយទេ ហេតុដូចនេះគេមិនសមនឹងនិយាយថា ការថយចុះចំនួនគ្រោះថ្នាក់ដោយសារមីនក្នុងប្រទេសកម្ពុជាកើតឡើងអាស្រ័យដោយសារប្រសិទ្ធិភាពនៃសកម្មភាពមីនឡើយ ។ សកម្មភាពមីនប្រហែលគ្រាន់តែជាកត្តារួមចំណែកមួយ ហើយមានឥទ្ធិពលក្នុងតំបន់ខ្លះជាជាងតំបន់ឯទៀតប៉ុណ្ណោះ ប៉ុន្តែមិនអាចមានន័យថាអាចធ្វើជាចំណងវិជ្ជមានជួយដល់ការកាត់បន្ថយគ្រោះថ្នាក់ដោយសារមីនទាំងស្រុងឡើយ[80] ។

វាជាការច្បាស់ណាស់ដែលថា ភាពទន់ខ្សោយក្នុងការជ្រើសរើសសាលារៀនគោលដៅ គឺ ជាបរាជ័យយ៉ាងធ្ងន់ធ្ងររបស់កម្មវិធីអប់រំកុមារអោយយល់ដឹងពីគ្រោះថ្នាក់ដោយសារមីន ហើយនៅពេលដែលកម្មវិធីដាក់អោយដំណើរការ វាប្រឆាំងទៅនឹងខ្លឹមសារគោលបំណងនៃកម្មវិធីផ្ទាល់តែម្តង[81] ។

ឥទ្ធិពលនៃការអប់រំកុមារអោយយល់ដឹងពីគ្រោះថ្នាក់ដោយសារមីន ប្រហែលជាអាចកើតមានដើម្បីកាត់បន្ថយគ្រោះថ្នាក់របស់កុមារដោយសារមីន/គ្រាប់មិនទាន់ផ្ទុះប៉ុណ្ណោះ បើសិនណាកុមារគ្រប់អាយុរៀនទាំងអស់ទទួលបានការអប់រំពីកម្មវិធី ''អប់រំកុមារអោយយល់ដឹងពីគ្រោះថ្នាក់ដោយសារមីន'' ។ កុមារដែលទទួលបានចំណេះដឹងពីការអប់រំកុមារអោយយល់ដឹងពីគ្រោះថ្នាក់ដោយសារមីន បានបង្ហាញនូវស្មារតីជឿជាក់លើចំណេះដឹងរបស់ពួកគេ ។ កុមារទាំងនេះប្រាកដក្នុងចិត្ត នៅពេលគេពន្យល់ និង ឆ្លើយតបសំនួរអប់រំបំភ្លឺដែលគេបានស្តាប់ និង រៀនសូត្រពី ''កម្មវិធីអប់រំកុមារអោយយល់ដឹងពីគ្រោះថ្នាក់ដោយសារមីន'' យ៉ាងទៀងទាត់នោះ ។ កុមារដែលមិនបានចូលសាលារៀន ២០,៥៣ភាគរយក្នុងតំបន់គោលដៅសាកល្បង និង ៦៨,៧១ភាគរយ ក្នុងឃុំ

[79] UNICEF External Evaluation of Supported Mine Action Projects June/July 2000, Phnom Penh, Cambodia, p.9
[80] UNICEF External Evaluation of Supported Mine Action Projects June/July 2000, Phnom Penh, Cambodia, p.16
[81] Ibid, p.64

ប៉ុន្តែត្រូវតែជាចំណុចគោលដៅរបស់កម្មវិធី ‘‘ អប់រំកុមារអោយយល់ដឹងពីគ្រោះថ្នាក់ដោយសារមីន ’’ ព្រោះពួកគេហាក់ដូចជាក្រុមដែលរងការឈឺចាប់ជាងគេ និង ប្រឈមមុខនឹងគ្រោះថ្នាក់ដោយសារមីនជាប្រចាំច្រើនជាងគេឯង[82] ។

## គ្រោះថ្នាក់ដោយសារមីនក្នុងឆ្នាំ ២០០០ (Mine Casualties 2000)[83]

គ្រោះថ្នាក់ដោយសារមីនក្នុងប្រទេសកម្ពុជាបានថយចុះ ប៉ុន្តែអត្រាគ្រោះថ្នាក់នៅតែមានក្នុងចំនួន២នាក់ក្នុងមួយថ្ងៃ ។ នៅឆ្នាំ ២០០០ មានប្រជាជន៨០០នាក់ ទទួលរងគ្រោះ ឬ ស្លាប់ដោយសារមីន ពោលគឺមានការថយចុះចំនួន២៣៥នាក់ បើធៀបទៅឆ្នាំមុន ។ ក្នុងចំណោមអ្នករងគ្រោះទាំងនេះមាន ២៥១នាក់ជាកុមារ ៤៩៤នាក់ជាបុរស និង ៤៨នាក់ ជាស្ត្រី ។ ក្នុងចំនួននេះ មាន១៥៩នាក់ស្លាប់ និង ៦៣៤នាក់ដែលនៅសល់រងរបួស ។ ជាបន្ថែមនៅក្នុងឆ្នាំ២០០១ ចំនួនអ្នករងគ្រោះក្នុងខែមករាមាន ៦៨នាក់ ខែកុម្ភៈមាន៧៩នាក់ ខែមិនាមាន១១២នាក់ ខែមេសាមាន៥៧នាក់ និង ខែឧសភាមាន៧០នាក់ ។

មូលហេតុរងគ្រោះនិយាយរួមក្នុងឆ្នាំ២០០០ គឺមានការធ្វើស្រែចំការ២២% ធ្វើដំណើរ១៣% រកអុស១១% ឃ្វាលសត្វ២% ដំគ្រាប់លេង៣៩% និង មូលហេតុដទៃទៀត១% ។ ទោះជាយ៉ាងណាក្តី ក៏៦៧%នៃគ្រោះថ្នាក់របស់កុមារ គឺ បណ្តាលមកពីការដំគ្រាប់លេង ។

ក្នុងឱកាសកិច្ចប្រជុំស្តីពីការត្រួតពិនិត្យមីននៅខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០០ តំណាងអង្គការកាកបាទក្រហមកម្ពុជាបានអោយដឹងថា គ្រាប់មីនមានរូបរាងដូចមីនដែលគាត់បានឃើញមុនឆ្នាំ១៩៧៥ក្នុងខេត្តកំពុងស្ពឺ បានកួចដោយទឹកជំនន់បញ្ជូនខុសពីទីតាំងដើម ហើយក៏ផ្ទុះបណ្តាលអោយរបួសក្មេង ៥នាក់ នៅក្នុងភូមិមួយ ។

ទីតាំងគ្រាប់មីនដែលបង្កអោយមានគ្រោះថ្នាក់នៅក្នុងឆ្នាំ២០០០ គឺដីព្រៃ៤២% ដីវាលស្រែ១៦% ដីថ្នល់១២% ដីភូមិ១២% ដីភ្នំ៥% ដីដងស្ទឹងទន្លេ៥% ដីក្បែរបន្ទាយទាហាន និងដីព្រៃគុម្ពោត ៥% ។

ភាគច្រើននៃគ្រោះថ្នាក់ដោយសារមីនថ្មីៗនៅខេត្តបាត់ដំបងមាន៣២% បន្ទាប់មកគឺខេត្តបន្ទាយមានជ័យ ១៤% ខេត្តឧត្តរមានជ័យ៩% ខេត្តព្រះវិហារ៨% ក្រុងប៉ៃលិន៨% ខេត្តសៀមរាប៥% និង ខេត្តពោធិសាត់៣% ។ ពីមួយខែទៅមួយខែ ពីខេត្តមួយទៅខេត្តមួយចំនួនអ្នករងគ្រោះត្រូវបានគេរាយក្នុងតារាងខាងក្រោមនេះ ។

[82] Ibid, p.72
[83] CRC Mine Incidents Database, December 2000, Cambodia.

វាជាការពិបាកដើម្បីធ្វើការប៉ាន់ស្មានចំនួនសរុបពិតប្រាកដនៃអ្នករងគ្រោះដោយសារមីនដែលនៅរស់សព្វថ្ងៃនេះក្នុងប្រទេសកម្ពុជា ។ តែទោះយ៉ាងណានេះក្តី ក៏កំនត់ហេតុទាំងឡាយនេះបង្ហាញថា យ៉ាងតិចក៏មានប្រជាជនចំនួន៤១,១៩៣នាក់ដែរដែលរងគ្រោះដោយសារមីនរហូតមកដល់ចុងឆ្នាំ២០០០ ។ កំនត់ហេតុទាំងឡាយនោះក៏បានបញ្ជាក់ផងដែរថាក្នុងចំនោមជនរងគ្រោះទាំងនោះដែលស្លាប់មានចំនួន១៣,៩១៧នាក់ គិតពីខែមករា ឆ្នាំ១៩៧៩ ដល់ ខែធ្នូ ឆ្នាំ១៩៩៩ ។ អាស្រ័យហេតុនេះបច្ចុប្បន្នប្រទេសកម្ពុជាមានអ្នករងគ្រោះដោយសារមីនប្រមាណជា ២៧.២៧៦នាក់ ។

ចំនួនគ្រោះថ្នាក់ដោយសារមីន និង គ្រាប់មិនទាន់ផ្ទុះក្នុងប្រទេសកម្ពុជា

| ឆ្នាំ | គ្រោះថ្នាក់ដោយសារមីន/គ្រាប់មិនទាន់ផ្ទុះ | ជាមធ្យមប្រចាំខែ | ប្រចាំថ្ងៃ |
|---|---|---|---|
| ១៩៩៦ | ៣០៤៦ | ២៥៤ នាក់ | ៨ នាក់ |
| ១៩៩៧ | ១៨១០ | ១៥១ នាក់ | ៥ នាក់ |
| ១៩៩៨ | ១៩១៨ | ១៦០ នាក់ | ៥ នាក់ |
| ១៩៩៩ | ១០៤៥ | ៨៧ នាក់ | ៣ នាក់ |
| ២០០០ | ៨០០ | ៦៦ នាក់ | ២ នាក់ |
| ២០០១(គិតដល់ខែមេសា) | ៣២៨ | ៨២ នាក់ | ៣ នាក់ |

អ្នករងគ្រោះជាទាហាន/ស៊ីវិល

| ឆ្នាំ | ទាហាន | ស៊ីវិល |
|---|---|---|
| ១៩៩៧ | ៤៩% | ៥១% |
| ១៩៩៨ | ៤១% | ៥៩% |
| ១៩៩៩ | ១៤% | ៨៦% |
| ២០០០ | ៧ % | ៩៣% |
| ២០០១ (៤ខែ) | ៩ % | ៩១% |

នៅឆ្នាំ១៩៩៩ ក្នុងចំណោមគ្រោះថ្នាក់ ១០៣៧លើក ៦៣%ត្រូវបានគេកត់ត្រាថាជាគ្រោះថ្នាក់ដោយសារមីន និង ៣៧%ជាគ្រោះថ្នាក់ដោយសារគ្រាប់មិនទាន់ផ្ទុះ ។ ក្នុងឆ្នាំ២០០០ ក្នុងចំណោម ៧៩៩លើក ៥៤%ត្រូវបានគេកត់ត្រាថាបណ្តាលមកពីគ្រាប់មីន ចំណែកឯ ៤៥%ទៀតត្រូវរងរបួស ឬ ស្លាប់ដោយសារគ្រាប់មិនទាន់ផ្ទុះ ។ មន្ត្រីផ្លូវការស្ថានទូតអូស្ត្រាលីមួយរូបបានថ្លែងថា[84] ក្នុងឱកាសទស្សនកិច្ចនៅខេត្តកោះកុងថ្មីៗនេះ យោធាម្នាក់បានប្រាប់អោយដឹងថា ក្នុងចំណោមកងទ័ពដែលឈរជើងក្នុងតំបន់នោះ ជាមធ្យមទទួលគ្រោះថ្នាក់ដោយសារមីន ១០នាក់ក្នុងមួយខែ ។ មន្ទីរពេទ្យខេត្តកោះកុងបានបង្ហាញនូវរូបថតអ្នករងគ្រោះដោយសារមីនដល់គាត់ ។ បើសិនជាពត៌មាននេះជាការពិត ស្ថិតិដែលសំរង់បានក្នុងដាតាបាស នៅមិនទាន់កត់ត្រាចុះនូវរាល់គ្រោះថ្នាក់ដែលកើតមានក្នុងតំបន់ដែលគេពិបាកចូលទៅដល់នៅឡើយ ។

[84] Report to Denise Coghlan, 1 March, 2001, Phnom Penh, Cambodia.

| គ្រោះថ្នាក់ដោយសារមីន និង គ្រាប់មិនទាន់ផ្ទុះក្នុងប្រទេសកម្ពុជាពីឆ្នាំ ១៩៧៩-២០០០[85] | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ឆ្នាំ | សរុប | អ្នកស្លាប់ជាទាហាន | ចំនួនអ្នកស្លាប់ជាស៊ីវិល | ចំនួនក្មេងស្លាប់ | អ្នករងគ្រោះជាទាហាន | អ្នករងគ្រោះជាស៊ីវិល | អ្នករងគ្រោះជាកូនក្មេង | មិនស្គាល់ភិនភាគ |
| **1979** | 4,472 | 757 | 1,143 | 424 | 667 | 1,409 | 72 | |
| **1980** | 1,142 | 91 | 305 | 122 | 201 | 388 | 35 | |
| **1981** | 804 | 110 | 172 | 71 | 187 | 251 | 13 | |
| **1982** | 1,523 | 217 | 291 | 105 | 407 | 480 | 23 | |
| **1983** | 2,254 | 412 | 388 | 105 | 675 | 635 | 36 | 3 |
| **1984** | 2,422 | 442 | 371 | 85 | 796 | 687 | 40 | 1 |
| **1985** | 2,922 | 580 | 446 | 106 | 954 | 781 | 54 | 1 |
| **1986** | 2,392 | 469 | 352 | 72 | 861 | 610 | 27 | 1 |
| **1987** | 2,890 | 525 | 366 | 79 | 1,137 | 724 | 59 | |
| **1988** | 2,394 | 432 | 274 | 74 | 944 | 631 | 38 | 1 |
| **1989** | 2,719 | 462 | 314 | 74 | 1,083 | 705 | 76 | 5 |
| **1990** | 2,520 | 355 | 336 | 98 | 942 | 696 | 90 | 3 |
| **1991** | 1,932 | 267 | 271 | 57 | 688 | 582 | 66 | 1 |
| **1992** | 1,813 | 209 | 254 | 64 | 455 | 724 | 105 | 2 |
| **1993** | 2,047 | 218 | 349 | 67 | 522 | 763 | 126 | 2 |
| **1994** | 2,402 | 247 | 366 | 74 | 658 | 867 | 190 | |
| **1995** | 2,985 | 262 | 229 | 92 | 1,228 | 864 | 306 | 4 |
| **1996** | 4,098 | 444 | 331 | 84 | 2,058 | 904 | 275 | 2 |
| **1997** | 1,937 | 223 | 157 | 67 | 724 | 536 | 230 | |

[85] CRC Cambodia Mine-UXO Victim Information System, 20 May 2001, Phnom Penh, Cambodia.

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **1998** | 1,900 | 145 | 205 | 44 | 636 | 592 | 259 | 19 |
| **1999** | 1,045 | 30 | 150 | 56 | 124 | 451 | 233 | 1 |
| **2000** | 800 | 19 | 88 | 54 | 38 | 402 | 199 | |
| សរុប | **49,413** | **6,916** | **7,158** | **2,074** | **15,985** | **14,682** | **2,552** | **46** |
| | | ស្លាប់ | **16,148** | | របួស | **33,219** | | |

## ចំនួនអ្នករងគ្រោះដោយសារមីនឆ្នាំ ២០០០:

| ខេត្ត | មករា | កុម្ភ: | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បាត់ដំបង | ២៨ | ២៥ | ៣០ | ៣៤ | ២៨ | ១២ | ១៣ | ២១ | ២៩ | ៥ | ២០ | ១៣ | ២៥៨ |
| បន្ទាយមានជ័យ | ១២ | ១១ | ១៤ | ១៦ | ១៧ | ១០ | ៤ | ៨ | ៥ | ៤ | ១១ | ៥ | ១១៧ |
| ឧត្ដរមានជ័យ | ៣ | ៧ | ១៦ | ៧ | ៧ | ៥ | ២ | ៤ | ៥ | ០ | ៥ | ៤ | ៦៥ |
| ព្រះវិហារ | ១០ | ៥ | ៤ | ១៤ | ៦ | ៤ | ៦ | ២ | ២ | ៥ | ៥ | ៤ | ៦៧ |
| សៀមរាប | ៩ | ៣ | ២ | ៤ | ៧ | ៣ | ៧ | ២ | ១ | ២ | ១ | ១ | ៤២ |
| ពោធិ៍សាត់ | ២ | ១៣ | ៤ | ៦ | ០ | ៤ | ០ | ៤ | ២ | ១ | ២ | ១ | ៣៩ |
| កំពង់ធំ | ០ | ០ | ៣ | ២ | ០ | ៩ | ៣ | ០ | ១ | ១ | ១ | ៥ | ២៥ |
| កំពង់ចាម | ០ | ៤ | ៩ | ១ | ២ | ២ | ០ | ០ | ២ | ៨ | ០ | ០ | ២៨ |
| ប៉ៃលិន | ៩ | ៤ | ២ | ១ | ៤ | ៨ | ៧ | ៤ | ៣ | ៥ | ៨ | ៨ | ៦៤ |
| ស្វាយរៀង | ០ | ០ | ២ | ០ | ០ | ០ | ០ | ០ | ១ | ៤ | ០ | ១ | ៨ |
| កំពង់ស្ពឺ | ២ | ០ | ១ | ០ | ១ | ៥ | ០ | ០ | ១ | ១ | ២ | ០ | ១៣ |
| កំពត | ១ | ៣ | ០ | ៤ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ៨ |
| កោះកុង | ០ | ៥ | ២ | ២ | ៥ | ០ | ០ | ០ | ០ | ០ | ០ | ១ | ១៥ |
| កណ្ដាល | ០ | ២ | ០ | ០ | ០ | ០ | ០ | ០ | ៥ | ០ | ៣ | ០ | ១០ |
| ក្រចេះ | ២ | ០ | ៣ | ៣ | ១ | ០ | ១ | ៣ | ២ | ០ | ០ | ០ | ១៥ |
| ភ្នំពេញ | ០ | ០ | ០ | ០ | ២ | ០ | ០ | ០ | ០ | ០ | ០ | ០ | ២ |
| ក្រុងព្រះសីហនុ | ០ | ០ | ០ | ០ | ០ | ២ | ០ | ០ | ០ | ០ | ០ | ០ | ២ |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កំពង់ឆ្នាំង | ១ | ០ | ០ | ០ | ០ | ០ | ០ | ០ | ១ | ១ | ០ | ១ | ៤ |
| តាកែវ | ០ | ៨ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ៨ |
| ព្រៃវែង | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| មណ្ឌលគិរី | ០ | ០ | ១ | ០ | ០ | ០ | ១ | ០ | ០ | ០ | ៥ | ០ | ៧ |
| រតនគិរី | ០ | ០ | ០ | ០ | ០ | ០ | ០ | ១ | ០ | ០ | ០ | ០ | ១ |
| ក្រុងកែប | ០ | ០ | ០ | ១ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ១ |
| ស្ទឹងត្រែង | ០ | ០ | ០ | ០ | ០ | ២ | ០ | ០ | ០ | ០ | ០ | ០ | ២ |
| សរុប | ៧៩ | ៩០ | ៩៣ | ៩៥ | ៨០ | ៦៦ | ៤៤ | ៤៩ | ៦០ | ៣៧ | ៦៣ | ៤៤ | ៨០០ |

## ការឧបត្ថម្ភអ្នករងគ្រោះដោយសារមីន (Mine Victim Assistance)

ធាតុនៃការជួយឧបត្ថម្ភអ្នករងគ្រោះដោយសារមីន/គ្រាប់មិនទាន់ផ្ទុះ គឺ ជាទូទៅត្រូវការពេលវេលាយូរអង្វែងជាងការកំនត់ទុក ។ អវយវៈ សិប្បនិម្មិត និង រទេះអ្នកពិការត្រូវការផ្លាស់ប្តូរ និង ជួសជុលជាប្រចាំ ។ ការកើតមានឡើងវិញនូវបញ្ហាសុខភាព ការព្យាបាលផ្នែកចិត្តសាស្ត្រសង្គម ការឧបត្ថម្ភជាប្រាក់ និង ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ជាញឹកញាប់តំរូវអោយធ្វើការឧត្ថម្ភក្នុងរយៈពេលយូរអង្វែងជាងការគ្រោងទុក ។ ហេតុនេះការជួយឧបត្ថម្ភអ្នករងគ្រោះថ្នាក់ដោយសារមីនតំរូវអោយគ្របដណ្តប់នូវតំរូវការទាំងអ្នកដែលរងគ្រោះរួចទៅ ហើយព្រមទាំងអ្នកដែលនឹងទទួលគ្រោះថ្នាក់នាពេលខាងមុខផង [86] ។

ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC)ត្រូវបានបង្កើតនៅឆ្នាំ១៩៩៧ គឺជាអង្គភាពអចិន្ត្រៃយ៍ថ្នាក់ជាតិផ្នែកសំរបសំរួលរួមមាន តំណាងរបស់រដ្ឋាភិបាល អង្គការក្នុងស្រុក អង្គការអន្តរជាតិ និង បុគ្គលដែលលះបង់ដើម្បីជួយស្តារលទ្ធភាពពលកម្ម និង ធ្វើសមាហរណកម្មទាំងផ្នែកសេដ្ឋកិច្ច និង សង្គមកិច្ចដល់ជនពិការកម្ពុជា ។ សមាជិកភាពនៃ DAC ឆ្នាំ២០០១ រួមមាន អង្គការរបស់រដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាលចំនួន៣៥ អង្គការ ។ អង្គភាពនេះត្រូវបានបង្កើតឡើងតាមអនុក្រឹត្យដែលចេញដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនិតិសម្បទា (MoSALVY) [87] ។

[86] Bullpitt Ian: "Summary of Discussions and Recommendations Relating To National Strategy and Management Of The Mine Action Sector Within Cambodia In The Short and Long Term Beyond 2000," p.55, Phnom Penh 5 November 2000.
[87] Ibid. p.56

គោលបំណងរបស់ DAC គឺធ្វើការសំរបសំរួលនូវកម្មវិធីទាំងឡាយដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រពង្រឹងថ្នាក់ជាតិ កាត់បន្ថយនូវសេវាជាន់គ្នា សំរួលការផ្លាស់ប្តូរបទពិសោធន៍ល្អៗ កសាងសមត្ថភាពថ្នាក់ជាតិ សម្រួលបញ្ចូលតំរូវការរបស់អ្នកពិការទៅក្នុងគំរោងផែនការរបស់ក្រសួងនានា និង អភិវឌ្ឍន៍ អនុវត្ត ត្រួតពិនិត្យ និង វាយតំលៃគំរោងផែនការជាតិ ។ ក្រុមប្រឹក្សាសកម្មភាពជនពិការអនុវត្តកម្មវិធីមួយចំនួនដោយខ្លួនឯង ។

**ការថែរក្សាសុខភាព**

ក្នុងឆ្នាំ២០០០ និងឆ្នាំ២០០១ ប្រជាជនដែលទទួលគ្រោះថ្នាក់ដោយសារមីនភាគច្រើនមានលទ្ធភាពត្រូវបានដឹកជញ្ជូនទៅកាន់មន្ទីរខេត្ត ឬ ទីក្រុងសំរាប់ធ្វើការវះកាត់ ឬ ក៏បញ្ជូនទៅមន្ទីរពេទ្យសង្គ្រោះបន្ទាន់ (Emergency) នៅខេត្តបាត់ដំបង ។ ទោះជាយ៉ាងនេះក្តី ក៏អ្នករងគ្រោះភាគច្រើនមិនអាចមានប្រាក់គ្រប់គ្រាន់សំរាប់បង់ថ្លៃព្យាបាលក្នុងមន្ទីរពេទ្យរដ្ឋឡើយ ។ ការបង់ប្រាក់ជាទូទៅមានន័យថា ត្រូវលក់គោ ឬ ដីធ្លី ឬ ក៏ត្រូវជាប់បំណុលគេរើមិនរួច ។ អំបែងគ្រាប់នឹងផុសលើខ្លួនជាថ្មី ហើយបញ្ហាវះកាត់យកវាចេញបន្ទាប់មក សុទ្ធសឹងជាបញ្ហាសុខភាពដែលស៊ីរូងប្រាក់ចំណូលរបស់គ្រួសារអ្នកពិការគ្មានទីបញ្ចប់ ។ មន្ទីរពេទ្យនៅខេត្តកោះកុងជាឧទាហរណ៍មួយ បង្ហាញពីកង្វះខាតផ្នែកបរិក្ខារ និង ថ្នាំពេទ្យសំរាប់ព្យាបាលអ្នករងគ្រោះដោយសារមីន[88] ។

អង្គការដែលផលិតជើងសិប្បនិម្មិត និង រទេះជនពិការក្នុងប្រទេសកម្ពុជាឆ្នាំ២០០០ [89] :

| អង្គការ | ទីតាំង | ជើងសិប្បនិម្មិត | រទេះជនពិការ |
|---|---|---|---|
| American Red Cross | ខេត្តកំពង់ស្ពឺ | ៥៩៥ | *គ្មាន* |
| Association to Aid the Refugee – Japan Cambodia | ក្រុងភ្នំពេញ | *គ្មាន* | ៣០០ |
| Cambodia Trust (CT) | ៣ ខេត្ត | ៩៦១ | *គ្មាន* |
| Handicap International (HI) រួមនឹង MSALVY | ៧ ខេត្ត | ១៥៩៩ | *គ្មាន* |
| International Committee of the Red Cross (ICRC) | ខេត្តបាត់ដំបង | ១២៩៥ | *គ្មាន* |
| Jesuit Service Cambodia (JS) | ខេត្តកណ្តាល | *គ្មាន* | ៩៩៧ |
| Veterans International (VI) | ក្រុងភ្នំពេញ | ១០៧៣ | ៤៥១ |
| **សរុប** | | **៥,៥២៣** | **១,៧៤៨** |

អង្គការដែលចែកចាយរទេះជនពិការ រួមមាន: American Red Cross (213គ្រឿង), Cambodia Trust (173គ្រឿង), Handicap International (449គ្រឿង), ICRC (180គ្រឿង), Jesuit Service (222គ្រឿង) និង Veterans International (555គ្រឿង)។

---

[88] T. McCormack interview with Denise Coghlan, 1 March 2001, Phnom Penh, Cambodia.
[89] Information provided by named organizations to Land Mine Monitor, December,2000, Phnom Penh, Cambodia.

## ការផលិតសំភារៈរណប[90]

| អង្គការ | លើជង្គង់ | ក្រោមជង្គង់ | ឆ្អឹងខ្នង | ប្រព័ន្ធអង្គុយ | សរុប |
|---|---|---|---|---|---|
| AmCross | ៧ | ៤៩៦ | ៥ | ៣០ | ៥៣៨ |
| Cambodia Trust (CT) | ២១ | ១,៣៧១ | ១១ | ៧០ | ១,៤៧៣ |
| HI | ៤ | ១៨៥ | ២ | ១ | ១៩២ |
| ICRC | ៣៦ | ៤៣៦ | ៨ | ០ | ៤៨០ |
| VI | ១២ | ១,៥៧៥ | ៤៤ | ០ | ១,៦៣១ |
| សរុប | ៨០ | ៤,០៦៣ | ៧០ | ១០១ | ៤,៣១៤ |

សេវាបំរើតំរូវការរបស់មនុស្សខ្វាក់បានចាប់ផ្តើមដោយអង្គការ Maryknoll បច្ចុប្បន្ននេះដំណើរការដោយអង្គការ Caritas វិញ ។ អង្គការ South Asia Outreach ក៏បានជួយបញ្ហាផ្នែកផងដែរ ។ ជំនួយត្រចៀក និង ការសាកល្បងផ្នែកស្តាប់សំលេងធ្វើឡើងដោយអង្គការ Jesuit Service ។

អង្គការដែលជួយផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនពិការ រួមមាន : Jesuit Service, Maryknoll ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនិតិសម្បទា World Vision ការបង្កើនការសិក្សាសំរាប់កុមារពិការផ្តល់អោយដោយអង្គការ Marist Mission អូស្ត្រាលី ។ ការអប់រំសំរាប់កុមារថ្លង់ និង ខ្វាក់ផ្តល់អោយដោយអង្គការគ្រួសារថ្មី ។

អង្គការបំរើតំរូវការផ្នែកចិត្តសាស្ត្រសង្គម ការអភិវឌ្ឍន៍ និង សេដ្ឋកិច្ច រួមមាន: Action on Disability and Development, AFSC, CDPO, CMI, HI, Jesuit Service, Maryknoll, Social Service of Cambodia, Jesuit Service និង Transcultural Psycho Social Organisation (TPO) ។

ការសិក្សាស្រាវជ្រាវដែលធ្វើឡើងដោយអង្គការ Cambodia Trust ឆ្នាំ២០០០ បានអោយដឹងថា[91]:

- ៦៤% នៃជនពិការ មានដីធ្លី និង ទ្រព្យសម្បត្តិតិចជាងប្រជាជនដទៃទៀតក្នុងសហគមន៍ជិតខាងរបស់គាត់
- ៦៨% មានចំនូលមធ្យមប្រចាំគ្រួសារតិចជាង ១៥២,០០០រៀលក្នុងមួយខែ (៤០$ US)
- ៥៤% នៃអ្នកសំភាសជាទូទៅ(២៨%) ឬ ក៏ស៊ឹងតែ២៦% ទាំងអស់បារម្ភព្រួយជាច់ច្រកមួយថ្ងៃៗ
- ៦៦% នៃអ្នកសំភាសមានឱកាសលំហែកំសាន្ត ឬចូលរួមក្នុងសកម្មភាពសង្គម
- ៨៥% នៃអ្នកសំភាសជាទូទៅ ឬ ស៊ឹងតែទាំងអស់តែងធ្លាប់ទទួលអារម្មណ៍ធ្លាក់ទឹកចិត្ត ឬ ក៏តែលតោលអស់សង្ឃឹម ។

---

[90] Claude Tardif, Physical Rehabilitation Committee Report, March 2001, Phnom Penh, Cambodia.
[91] Powell B. Qualitative Impact of Assistance to Disabled People, p. 2, November, 200, Phnom Penh Cambodia.

ក្រុមប្រឹក្សាសកម្មភាពជនពិការបានសំរបសំរួលគំរោងការស្រាវជ្រាវមួយចំនួនកាលពីឆ្នាំ២០០០[92]:

ឧបត្ថម្ភថវិកាដោយអង្គការ UNICEF ក្នុងទឹកប្រាក់ $១២,៣៨៦US ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) កំណត់ទិន្នន័យដែលមាន ទិន្នន័យដែលនៅខ្វះចន្លោះ និង អ្នកដាក់ហ៊ុនក្នុងបញ្ហាជនពិការកម្ពុជា ហើយធ្វើការអង្កេតស្រាវជ្រាវពីគំរូ ការសាកល្បង និង អភិវឌ្ឍន៍ការស្ទង់មតិ និង វិធីសាស្ត្រ ។ តាមរយៈការសិក្សាស្រាវជ្រាវនេះ គេសង្ឃឹមថានឹងអាចស្នើសុំប្រព័ន្ធទ្រទ្រង់បញ្ចូលទិន្នន័យក្នុងកុំព្យូទ័រមួយគ្រឿង ដែលអាចបំរើការកម្មវិធីផ្នែកសំរង់ស្ថិតិសំរាប់ការស្រាវជ្រាវ និង ការស្ទង់មតិបន្ថែមទៀត ស្តីពីស្ថានភាពជនពិការនៅប្រទេសកម្ពុជា ហើយនិងអាចប៉ាន់ប្រមាណសមត្ថភាពរបស់អង្គការក្រៅរដ្ឋាភិបាលទាំងឡាយ និង សមត្ថភាពរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនិតិសម្បទាថ្នាក់ស្រុក និង ថ្នាក់ខេត្តក្នុងការងារប្រមូលទិន្នន័យ។

ដោយមានការគាំទ្រពីមូលនិធិ World Rehabilitation Fund DAC បានផ្តួចផ្តើមសកម្មភាពមុនគំរោង ផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច និង ការរកប្រាក់ចំណូលសំរាប់ជនពិការ ($៣៥,៩៤០US) ។ ការសិក្សាស្រាវជ្រាវមួយទៀតដែលឧបត្ថម្ភដោយមូលនិធិស្តារនិតិសម្បទាពិភពលោកក្នុងទឹកប្រាក់ $១៨,៦៨០US សំរាប់បំផុសការយល់ដឹងពីពិការភាព ។

ឧបត្ថម្ភមូលនិធិដោយ WHO សិក្ខាសាលាមួយដែលមានរយៈពេលបីថ្ងៃក្នុងទឹកប្រាក់ $ ២០,៣៦៥ US សំរាប់ពង្រឹងកិច្ចប្រតិបត្តិការចំរុះតាមផ្នែកសេវាស្តារនិតិសម្បទាថ្នាក់ឃុំ ត្រូវបានរៀបចំឡើងដោយ DAC បាត់ដំបង ។ អង្គការ FAO កំពុងផ្តល់ទឹកប្រាក់ $១៤,៧៥០US សំរាប់សិក្ខាសាលារយៈពេលពីរថ្ងៃ និង ទស្សនកិច្ចសិក្សាមួយថ្ងៃផ្សេងទៀត ស្តីពីការបង្កើនការចូលរួមដោះស្រាយបញ្ហាអភិវឌ្ឍន៍ជនបទ តាមរយៈការបណ្តុះបណ្តាល ការកសាងសមត្ថភាពជនពិការក្នុងវិស័យរកប្រាក់ចំណូល ។

WRF បានផ្តល់ថវិកាចំនួន $១៦,០០០US សំរាប់បង្កើតក្រុមទីប្រឹក្សាពាណិជ្ជកម្ម (BAC) ដែលជ្រើសតាំងចេញពីចំណោមថ្នាក់ដឹកនាំសហគមន៍ពាណិជ្ជកម្មឯកជន ក្នុងបំណងគាំទ្រ NCDP អោយបង្កើតចំណងទំនាក់ទំនងរវាងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលរៀបចំឡើងដោយអង្គការនានា និង សហគមន៍ជំនួញ រួមនិងវិស័យសាធារណៈផ្នែកផ្តល់ការងារអោយធ្វើ [93] ។

ដោយរួមជាមួយ UNDP WRF ក៏បានផ្តល់ថវិការចំនួន $២៥,០០០US ដល់អង្គការក្រៅរដ្ឋាភិបាលចំនួន៤គឺ NCDP, VI , Rehab Craft និង Maryknoll ដើម្បីបង្កើតសហគមសិប្បករផងដែរ [94] ។

DAC មានគំរោងពង្រីកសហគមន៍គំរូជាផ្លូវការមួយដោយផ្អែកលើកម្មវិធីបណ្តុះបណ្តាលកម្មករសំរាប់ប្រទេសកម្ពុជា ។

---

[92] Men Sinouen, DAC response to Land Mine Monitor, 11 January 2001, Phnom Penh, Cambodia
[93] Men Sinouen, DAC response to Land Mine Monitor, 11 January 2001, Phnom Penh, Cambodia
[94] Ibid.

បទពិសោធន៍ផ្សេងៗកំពុងលេចឡើងនៅក្នុងបណ្តាខេត្តមួយចំនួន ដើម្បីធានាអោយបានថាជនពិការក្នុងតំបន់ដាច់ស្រយាលអាចទទួលបានសេវាទាំងឡាយ ។ អង្គការមួយចំនួនដូចជា HI PRESS បានរៀបចំការជួបជុំគ្នា ទៅតាមចំនុចជួបជុំសំរាប់ជនពិការទាំងឡាយប្រមូលផ្តុំគ្នា ក្នុងភូមិមួយតាមស្រុក មួយខែម្តង ។

ស្រុកខ្លះក្នុងខេត្តបន្ទាយមានជ័យមាន ៣៨ភូមិ ឯស្រុកខ្លះទៀតមានច្រើនជាង ១៦០ភូមិ ដូចនេះប្រជាជនដែលនៅឆ្ងាយដាច់ស្រយាលមិនអាចទទួលផលបានឡើយ [95] ។ ឯអង្គការឯទៀតដូចជា JS មេត្តាករុណាចុះសាកសួរសុខទុក្ខគ្រួសារជនពិការដល់ផ្ទះសំបែងរបស់ពួកគេផ្ទាល់នៅអន្លង់វែងដើម្បីប៉ាន់ប្រមាណតំរូវការរបស់អ្នកពិការ ។ ធ្វើដូចនេះគេអាចយល់ដឹងបានកាន់តែច្បាស់ឡើងអំពីស្ថានភាពពិតរបស់គ្រួសារអ្នកពិការ ប៉ុន្តែមធ្យោបាយធ្វើដំណើរ ទឹកជំនន់ ផ្លូវដើរ កំលាំងកំហែង សុទ្ធសឹងជាបញ្ហាដែលអ្នកចុះពិគ្រោះយោបល់ទាំងឡាយត្រូវខំត្រិះរិះមើលដោយប្រុងប្រយ័ត្នហើយសាកល្បងអោយអស់ពីសមត្ថភាពរបស់ខ្លួន ។

អង្គការ ADD បានរៀបចំ ‘‘ក្រុមជួយខ្លួនឯង’’ ។ កិច្ចប្រជុំស្តីពីការត្រួតពិនិត្យគ្រាប់មីនដែលបានរៀបចំនៅខេត្តបាត់ដំបង បន្ទាយមានជ័យ និង សៀមរាប បានបញ្ជាក់ថាគំរោងទាំង១២ចំនុចដែលរៀបចំដោយអ្នករងគ្រោះដោយសារមីនខ្លួនឯង បានចាប់ផ្តើមខិតកាន់តែជិតបំផុតទៅបំពេញតំរូវការរបស់អ្នករងគ្រោះដោយសារមីននៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជាហើយ ។

**គំរោងទាំង១២ចំនុចសំរាប់ជួយអ្នករងគ្រោះដោយសារមីន** [96]

1- អ្នករងគ្រោះដោយសារមីន/អ្នកពិការនៅក្នុងតំបន់រងគ្រោះដោយសារគ្រាប់មីន ***មានផ្ទះ*** សំរាប់គ្រួសាររបស់គេជ្រកកោន ។

2- អ្នករងគ្រោះដោយសារមីនមាន ***អាហារ*** បរិភោគគ្រប់គ្រាន់ ។

3-អ្នកពិការដោយសារមីន ***មានទឹក*** សំរាប់ផឹក និង ប្រើប្រាស់ដែលដើរទៅដងមិនលើសពី5នាទីពីផ្ទះរបស់ពួកគេ ។

4-កូនរបស់គេអាចទទួលបាន ***ការសិក្សា*** (ចំងាយ-ថវិកា) ហើយមនុស្សពេញវ័យមានឱកាសចូលរៀនបាន ។

5- គ្រួសារពួកគេអាចទទួលនូវ ***សេវាផ្នែកសុខភាព*** បឋមដែលការដឹកជញ្ជូនអាចរកបានមិនលើសពីមួយម៉ោងទៅដល់មណ្ឌលសុខភាព និង អាចទទួលបាននូវថ្នាំចាំបាច់ដែលពួកគេត្រូវការ ។

6-អ្នកពិការដោយសារមីនមានលទ្ធភាពរក ***ចំណូល*** បានគ្រប់គ្រាន់សំរាប់ធានាការចំណាយក្នុងគ្រួសារ ។

7- ***គ្មានគ្រាប់មីន*** សេសសល់នៅតាមផ្ទះ នៅតាមស្រែចំការ និង តាមទីធ្លាកំសាន្តក្នុងភូមិ ។

8-អ្នកភូមិដែលបាត់បង់ ***ដីធ្លី*** ដោយសារសង្គ្រាម និង គ្រាប់មីនទទួលបានសិទ្ធិកាន់កាប់ដីធ្លីដែលដោះមីនរួច ឬ ដីធ្លីផ្សេងៗទៀត ។

---

[95] Ouk Sisovann- Memo to Land Mine Monitor 28 February, 2001, Phnom Penh, Cambodia.
[96] Land Mine Team, Jesuit Service Cambodia July,1999.

9-អ្នកពិការទទួលបាន*ជើងសិប្បនិមិត្ត* រទេះជនពិការ ។ល។ ហើយនឹងទទួលបានសេវាសមរម្យសំរាប់តាមដានរបួសរបស់គេ ។

10-*ផ្លូវថ្នល់* ទៅកាន់ទីផ្សារ ផ្លូវទៅកាន់ប្រព័ន្ធចែកចាយទឹក មានភាពងាយស្រួលសំរាប់ភូមិរបស់ពួកគេ ។

11-*ឧទាហរណ៍* ជាគំរូមួយចំនួនស្តីពីអ្នកភូមិ ហើយនិង អ្នកពិការចេះជួយគ្នាទៅវិញទៅមក ហើយធ្វើការងារជាមួយគ្នាដោះស្រាយបញ្ហារួមដោយ អ្នកភូមិចូលរួមធ្វើការសំរេចចិត្តនូវអ្វីដែលជះឥទ្ធិពលទៅលើការរស់នៅប្រចាំថ្ងៃរបស់ពួកគេ និង ចូលរួមក្នុងសកម្មភាពផ្នែកវប្បធម៌និងសាសនារបស់ភូមិពួកគេ ។

12-អ្នកភូមិមានការ *យល់ដឹង* ពីគ្រោះថ្នាក់ដោយសារគ្រាប់មីន ហើយនឹង មិនថ្លៃឬយកមីន ឬ គ្រាប់មិនទាន់ផ្ទុះទៅធ្វើជាឧបករណ៍សំរាប់រកចំណូលក្នុងគ្រួសារឡើយ ។

ពង្រាងច្បាប់ស្តីពីជនពិការឆ្នាំ២០០០មិនមានការផ្លាស់ប្តូរទេ ។